# ព្រះរាជក្រម

នស/រកម/០៦២៣/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ២៦៧
ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៣
ម៉ោង: [illegible]

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមលើ
# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន

**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន ដែលបានចុះហត្ថលេខានៅរដ្ឋធានីម៉ានីលនៃសាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២៣

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

នស/រកម.០៦២៣.០១៣

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**



ទោះបញ្ចូលរក្សាសិទ្ធិ | https://t.me/oa_channel

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន

រដ្ឋាភិបាលនៃព្រុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលតទៅនេះហៅកាត់ជារួមថា "បណ្តារដ្ឋសមាជិក" ឬហៅកាត់រដ្ឋនីមួយៗថា "រដ្ឋសមាជិក"

**ដោយកត់សម្គាល់** កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ប្រទេសថៃ (ដែលតទៅនេះហៅកាត់ថា "AFAS") និងពិធីសារអនុវត្តន៍ជាបន្តបន្ទាប់របស់កិច្ចព្រមព្រៀងនេះ ដែលមានគោលបំណង ពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក លុបបំបាត់ឱ្យបានច្រើនបំផុតលើការរឹតត្បិតទាំងឡាយ ចំពោះពាណិជ្ជកម្មសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម តាមរយៈការពង្រីកភាពស៊ីជម្រៅ និងវិសាលភាពនៃការធ្វើសេរីភាវូបនីយកម្មឱ្យលើសពីអ្វី ដែលបានធ្វើឡើងដោយបណ្តារដ្ឋសមាជិក នៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS)

**ដោយពិចារណា** លើអាណត្តិរបស់ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី៧ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យឡើងវិញ និងលើកកម្ពស់កិច្ចព្រមព្រៀងAFAS ដែលមានជាធរមាន ក្នុងការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចនិងវិស័យសេដ្ឋកិច្ចអាស៊ាន ក្នុងន័យដូចគ្នាដែលអាស៊ានបានផ្លាស់ប្តូរកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន ព្រមទាំងកិច្ចព្រមព្រៀងអាស៊ានសម្រាប់ការជំរុញនិងការការពារវិនិយោគ ទៅជាកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន (ACIA) និងកិច្ចព្រមព្រៀងស្តីពីគម្រោងអនុគ្រោះពន្ធគយប្រកបដោយប្រសិទ្ធភាពជារួមសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ទៅជាកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

**ដោយពិចារណាផងដែរ** ទៅលើគោលការណ៍ណែនាំ និងគោលបំណង ក្នុងការលើកកម្ពស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន (ATISA) ដែលបានអនុម័តនៅកិច្ចប្រជុំAEM លើកទី៤៤ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ នៅទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា

**ដោយកត់សម្គាល់** លើសេចក្តីសម្រេចរបស់កិច្ចប្រជុំAEM លើកទី៤៨ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ដែលបានណែនាំឱ្យមន្ត្រីពាក់ព័ន្ធពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់វិធីសាស្ត្របែបបញ្ជីអវិជ្ជមាន ដែលអាចអនុវត្តបានក្រោមកិច្ចព្រមព្រៀង ATISA ដោយពិចារណាលើអាណត្តិរបស់ផែនការមេគ្រោងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងនូវការវិវឌ្ឍនៃការចរចាដែលកំពុងបន្តធ្វើនៅក្រោមក្របខ័ណ្ឌផ្សេងៗទៀត

**ដោយទទួលស្គាល់ថា** កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់អាស៊ាននឹងជានាទូវក្របខ័ណ្ឌពាណិជ្ជកម្មសេរីមួយសម្រាប់ពាណិជ្ជកម្មសេវាកម្ម ដែលនឹងពង្រឹងនិងលើកកម្ពស់ដល់ពាណិជ្ជកម្មសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក

**ដោយអះអាងជាថ្មី** អំពីការសន្យារបស់យើងចំពោះវិធាននិងគោលការណ៍នានាក្រោមកិច្ចព្រមព្រៀង GATS ព្រមទាំងកត់សម្គាល់លើមាត្រាV នៃកិច្ចព្រមព្រៀងGATS ដែលអនុញ្ញាតដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មរវាងឬក្នុងចំណោមបណ្តាភាគី ក្រោមកិច្ចព្រមព្រៀងសមាហរណកម្មសេដ្ឋកិច្ច

**បានព្រមព្រៀងគ្នាដូចខាងក្រោម៖**

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១
### គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បី៖

(ក) ពង្រឹងការតភ្ជាប់សេដ្ឋកិច្ចនិងផ្តល់កាលានុវត្តភាពកាន់តែច្រើន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច

(ខ) បង្កើនពាណិជ្ជកម្មនិងការវិនិយោគលើវិស័យសេវាកម្ម ព្រមទាំងបង្កើតទីផ្សារឱ្យកាន់តែទូលំទូលាយ និងសេដ្ឋកិច្ចមាត្រដ្ឋានកាន់តែធំ

(គ) កាត់បន្ថយរបាំងពាណិជ្ជកម្មនិងការវិនិយោគក្នុងវិស័យសេវាកម្ម និងបង្កើតបរិយាកាសធុរកិច្ចដែលអាចព្យាករបាន

(ឃ) ពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងបណ្តារដ្ឋសមាជិកតាមរយៈ៖ ការជំរុញនិងការសម្រួលដល់ការប្រើប្រាស់នូវកាលានុវត្តភាពដ៏ទូលំទូលាយ ដែលផ្តល់ដោយកិច្ចព្រមព្រៀងនេះ ការជំរុញកិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្ម ការបង្កើតកិច្ចសហប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើនការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងសកម្មភាពពាណិជកម្មនិងការវិនិយោគ *ជាដើម* និង

(ង) កាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងបណ្តារដ្ឋសមាជិក ដើម្បីអាចសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយសមធម៌ គុណភាព និងចីរភាព។




https://t.me/oa_channel

## មាត្រា២
## វិសាលភាព

១. កិច្ចព្រមព្រៀងនេះអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយបណ្តារដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។

២. កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះ៖

(ក) សេវាកម្មដែលត្រូវបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាលនៅក្នុងដែនដីនៃរដ្ឋសមាជិកនីមួយៗ

(ខ) ច្បាប់ បទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា ដែលគ្រប់ដណ្តប់លើលទ្ធកម្មដោយភ្នាក់ងាររដ្ឋាភិបាលចំពោះសេវាកម្មទាំងឡាយ ដែលត្រូវបានទិញសម្រាប់គោលបំណងរដ្ឋាភិបាល ហើយមិនស្ថិតក្នុងរូបភាពនៃការលក់បន្តបែបពាណិជ្ជកម្ម ឬក៏មិនស្ថិតក្នុងរូបភាពនៃការប្រើប្រាស់ដើម្បីផ្គត់ផ្គង់សេវាកម្មដល់ការលក់បែបពាណិជ្ជកម្ម

(គ) តីវនាវាចរណ៍

(ឃ) ឧបត្ថម្ភធននិងជំនួយ និង

(ង) សិទ្ធិចរាចរណ៍ផ្លូវអាកាស បើទោះបីជាត្រូវបានអនុញ្ញាតក៏ដោយ ឬសេវាកម្មដែលពាក់ព័ន្ធដោយផ្ទាល់នឹងការអនុវត្តសិទ្ធិចរាចរណ៍ និង(ច) សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស លើកលែងតែសេវាកម្មដែលគាំទ្រដល់ការដឹកជញ្ជូនតាមផ្លូវអាកាស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធស្តីពីសេវាកម្មដែលគាំទ្រដល់ការដឹកជញ្ជូនតាមផ្លូវអាកាស។

## មាត្រា៣
## ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

១. កិច្ចព្រមព្រៀងACIA ដែលបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ នៅទីក្រុងឆាអាម ព្រះរាជាណាចក្រថៃ ព្រមទាំងការធ្វើវិសោធនកម្មជាបន្តបន្ទាប់របស់កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះវិធានការទាំងឡាយណា ដែលអនុម័តដោយឬរក្សាទុកដោយរដ្ឋសមាជិកណាមួយ ដែលគ្រប់ដណ្តប់ដោយកិច្ចព្រមព្រៀងនេះឡើយ។

២. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ១ ក្នុងគោលបំណងនៃការការពារវិនិយោគពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មតាមវត្តមានពាណិជ្ជកម្ម នោះមាត្រា១១ (ប្រព្រឹត្តិកម្មនៃការវិនិយោគ) មាត្រា១២ (សំណងក្នុងករណីមានកលយុគ) មាត្រា១៣ (ការផ្ទេរ) មាត្រា១៤ ( ការដកហូត និងសំណង) មាត្រា១៥ (ឧបាទេសកម្ម) និងផ្នែក"ខ" (វិវាទវិនិយោគរវាងវិនិយោគិននិងរដ្ឋសមាជិកមួយ) នៃកិច្ចព្រមព្រៀងACIA ត្រូវបានអនុវត្ត *ហើយត្រូវយកមកអនុវត្តដូចគ្នា* ចំពោះវិធានការនានាដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវាកម្ម ដោយអ្នកផ្គត់ផ្គង់សេវាកម្មណាមួយរបស់រដ្ឋសមាជិកតាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ប៉ុន្តែនៅត្រឹមវិសាលភាពដែលវិធានការទាំងនោះជាប់ពាក់ព័ន្ធនឹងការវិនិយោគ និងកាតព្វកិច្ចដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងACIA ប៉ុណ្ណោះ ។



៣. ដើម្បីជៀសវាងការសង្ស័យ មាត្រា១១ (ប្រព្រឹត្តិកម្មនៃការវិនិយោគ) មាត្រា១២ (សំណងក្នុងករណីមានកលយុគ) មាត្រា១៣ (ការផ្ទេរ) មាត្រា១៤ (ការដកហូត និងសំណង) មាត្រា១៥ (ឧបាទេសកម្ម) និងផ្នែក"ខ" (វិវាទវិនិយោគរវាងវិនិយោគិននិងរដ្ឋសមាជិកមួយ) នៃកិច្ចព្រមព្រៀងACIA មិនត្រូវបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះឡើយ។

៤. ដើម្បីឱ្យកាន់តែច្បាស់ រាល់ការលើ្មសនឹងប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវផ្អែកលើយន្តការដោះស្រាយវិវាទណាមួយក្រោមកិច្ចព្រមព្រៀងACIA ឡើយ រួមបញ្ចូលទាំងយន្តការដោះស្រាយវិវាទរវាងវិនិយោគិននិងរដ្ឋ ប៉ុន្តែមិនកំណត់ឡើយ។

## មាត្រា៤
## ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងអាស៊ានស្តីពីបន្លាស់ទីរូបវន្តបុគ្គល

១. កិច្ចព្រមព្រៀងអាស៊ានស្តីពីបន្លាស់ទីរូបវន្តបុគ្គល ដែលបានចុះហត្ថលេខា នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា (ដោយហៅកាត់ថា "កិច្ចព្រមព្រៀងអាស៊ានស្តីពីMNP") ត្រូវអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ការផ្តត់ផ្គង់សេវាកម្ម តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយ នៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ហើយត្រូវមានអធិកភាពចំពោះករណីអសង្គតិភាពណាមួយទៅនឹងកិច្ចព្រមព្រៀងនេះ។

២. ដោយយោងទៅតាមប្រការទាំងឡាយនៅក្រោមផ្នែកទី២ និងទី៣ នៃកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងអាស៊ានស្តីពីMNP ត្រូវមានអធិកភាព និងត្រូវអនុវត្តទាំងស្រុងលើវិធានការដែលជះឥទ្ធិពលដល់ការផ្តត់ផ្គង់សេវាកម្ម តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។

## មាត្រា៥
## និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ វាក្យសព្ទ៖

(ក) **"សេវាកម្មដែលត្រូវបានផ្តត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល"** សំដៅដល់ រាល់សេវាកម្មទាំងឡាយ ដែលត្រូវបានផ្តត់ផ្គង់ក្នុងរូបភាពដែលមិនមែនជាការធ្វើពាណិជ្ជកម្ម ឬការប្រកួតប្រជែងជាមួយអ្នកផ្តត់ផ្គង់សេវាមួយឬច្រើនផ្សេងទៀត។

(ខ) **"វត្តមានពាណិជ្ជកម្ម"** សំដៅដល់ បែបផែនទាំងឡាយនៃការបង្កើតស្ថាប័នធុរកិច្ច ឬស្ថាប័នវិជ្ជាជីវៈ រួមទាំងតាមរយៈ៖

(i) ការបង្កើត ការទិញយក ឬការរក្សាទុកនូវនីតិបុគ្គលណាមួយ ឬ

(ii) ការបង្កើតឬការរក្សាទុកនូវសាខាឬការិយាល័យតំណាងណាមួយ

នៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ក្នុងគោលបំណងផ្តត់ផ្គង់សេវាកម្ម។



https://t.me/oa_channel

(គ) "គ្រឿងបរិក្ខារកុំព្យូទ័រ" សំដៅដល់ បណ្តុំសមីកុំព្យូទ័រនិងឧបករណ៍ផ្ទុកឯកសារ សម្រាប់ការដំណើរការឬការផ្ទុកព័ត៌មានសម្រាប់ការប្រើប្រាស់បែបពាណិជ្ជកម្ម។

(ឃ) "ពន្ធផ្ទាល់" រួមបញ្ចូលនូវបណ្តាពន្ធលើចំណូលសរុប លើមូលធនសរុប ឬលើសមាសធាតុនៃចំណូលឬនៃមូលធន រួមទាំងបណ្តាពន្ធលើអត្ថប្រយោជន៍ពីការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ពន្ធលើអចលនទ្រព្យ កេរមរតក និងអំណោយ និងពន្ធលើប្រាក់ឈ្នួលឬប្រាក់បៀវត្សរ៍សរុប ដែលចំណាយដោយសហគ្រាស ក៏ដូចជាបណ្តាពន្ធលើការរម្លស់មូលធន។

(ង) "កញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀង AFAS" សំដៅដល់ កញ្ចប់សន្យាទី១០ ដែលត្រូវបានធ្វើឡើងដោយបណ្តារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងAFAS ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីAEM និងកញ្ចប់សន្យាចុងក្រោយដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន (AFM) និងរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន (ATM) នៅមុនការចូលជាធរមាននៃតារាងវិធានការបដិលោម ស្របតាមមាត្រា១១ (វិធានការបដិលោម)។

(ច) "GATS" សំដៅដល់ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម។

(ឆ) "ការវិនិយោគ" សំដៅដល់ ការវិនិយោគដែលត្រូវបានផ្តល់និយមន័យក្រោមកថាខណ្ឌ(គ) នៃមាត្រា៤ (និយមន័យ) នៃកិច្ចព្រមព្រៀងACIA ដូចដែលអាចនឹងត្រូវបានធ្វើវិសោធនកម្ម

(ជ) "វិនិយោគិន" សំដៅដល់ រូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយ ឬនីតិបុគ្គលនៃរដ្ឋសមាជិកមួយ ដែលកំពុងធ្វើឬបានធ្វើការវិនិយោគនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។

(ឈ) "នីតិបុគ្គល" សំដៅដល់ នីតិបុគ្គលទាំងឡាយ ដែលត្រូវបានបង្កើតឬរៀបចំឡើងនៅក្រោមច្បាប់ជាធរមាននៃរដ្ឋសមាជិកមួយ ទោះជាក្នុងគោលបំណងដើម្បីប្រាក់ចំណេញ ឬក្នុងគោលបំណងដទៃទៀត ទោះជាកម្មសិទ្ធិឯកជនឬកម្មសិទ្ធិរបស់រដ្ឋាភិបាល រួមមានសាជីវកម្ម ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចម្រុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬសមាគម។

(ញ) "នីតិបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀត" សំដៅដល់ នីតិបុគ្គលដែលៈ

(i) ត្រូវបានបង្កើតឬរៀបចំឡើងនៅក្រោមច្បាប់របស់រដ្ឋសមាជិកផ្សេងទៀតនោះ ព្រមទាំងចូលរួមក្នុងប្រតិបត្តិការជុំកិច្ចជាដុំកំភួន នៅក្នុងដែនដីនៃរដ្ឋសមាជិកនោះ ឬរដ្ឋសមាជិកផ្សេងទៀត ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ដែលត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយៈ

(១) រូបវន្តបុគ្គលនៃរដ្ឋសមាជិកនោះ ឬ

(២) នីតិបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀតនោះ ដូចមានចែងក្នុងវាក្យខណ្ឌ(i)

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

(ង) នីតិបុគ្គល៖

(i) "ត្រូវបានកាន់កាប់" ដោយបុគ្គលនៃរដ្ឋសមាជិកមួយ ប្រសិនបើកម្មសិទ្ធិលើសពី ៥០ភាគរយនៃភាគទុនរបស់នីតិបុគ្គលនោះ ត្រូវបានកាន់កាប់ដោយបុគ្គលនៃរដ្ឋសមាជិកនោះ

(ii) "ត្រូវបានគ្រប់គ្រង" ដោយបុគ្គលនៃរដ្ឋសមាជិកមួយ ប្រសិនបើបុគ្គលនោះមានអំណាចតែងតាំងសមាសភាពភាគច្រើននៃនាយករបស់ខ្លួន ឬមានសិទ្ធិដឹកនាំតាមផ្លូវច្បាប់នូវសកម្មភាពនានានៃនីតិបុគ្គលនោះ និង

(iii) "ត្រូវបានចងសម្ព័ន្ធ" ជាមួយបុគ្គលផ្សេងទៀត នៅពេលដែលនីតិបុគ្គលនោះគ្រប់គ្រងឬត្រូវបានគ្រប់គ្រងដោយបុគ្គលផ្សេងទៀតនោះ ឬនៅពេលដែលទាំងនីតិបុគ្គលនិងបុគ្គលផ្សេងទៀតនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលដូចគ្នា។

(ច) "វិធានការ" សំដៅដល់ វិធានការទាំងឡាយចាត់ឡើងដោយរដ្ឋសមាជិកមួយ ទោះជាក្នុងទម្រង់ច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសម្រេច វិធានការរដ្ឋបាល ឬក្នុងទម្រង់ផ្សេងទៀត[1]

(ឆ) "វិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក" សំដៅដល់ វិធានការទាំងឡាយណា ដែលធ្វើឡើងដោយ៖

(i) រដ្ឋាភិបាលនិងអាជ្ញាធរថ្នាក់មជ្ឈិម ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋសមាជិកមួយ និង

(ii) អង្គភាពក្រៅរដ្ឋាភិបាលនានា ដែលប្រើប្រាស់នូវអំណាចប្រតិភូកម្មដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់មជ្ឈិម ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋសមាជិកមួយ

(ជ) "វិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម" រួមបញ្ចូលទាំងវិធានការនានា ដែលពាក់ព័ន្ធនឹង៖

(i) ការទិញ ការទូទាត់ ឬការប្រើប្រាស់សេវាកម្ម

(ii) ឱកាសទទួលបាននិងការប្រើប្រាស់នូវសេវាកម្មទាំងឡាយ ដែលត្រូវបានតម្រូវដោយរដ្ឋសមាជិកឱ្យផ្តល់នូវសេវាកម្មនោះដល់សាធារណជនទូទៅ ដោយវិធានការបែបនេះពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្ម និង

(iii) វត្តមាននៃបុគ្គល រួមទាំងវត្តមានពាណិជ្ជកម្មរបស់រដ្ឋសមាជិកមួយ ដើម្បីធ្វើការផ្គត់ផ្គង់សេវាកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត

---

[1] វិធានការ ត្រូវរួមបញ្ចូលទាំងបណ្តាវិធានការពន្ធទៅតាមវិសាលភាពដូចមានគ្របដណ្តប់ដោយកិច្ចព្រមព្រៀង GATS។



តេលេក្រាម ឯកសារសាធារណៈ | https://t.me/oa_channel

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

(ណ) "អ្នកផ្គត់ផ្គង់សេវាផ្ដាច់មុខ" សំដៅដល់ បុគ្គល ស្ថាប័នសាធារណៈ ឬស្ថាប័នឯកជន ដែលនៅក្នុងទីផ្សារពាក់ព័ន្ធក្នុងដែនដីនៃរដ្ឋសមាជិកមួយ ត្រូវបានអនុញ្ញាតឬត្រូវបានបង្កើតឡើងជាផ្លូវការឬជាធរមានដោយរដ្ឋសមាជិកនោះ ឱ្យធ្វើជាអ្នកផ្គត់ផ្គង់តែមួយគត់នូវសេវាកម្មនោះ

(ត) "រូបវន្តបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀត" សំដៅដល់ រូបវន្តបុគ្គលដែលស្ថិតក្រោមច្បាប់នៃរដ្ឋសមាជិកនោះ៖

(i) គឺជាជនជាតិឬពលរដ្ឋនៃរដ្ឋសមាជិកនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នៅក្នុងដែនដីនៃរដ្ឋសមាជិកនោះ ករណីដែលទាំងរដ្ឋសមាជិកនោះនិងរដ្ឋសមាជិកដែលបុគ្គលនោះផ្គត់ផ្គង់សេវាកម្ម ទទួលស្គាល់និវេសនជនអចិន្ត្រៃយ៍ ហើយផ្តល់នូវប្រព្រឹត្តិកម្មចំពោះនិវេសនជនអចិន្ត្រៃយ៍របស់ខ្លួន ដូចគ្នាស្មើរទាំងស្រុងទៅនឹងការផ្តល់នូវប្រព្រឹត្តិកម្មចំពោះជនជាតិខ្លួនពាក់ព័ន្ធនឹងវិធានការនានាដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម

(ថ) "បុគ្គល" សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល

(ទ) "វិស័យ" នៃសេវាកម្មមួយ សំដៅដល់៖

(i) ដោយយោងទៅនឹងការសន្យាតាមវិស័យ គឺជាអនុវិស័យមួយ ឬច្រើន ឬទាំងអស់នៃសេវាកម្មនោះ ដូចបានបញ្ជាក់នៅក្នុងតារាងសន្យាតាមវិស័យរបស់រដ្ឋសមាជិកមួយ

(ii) ម្យ៉ាងទៀត ជាវិស័យសេវាកម្មនោះទាំងមូល ដែលរួមបញ្ចូលនូវអនុវិស័យសេវាកម្មទាំងអស់របស់វា

(ធ) "សេវាកម្ម" រួមបញ្ចូលនូវសេវាកម្មទាំងឡាយនៅក្នុងវិស័យទាំងឡាយ លើកលែងតែសេវាកម្មដែលត្រូវបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល

(ន) "អ្នកប្រើប្រាស់សេវាកម្ម" សំដៅដល់ បុគ្គលទាំងឡាយណាដែលទទួលយកឬប្រើប្រាស់សេវាកម្ម

(ប) "សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត" សំដៅដល់ សេវាកម្មណាមួយដែលត្រូវបានផ្គត់ផ្គង់៖

(i) ចេញពីឬនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀតនោះ ឬក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ត្រូវបានផ្គត់ផ្គង់ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់នៃរដ្ឋសមាជិកផ្សេងទៀតនោះ ឬដោយបុគ្គលណាមួយនៃរដ្ឋសមាជិកផ្សេងទៀតនោះ ដែលផ្គត់ផ្គង់សេវាកម្មតាមរយៈប្រតិបត្តិការរបស់នាវាណាមួយ និង/ឬការប្រើប្រាស់នាវានោះទាំងស្រុងឬដោយផ្នែក ឬ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

(ii) ដោយអ្នកផ្គត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតនោះ ក្នុងករណីការផ្គត់ផ្គង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គល

(ផ) **"អ្នកផ្គត់ផ្គង់សេវាកម្ម"** សំដៅដល់ បុគ្គលទាំងឡាយដែលធ្វើការផ្គត់ផ្គង់សេវាកម្ម[2]

(ព) "ការផ្គត់ផ្គង់សេវាកម្ម" រួមបញ្ចូលនូវផលិតកម្ម ការចែកចាយ ការធ្វើទីផ្សារ ការលក់ និងការផ្តល់សេវាកម្ម

(ភ) **"ពាណិជ្ជកម្មសេវាកម្ម"** សំដៅដល់ ការផ្គត់ផ្គង់សេវាកម្មៈ

(i) ចេញពីដែនដីនៃរដ្ឋសមាជិកមួយ ចូលទៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន")

(ii) នៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ទៅដល់អ្នកប្រើប្រាស់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត ("ការប្រើប្រាស់សេវាកម្មនៅបរទេស");

(iii) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("វត្តមានពាណិជ្ជកម្ម");

(iv) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("វត្តមានរូបវន្តបុគ្គល") និង

(ម) **"សិទ្ធធ្វើចរាចរ"** សំដៅដល់ សិទ្ធិទាំងឡាយសម្រាប់សេវាកម្មដែលមានក្នុងតារាងសន្យា ឬគ្មានក្នុងតារាងសន្យា ដើម្បីធ្វើប្រតិបត្តិការ និង/ឬ ដឹកអ្នកដំណើរ ទំនិញ និងបញ្ញើ ដើម្បីទទួលបានជាលាភការ ឬជាការជួលចេញពី ទៅកាន់ នៅក្នុង ឬពីលើដែនដីនៃរដ្ឋសមាជិកមួយ រួមបញ្ចូលទាំងគោលដៅបម្រើសេវាកម្ម ផ្លូវធ្វើប្រតិបត្តិការ ប្រភេទនៃចរាចរ សមត្ថភាពដែលត្រូវផ្តល់ ពន្ធគយដែលត្រូវយកព្រមជាមួយលក្ខខណ្ឌនានា និងលក្ខណៈវិនិច្ឆ័យនានាសម្រាប់ការកំណត់ក្រុមហ៊ុនអាកាសចរណ៍ រួមបញ្ចូលទាំងលក្ខណៈវិនិច្ឆ័យ ដូចជាតួលេខ ភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រង។

## ផ្នែកទី២
## កាតព្វកិច្ចស្នូល និងវិន័យ

### មាត្រា៦
### ប្រព្រឹត្តិកម្មជាតិ

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត ពាក់ព័ន្ធនឹងរាល់វិធានការដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវាកម្ម នូវប្រព្រឹត្តិកម្មដែលមាន

---

[2] ករណីដែលសេវាកម្មពុំត្រូវបានផ្គត់ផ្គង់ផ្ទាល់ដោយនីតិបុគ្គលណាមួយ ប៉ុន្តែត្រូវបានផ្គត់ផ្គង់តាមរយៈទម្រង់ផ្សេងៗនៃវត្តមានពាណិជ្ជកម្ម ដូចជាសាខាណាមួយ ឬការិយាល័យតំណាងណាមួយ នោះអ្នកផ្គត់ផ្គង់សេវាកម្ម (ឧទាហរណ៍ នីតិបុគ្គល) តាមរយៈវត្តមានបែបនេះ ក៏ត្រូវទទួលបាននូវប្រព្រឹត្តិកម្មដែលផ្តល់ចំពោះអ្នកផ្គត់ផ្គង់សេវាកម្មទាំងឡាយនៅក្រោមកិច្ចព្រមព្រៀងនេះដែរ។ ប្រព្រឹត្តិកម្មបែបនេះ ត្រូវផ្តល់ចំពោះវត្តមានពាណិជ្ជកម្មដែលសេវាកម្មត្រូវបានផ្គត់ផ្គង់ ហើយមិនចាំបាច់ផ្តល់ដល់ផ្នែកផ្សេងៗទៀតរបស់អ្នកផ្គត់ផ្គង់នោះ ដែលមានទីតាំងនៅក្រៅដែនដីដែលសេវាកម្មនោះត្រូវបានផ្គត់ផ្គង់ឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

ភាពអនុគ្រោះមិនឱ្យតិចជាងប្រព្រឹត្តិកម្មដែលខ្លួនផ្ដល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា[3] ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មរបស់ខ្លួន។[4]

២. រដ្ឋសមាជិកមួយអាចបំពេញបានតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ១ តាមរយៈការផ្ដល់ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មជាផ្លូវការដូចគ្នាឬប្រព្រឹត្តិកម្មជាផ្លូវការខុសគ្នា ពីប្រព្រឹត្តិកម្មដែលខ្លួនផ្ដល់ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មដូចគ្នារបស់ខ្លួន។

៣. ប្រព្រឹត្តិកម្មជាផ្លូវការដូចគ្នាឬជាផ្លូវការខុសគ្នា ត្រូវចាត់ទុកថាមានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខណ្ឌប្រកួតប្រជែង ដោយផ្ដល់ភាពអនុគ្រោះដល់សេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកនោះ ធៀបនឹងសេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មដូចគ្នានៃរដ្ឋសមាជិកផ្សេងទៀត។

## មាត្រា៧
## ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្ដល់ដល់អ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្ដល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់អ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក។

២. រដ្ឋសមាជិកនីមួយៗ ត្រូវផ្ដល់ដល់សេវាកម្មដែលផ្គត់ផ្គង់ដោយរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្ដល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់សេវាកម្មដែលផ្គត់ផ្គង់នៅក្នុងដែនដីរបស់ខ្លួនដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក។

៣. ដើម្បីឱ្យកាន់តែច្បាស់ ពាក់ព័ន្ធនឹងសេវាកម្មដែលស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ប្រព្រឹត្តិកម្មអនុគ្រោះទាំងឡាយណា ដែលផ្ដល់ដោយរដ្ឋសមាជិកមួយដល់អ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀតឬរដ្ឋមិនមែនសមាជិក ព្រមទាំងដល់សេវាកម្មរបស់រដ្ឋទាំងនោះ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងឬកិច្ចរៀបចំនាពេលអនាគត ដែលរដ្ឋសមាជិកមួយគឺជាភាគីត្រូវធ្វើការផ្ដល់បន្តដល់បណ្ដារដ្ឋសមាជិកទាំងអស់ផងដែរ ដោយផ្អែកលើមូលដ្ឋានប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត។ កិច្ចព្រមព្រៀងនិងកិច្ចរៀបចំទាំងឡាយ ដែលបានបញ្ចប់ឬបានចុះហត្ថលេខា នាមុនការចុះហត្ថលេខានៃកិច្ចព្រមព្រៀងATISA និងវិសោធនកម្មទាំងឡាយក្នុងពេលអនាគតរបស់កិច្ចព្រមព្រៀងឬកិច្ចរៀបចំទាំងនោះ មិនត្រូវក្លាយជាកម្មវត្ថុចំពោះមាត្រានេះឡើយ។

---

[3] ដើម្បីឱ្យកាន់តែច្បាស់ ថាតើប្រព្រឹត្តិកម្មត្រូវបានផ្ដល់ឱ្យក្នុង "លក្ខខណ្ឌដូចគ្នា" ឬយ៉ាងណា ក្រោមមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) ឬមាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) គឺវាអាស្រ័យទៅនឹងស្ថានភាពទាំងមូលនៃលក្ខខណ្ឌនានា រួមបញ្ចូល [illegible]ថាតើប្រព្រឹត្តិកម្មពាក់ព័ន្ធមានការបែកញែកខុសគ្នារវាងសេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មដែរឬយ៉ាងណា ដោយផ្អែកលើមូលដ្ឋាន[illegible]សុខមាលភាពសាធារណៈស្របច្បាប់។

[4] [illegible]មានអ្វីនៅក្នុងមាត្រានេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកណាមួយផ្ដល់នូវសំណងទូទាត់ចំពោះគុណវិបត្តិប្រកួតប្រជែង[illegible] ដែលជាលទ្ធផលចេញពីចរិតលក្ខណៈបរទេសនៃសេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មពាក់ព័ន្ធឡើយ។

៤. ប្រព្រឹត្តិកម្មដូចមានចែងក្នុងកថាខណ្ឌ១ដល់៣ ពុំត្រូវអនុវត្តចំពោះសេវាកម្មហិរញ្ញវត្ថុឡើយ ហើយមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ ត្រូវអនុវត្តចំពោះសេវាកម្មហិរញ្ញវត្ថុ។

៥. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ពុំត្រូវបកស្រាយដើម្បីរារាំងរដ្ឋសមាជិកណាមួយពីការប្រគល់ឬការផ្តល់នូវអត្ថប្រយោជន៍នានាដល់ប្រទេសជិតខាង ក្នុងគោលបំណងសម្រួលដល់ការដោះដូរនានា ដោយកំណត់ចំពោះតំបន់ដែលមានព្រំដែនជាប់គ្នា នូវសេវាកម្មដែលត្រូវបានផលិតនិងប្រើប្រាស់ក្នុងស្រុកឡើយ។

៦. ប៉ុន្តែបើមានចែងក្នុងកថាខណ្ឌ១ដល់៥ ខាងលើ រដ្ឋសមាជិកពីរឬច្រើនអាចធ្វើការចរចានិងព្រមព្រៀងគ្នា ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មចំពោះវិស័យឬអនុវិស័យជាក់លាក់នានា ("រដ្ឋសមាជិកដែលចូលរួម")។ ការផ្តល់បន្តទាំងឡាយនូវប្រព្រឹត្តិកម្មអនុគ្រោះបែបនេះដល់រដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តត្រង់ផ្នែកណាដែលជារបស់រដ្ឋសមាជិកដែលចូលរួម។

៧. រដ្ឋសមាជិកដែលចូលរួមត្រូវផ្តល់ព័ត៌មានដល់រដ្ឋសមាជិកដែលនៅសេសសល់ តាមរយៈលេខាធិការដ្ឋានអាស៊ាន អំពីវឌ្ឍនភាពឬក៏លទ្ធផលនៃការចរចា។ រដ្ឋសមាជិកដែលមានបំណងចូលរួមក្នុងការចរចាដែលកំពុងបន្តក្នុងចំណោមរដ្ឋសមាជិកដែលចូលរួម អាចធ្វើបែបនេះបានដោយការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកដែលចូលរួម។

៨. រដ្ឋសមាជិកណាមួយ ដែលមិនមែនជាភាគីទៅនឹងកិច្ចព្រមព្រៀងណាមួយដែលសម្រេចបានអនុលោមតាមកថាខណ្ឌ៦ នាពេលសមស្របណាមួយ អាចក្លាយជាភាគីមួយនៃកិច្ចព្រមព្រៀងនោះ ដោយផ្តល់នូវការសន្យានៅត្រឹមកម្រិតប្រហាក់ប្រហែលគ្នាឬកម្រិតដែលអាចទទួលយកបានដល់រដ្ឋសមាជិកដែលចូលរួម។

## មាត្រា៨
## ច្រកចូលទីផ្សារ

បើទោះជាផ្អែកលើមូលដ្ឋាននៃផ្នែកណាមួយរបស់តំបន់ ឬផ្អែកលើមូលដ្ឋាននៃដែនដីទាំងមូលរបស់ខ្លួនក្តី រដ្ឋសមាជិកមួយមិនត្រូវរក្សាទុកឬអនុម័តនូវវិធានការទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា៖

(ក) ការដាក់កំណត់ទៅលើចំនួនអ្នកផ្គត់ផ្គង់សេវាកម្ម ទោះជាក្នុងទម្រង់កូតាចំនួន ភាពផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ខ) ការដាក់កំណត់ទៅលើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសកម្ម ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

https://t.me/oa_channel

(គ) ការដាក់កំណត់ទៅលើចំនួនសរុបនៃការប្រតិបត្តិសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្ម គិតជាឯកតាលេខដែលបានរៀបចំឡើងក្នុងទម្រង់ជាកូតា ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច[5]

(ឃ) ការដាក់កំណត់ទៅលើចំនួនសរុបនៃរូបវន្តបុគ្គល ដែលអាចនឹងត្រូវបានជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មជាក់លាក់ណាមួយ ឬដែលអ្នកផ្គត់ផ្គង់សេវាកម្មអាចនឹងជួលមកធ្វើការ ហើយជាបុគ្គលដែលចាំបាច់សម្រាប់និងដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាកម្មជាក់លាក់ណាមួយ ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវ សម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយណាដែលរឹតត្បិត ឬតម្រូវចំពោះប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះទុន ដែលតាមរយៈវិធានការទាំងនោះ ទើបអ្នកផ្គត់ផ្គង់សេវាកម្មអាចផ្តល់សេវាកម្មណាមួយបាន និង

(ច) ការដាក់កំណត់ទៅលើការរួមចំណែកនៃមូលធនបរទេស ក្នុងទម្រង់ជាអត្រាភាគរយអតិបរមាដែលអនុញ្ញាតចំពោះភាគទុនបរទេស ឬលើតម្លៃសរុបនៃការវិនិយោគបរទេសជាលក្ខណៈបុគ្គលឬជាលក្ខណៈរួម។

## មាត្រា៩
## វត្តមានក្នុងស្រុក

រដ្ឋសមាជិកមួយមិនត្រូវដាក់លក្ខខណ្ឌតម្រូវ ដើម្បីឱ្យអ្នកផ្គត់ផ្គង់សេវាកម្មណាមួយរបស់រដ្ឋសមាជិកផ្សេងទៀត ធ្វើការបង្កើតឬរក្សាទុកនូវការិយាល័យតំណាងឬទម្រង់ទាំងឡាយនៃនីតិបុគ្គល ឬក្លាយជានិវាសនជន នៅក្នុងដែនដីរបស់ខ្លួន ដែលចាត់ទុកជាលក្ខខណ្ឌមួយសម្រាប់ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែនឡើយ។[6]

## មាត្រា១០
## គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល

១. រដ្ឋសមាជិកមួយមិនត្រូវដាក់លក្ខខណ្ឌតម្រូវ ដើម្បីឱ្យនីតិបុគ្គលណាមួយរបស់រដ្ឋសមាជិកនោះផ្តល់ការតែងតាំងនៅក្នុងតួនាទីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដល់រូបវន្តបុគ្គលនៃជនជាតិជាក់លាក់ណាមួយឡើយ។

---

[5] អនុកថាខណ្ឌ(គ) មិនគ្របដណ្តប់លើវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលដាក់កម្រិតចំពោះធាតុចូលសម្រាប់ការផ្គត់ផ្គង់សេវាកម្មឡើយ។

[6] គ្មានអ្វីនៅក្នុងមាត្រានេះ ដែលត្រូវរាំងរដ្ឋសមាជិកមួយពីការអនុម័តនិងរក្សាទុកនូវវិធានការនិយតកម្មនានារបស់ខ្លួន ពាក់ព័ន្ធនឹងការប្រើប្រាស់ទីតាំងនៃគ្រឿងបរិក្ខារកុំព្យូទ័រឡើយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២. រដ្ឋសមាជិកមួយអាចដាក់លក្ខខណ្ឌតម្រូវថា សមាសភាពភាគច្រើននៃក្រុមប្រឹក្សាភិបាលរបស់នីតិបុគ្គលណាមួយរបស់រដ្ឋសមាជិកនោះ គឺជាជនជាតិជាក់លាក់ណាមួយ ឬក៏ជានិវាសនជននៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ប្រសិនបើលក្ខខណ្ឌតម្រូវបែបនេះមិនបន្ថយនូវលទ្ធភាពរបស់វិនិយោគិនក្នុងការអនុវត្តការគ្រប់គ្រងទៅលើការវិនិយោគរបស់ខ្លួន។

## ផ្នែកទី៣
## ការរក្សាសិទ្ធិ

### មាត្រា១១
### វិធានការបដិលោម

១. មាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ប្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) ពុំអនុវត្តចំពោះ៖

(ក) វិធានការបដិលោមដែលមានស្រាប់ទាំងឡាយ ដែលត្រូវបានរក្សាទុកដោយរដ្ឋសមាជិកមួយនៅ៖

(i) ថ្នាក់មជ្ឈិមរបស់រដ្ឋាភិបាល ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI

(ii) ថ្នាក់តំបន់របស់រដ្ឋាភិបាល ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI ឬ

(iii) រដ្ឋាភិបាលថ្នាក់មូលដ្ឋាន

(ខ) ការបន្តឬការកែប្រែថ្មីភ្លាមៗនៃវិធានការបដិលោមទាំងឡាយ ដូចមានចែងក្នុងវាក្យខណ្ឌ(ក) ឬ

(គ) ការធ្វើវិសោធនកម្មលើវិធានការបដិលោមណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ(ក) ដោយស្ថិតក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មមិនបន្ថយនូវអនុលោមភាពនៃវិធានការនោះទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ប្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) ដូចដែលធ្លាប់មានស្រាប់ភ្លាមៗនៅមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃតារាងវិធានការបដិលោមរបស់រដ្ឋសមាជិកនីមួយៗ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

២. មាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) មិនអនុវត្តចំពោះវិធានការទាំងឡាយណា ដែលរដ្ឋសមាជិកមួយអនុម័តឬរក្សាទុកពាក់ព័ន្ធនឹងវិស័យ អនុវិស័យ ឬសកម្មភាព ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធII។

៣. តារាងវិធានការបដិលោមដូចមានចែងក្នុងឧបសម្ព័ន្ធIនិងII ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះត្រូវបង្កើតជាផ្នែកស្នូលនៃកិច្ចព្រមព្រៀង។

៤. បណ្តារដ្ឋសមាជិកត្រូវចាប់ផ្តើមការពិភាក្សានានា នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ដើម្បីអនុវត្តគោលការណ៍ ដែលពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មចំពោះវិធានការបដិលោមណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ១(ក) ដោយស្ថិតក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មមិនបន្ថយនូវអនុលោមភាពនៃវិធានការនោះទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) ដូចដែលធ្លាប់មានស្រាប់ភ្លាមៗនៅមុនការធ្វើវិសោធនកម្ម។ លទ្ធផលនៃការពិភាក្សាត្រូវយកមកអនុវត្ត នៅពេលតារាងវិធានការបដិលោមរបស់រដ្ឋសមាជិកនីមួយៗចូលជាធរមាន។

## មាត្រា១២
## ការផ្លាស់ប្តូរទៅជាតារាងវិធានការបដិលោម

១. បណ្តារដ្ឋសមាជិកត្រូវដាក់ជូនលេខាធិការដ្ឋានអាស៊ាន នូវតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI និងឧបសម្ព័ន្ធII ដោយយោងតាមមាត្រា១១ (វិធានការបដិលោម) ក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ វៀតណាមត្រូវទទួលបានពេលវេលាបន្ថែមរហូតដល់៧ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ាត្រូវទទួលបានពេលវេលាបន្ថែមរហូតដល់១៣ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ វិធានការបដិលោមដូចដែលមាននៅក្នុងតារាងរបស់រដ្ឋសមាជិកនីមួយៗ ត្រូវឆ្លុះបញ្ចាំងនូវកម្រិតនៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលមានសមភាពឬល្អប្រសើរជាង កម្រិតនៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មដែលបានផ្តល់រួចក្រោមកញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀង AFAS របស់ខ្លួន។

២. ក្នុងរយៈពេល២ឆ្នាំ បន្ទាប់ពីបណ្តារដ្ឋសមាជិករៀបចំរួចនូវតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធIនិងII ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ បណ្តារដ្ឋសមាជិក រក្សាសិទ្ធដើម្បីធ្វើវិសោធនកម្មលើតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធIនិងII ដោយស្ថិតនៅក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មនោះ មិនបង្កឱ្យមានភាពថយចុះនូវកម្រិតនៃការសន្យាដែលបានផ្តល់រួចក្រោមតារាងសន្យារបស់ខ្លួន ក្នុងកញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀងAFAS។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣. តារាងវិធានការបដិសេធក្នុងឧបសម្ព័ន្ធនិងII ដែលបានរៀបចំរួចដោយបណ្ដារដ្ឋសមាជិក ត្រូវមានជាធរមានជាមួយគ្នានឹងតារាងសន្យារបស់បណ្ដារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀង AFAS សម្រាប់រយៈពេល៧ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រយៈពេល៩ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់វៀតណាម ឬរយៈពេល១៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ រហូតដល់ពេលនោះ ករណីកើតមាននូវភាពខុសគ្នាក្នុងការបកស្រាយលើការសន្យារបស់រដ្ឋសមាជិកមួយ នោះតារាងសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងAFAS ត្រូវមានអាទិភាព។

## មាត្រា១៣
## វិធានការការពារសុវត្ថិភាព

១. បណ្ដារដ្ឋសមាជិកកត់សម្គាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រាX នៃកិច្ចព្រមព្រៀង GATS អំពីចម្ងល់ពីវិធានការការពារក្នុងសភាពអាសន្នផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្ដារដ្ឋសមាជិកត្រូវធ្វើការពិនិត្យឡើងវិញក្នុងគោលបំណងពិភាក្សាអំពីការធ្វើវិសោធនកម្មឱ្យបានសមស្របទៅលើកិច្ចព្រមព្រៀងនេះ ដើម្បីដាក់បញ្ចូលនូវលទ្ធផលទាំងឡាយនៃកិច្ចចរចាពហុភាគីទាំងនោះ។

២. ក្នុងករណីដែលការអនុវត្តការសន្យាដែលធ្វើឡើងនៅក្នុងកិច្ចព្រមព្រៀងនេះ បណ្ដាលឱ្យប៉ះពាល់ជាដុំកំភួនទៅលើវិស័យសេវាកម្មរបស់រដ្ឋសមាជិក នៅមុនការបញ្ចប់កិច្ចចរចាពហុភាគីដូចមានចែងក្នុងកថាខណ្ឌ១ រដ្ឋសមាជិកដែលរងការប៉ះពាល់អាចស្នើសុំឱ្យមានការពិគ្រោះយោបល់ជាមួយរដ្ឋសមាជិកនោះឬបណ្ដារដ្ឋសមាជិកពាក់ព័ន្ធ។ រដ្ឋសមាជិកឬបណ្ដារដ្ឋសមាជិកដែលត្រូវបានស្នើសុំត្រូវចូលរួមក្នុងការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកស្នើសុំ អំពីការសន្យាដែលរដ្ឋសមាជិកឬបណ្ដារដ្ឋសមាជិកដែលត្រូវបានស្នើសុំគិតថា អាចបណ្ដាលឱ្យប៉ះពាល់ជាដុំកំភួន និងអំពីលទ្ធភាពរបស់រដ្ឋសមាជិកស្នើសុំក្នុងការអនុម័តនូវវិធានការណាមួយ ដើម្បីកាត់បន្ថយផលប៉ះពាល់នោះ។ រដ្ឋសមាជិកស្នើសុំត្រូវជូនដំណឹងដល់បណ្ដារដ្ឋសមាជិកទាំងអស់ផ្សេងទៀត អំពីការស្នើសុំរបស់ខ្លួនសម្រាប់ការពិគ្រោះយោបល់ដូចមានចែងក្នុងកថាខណ្ឌនេះ។

៣. វិធានការទាំងឡាយណាដែលចាត់ឡើងដោយអនុលោមនឹងកថាខណ្ឌ២ ត្រូវមានការឯកភាពគ្នាជារួមដោយបណ្ដារដ្ឋសមាជិកពិគ្រោះយោបល់។

៤. បណ្ដារដ្ឋសមាជិកពិគ្រោះយោបល់ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិគ្រោះយោបល់ ដល់បណ្ដារដ្ឋសមាជិកទាំងអស់ផ្សេងទៀតឱ្យបានឆាប់តាមដែលអាចអនុវត្តបាន និងមិនត្រូវយឺតជាងកិច្ចប្រជុំបន្ទាប់របស់រដ្ឋមន្ត្រីAEM បន្ទាប់ពីការបញ្ចប់នៃការពិគ្រោះយោបល់នោះឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផលិតដោយ ឯកសារផ្លូវការ | https://t.me/oa_channel

## ផ្នែកទី៤
## ភាពថ្លាភិច្ច និងវិន័យរបស់បទប្បញ្ញត្តិ

### មាត្រា១៤
### តម្លាភាព

១. បណ្ដារដ្ឋសមាជិកទទួលស្គាល់ថា វិធានការគ្រប់គ្រងពាណិជ្ជកម្មប្រកបដោយតម្លាភាពមានសារៈសំខាន់ក្នុងការសម្របសម្រួលដល់លទ្ធភាពរបស់អ្នកផ្គត់ផ្គង់សេវាកម្ម ដើម្បីទទួលបាននូវមធ្យោបាយចូលទៅកាន់និងធ្វើប្រតិបត្តិការនៅក្នុងទីផ្សាររវាងគ្នានិងគ្នា។ រដ្ឋសមាជិកនីមួយៗត្រូវជំរុញតម្លាភាពបទប្បញ្ញត្តិនៅក្នុងពាណិជ្ជកម្មសេវាកម្ម។

*ការបោះពុម្ពផ្សាយ*

២. លើកលែងតែស្ថិតក្នុងស្ថានភាពអាសន្ន និងយ៉ាងយូរបំផុតត្រឹមពេលនៃការចូលជាធរមានរបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវបោះពុម្ពផ្សាយនូវៈ

(ក) រាល់វិធានការពាក់ព័ន្ធនៃការអនុវត្តទូទៅ ដែលជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ការប្រតិបត្តិរបស់កិច្ចព្រមព្រៀងនេះ និង

(ខ) រាល់កិច្ចព្រមព្រៀងអន្តរជាតិ ដែលជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលរដ្ឋសមាជិកគឺជាភាគី។

៣. តាមលទ្ធភាពដែលអាចធ្វើទៅបាន រដ្ឋសមាជិកនីមួយៗត្រូវធ្វើយ៉ាងណាឱ្យវិធានការ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដូចមានចែងក្នុងកថាខណ្ឌ២ អាចរកបានតាមអ៊ីនធឺណែត ហើយតាមលទ្ធភាពដែលអនុញ្ញាតក្រោមក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន ផ្សាយជាភាសាអង់គ្លេស។

៤. ករណីដែលការបោះពុម្ពផ្សាយដូចមានចែងក្នុងកថាខណ្ឌ២និង៣ ពុំអាចអនុវត្តបាន ដូច្នេះព័ត៌មានបែបនោះ[7] ត្រូវធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ។

៥. តាមលទ្ធភាពដែលអាចធ្វើទៅបាននិងតម្រូវតាមក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវផ្ដល់នូវឱកាសសមស្រប សម្រាប់ការបញ្ចេញមតិយោបល់ដោយបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍របស់បណ្ដារដ្ឋសមាជិក លើបទប្បញ្ញត្តិនៃការអនុវត្តទូទៅទាំងឡាយណា ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលខ្លួនស្នើសុំដើម្បីអនុម័ត ធ្វើវិសោធនកម្ម ឬធ្វើនិរាករណ៍ នៅមុនពេលនៃការអនុម័តនិងការបោះពុម្ពផ្សាយរបស់ខ្លួន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

[7] ដើម្បីឱ្យកាន់តែច្បាស់ បណ្ដារដ្ឋសមាជិកឯកភាពថា ព័ត៌មានបែបនោះអាចបោះពុម្ពផ្សាយជាភាសាតាមជម្រើសរបស់រដ្ឋសមាជិកនីមួយៗ។

៦. តាមលទ្ធភាពដែលអាចធ្វើទៅបាន រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យមានពេលវេលាសមស្រប រវាងការបោះពុម្ពផ្សាយនូវបទប្បញ្ញត្តិចុងក្រោយនានា ដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ និងកាលបរិច្ឆេទដែលបទប្បញ្ញត្តិទាំងនោះចាប់ផ្តើមមានប្រសិទ្ធភាព។

*ការិយាល័យទំនាក់ទំនង*

៧. រដ្ឋសមាជិកនីមួយៗ ត្រូវចាត់តាំងការិយាល័យទំនាក់ទំនងមួយ ដើម្បីសម្របសម្រួលដល់ការប្រាស្រ័យទាក់ទងរវាងបណ្តារដ្ឋសមាជិក អំពីបញ្ហាទាំងឡាយណាដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ។ តាមការស្នើសុំពីរដ្ឋសមាជិកផ្សេងទៀត ការិយាល័យទំនាក់ទំនងត្រូវៈ

(ក) កំណត់នូវការិយាល័យ ឬមន្ត្រីដែលទទួលខុសត្រូវចំពោះបញ្ហាពាក់ព័ន្ធ និង

(ខ) ជួយទៅតាមការចាំបាច់ ក្នុងការសម្របសម្រួលដល់ការប្រាស្រ័យទាក់ទងជាមួយនឹងរដ្ឋសមាជិកស្នើសុំ ពាក់ព័ន្ធនឹងបញ្ហានោះ។

៨. រដ្ឋសមាជិកនីមួយៗ ត្រូវឆ្លើយតបភ្លាមៗចំពោះសំណើទាំងឡាយរបស់រដ្ឋសមាជិកផ្សេងទៀតសម្រាប់ព័ត៌មានជាក់លាក់ស្តីពីៈ

(ក) វិធានការណាមួយដូចមានចែងក្នុងវាក្យខណ្ឌ២(ក) ឬកិច្ចព្រមព្រៀងអន្តរជាតិនានាដូចមានចែងក្នុងវាក្យខណ្ឌទី២(ខ) និង

(ខ) ការបង្កើតថ្មីឬការផ្លាស់ប្តូរណាមួយចំពោះច្បាប់ បទប្បញ្ញត្តិ ឬគោលការណ៍ណែនាំរដ្ឋបាលដែលមានស្រាប់ ដែលជះឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់ពាណិជ្ជកម្មសេវាកម្ម ដែលគ្របដណ្តប់ដោយការសន្យារបស់រដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងនេះ។

៩. តាមលទ្ធភាពដែលអាចធ្វើបាន និងតម្រូវតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវឆ្លើយតបនឹងសំណួរទាំងឡាយរបស់បុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍នៃបណ្តារដ្ឋសមាជិក អំពីវិធានការពាក់ព័ន្ធរបស់រដ្ឋសមាជិកនោះ ដែលទាក់ទងនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៥
## ការលាតត្រដាងព័ត៌មានសម្ងាត់

១. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយផ្តល់ដល់រដ្ឋសមាជិកផ្សេងទៀតនូវព័ត៌មានសម្ងាត់ ដែលការលាតត្រដាងនូវព័ត៌មានបែបនោះ អាចនឹងបន្ទចបង្អាក់ដល់ការអនុវត្តច្បាប់ ឬមួយវិញទៀតមានលក្ខណៈផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬដែលអាចបុរេវិនិច្ឆ័យចំពោះផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់នីតិបុគ្គលជាក់លាក់សាធារណៈ ឬឯកជន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការ | https://t.me/oa_channel

២. ករណីដែលរដ្ឋសមាជិកមួយផ្ដល់នូវព័ត៌មានដល់រដ្ឋសមាជិកផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ហើយចាត់ទុកព័ត៌មាននោះថាជាការសម្ងាត់ ដូច្នេះរដ្ឋសមាជិកផ្សេងទៀតនោះត្រូវរក្សានូវភាពសម្ងាត់នៃព័ត៌មានទាំងនោះ។ ព័ត៌មានបែបនោះ ត្រូវយកទៅប្រើប្រាស់សម្រាប់តែគោលបំណងដូចដែលបានបញ្ជាក់ប៉ុណ្ណោះ ហើយពុំត្រូវយកទៅលាតត្រដាងដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាក់លាក់ ពីរដ្ឋសមាជិកដែលផ្ដល់ព័ត៌មាននោះឡើយ។

## មាត្រា១៦

## បទប្បញ្ញត្តិក្នុងស្រុក

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា រាល់វិធានការនៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលម្អៀង។

២. (ក) រដ្ឋសមាជិកនីមួយៗត្រូវរក្សាឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវ អង្គជំនុំជម្រះ ឬនីតិវិធីបែបតុលាការ មជ្ឈត្តកម្ម ឬរដ្ឋបាល តបតាមសំណើររបស់អ្នកផ្គត់ផ្គង់សេវាកម្មរងការប៉ះពាល់ ដើម្បីអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញភ្លាមៗ និងករណីសមហេតុផលមានដំណោះស្រាយសមរម្យ ចំពោះសេចក្ដីសម្រេចរដ្ឋបាលនានាដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។ ករណីដែលនីតិវិធីទាំងនោះពុំមានឯករាជ្យភាពពីភ្នាក់ងារដែលទទួលបន្ទុកពិនិត្យលើសេចក្ដីសម្រេចរដ្ឋបាលពាក់ព័ន្ធទាំងនោះ រដ្ឋសមាជិកនោះត្រូវធានាថា នីតិវិធីទាំងនោះធ្វើឡើងសម្រាប់ការពិនិត្យឡើងវិញប្រកបដោយសត្យានុម័ត និងមិនលម្អៀងយ៉ាងពិតប្រាកដ។

(ខ) ប្រការទាំងឡាយនៃវាក្យខណ្ឌ(ក) ពុំត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយបង្កើតនូវអង្គជំនុំជម្រះឬនីតិវិធីទាំងឡាយណា ដែលផ្ទុយទៅនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬចរិតលក្ខណៈនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ។

៣. ករណីដែលច្បាប់ឬបទប្បញ្ញត្តិក្នុងស្រុកតម្រូវឱ្យមាននូវ សេចក្ដីអនុញ្ញាតសម្រាប់ការផ្គត់ផ្គង់សេវាកម្ម នោះអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋសមាជិកត្រូវ៖

(ក) ក្នុងករណីពាក្យស្នើសុំពុំមានភាពពេញលេញ តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំបង្ហាញនូវរាល់ព័ត៌មានបន្ថែមទាំងឡាយដែលតម្រូវឱ្យមានដើម្បីបំពេញពាក្យស្នើសុំឱ្យបានពេញលេញ និងផ្ដល់នូវឱកាសដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនោះ ក្នុងអំឡុងពេលសមស្របមួយ

(ខ) តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំ ដោយពុំមានការពន្យារពេលមិនសមហេតុផល ផ្ដល់នូវព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនៃពាក្យស្នើសុំ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

(គ) ស្ថិតក្នុងរយៈពេលសមស្របបន្ទាប់ពីការដាក់ពាក្យស្នើសុំ ដែលចាត់ទុកថាមានភាពពេញលេញក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីការសម្រេចពាក់ព័ន្ធនឹងពាក្យស្នើសុំនោះ និង

(ឃ) ប្រសិនបើពាក្យស្នើសុំត្រូវបានបញ្ឈប់ឬបដិសេធ តាមលទ្ធភាពអតិបរិមាដែលអាចធ្វើទៅបាន ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីមូលហេតុនៃការសម្រេចបែបនោះជាលាយលក្ខណ៍អក្សរនិងគ្មានការពន្យារពេល។ អ្នកដាក់ពាក្យស្នើសុំនឹងមានលទ្ធភាពក្នុងការដាក់ឡើងវិញនូវពាក្យស្នើសុំថ្មី តាមឆន្ទានុសិទ្ធិរបស់ខ្លួន។

៤. ករណីដែលរដ្ឋសមាជិកមួយអនុម័តឬរក្សាទុកនូវវិធានការទាំងឡាយណាពាក់ព័ន្ធនឹង តម្រូវការនិងនីតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណ តម្រូវការនិងនីតិវិធីចំពោះគុណវុឌ្ឍិ ឬករណីដែលរដ្ឋសមាជិកមួយអនុម័តឬរក្សាទុកនូវវិធានការទាំងឡាយណាពាក់ព័ន្ធនឹង ស្តង់ដាបច្ចេកទេស ក្នុងន័យជាលក្ខខណ្ឌសម្រាប់ការផ្គត់ផ្គង់សេវាកម្ម នោះរដ្ឋសមាជិកត្រូវធានាថា៖

(ក) វិធានការបែបនោះ ផ្អែកលើលក្ខណៈវិនិច្ឆ័យប្រកបដោយសត្យានុម័តនិងតម្លាភាព

(ខ) នីតិវិធីទាំងនោះមិនលម្អៀង ហើយនីតិវិធីទាំងនោះមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ឱ្យអ្នកដាក់ពាក្យស្នើសុំអាចបញ្ជាក់បាន ថាតើពួកគេបានបំពេញតាមតម្រូវការដែរឬយ៉ាងណា ករណីដែលមានតម្រូវការដូចខាងលើនេះ

(គ) នីតិវិធីទាំងនោះមានភាពសមស្រប ហើយនីតិវិធីទាំងនោះផ្ទាល់ពុំបង្កជាឧបសគ្គដល់ការបំពេញតាមតម្រូវការនានាដោយមិនសមហេតុផលឡើយ

៥. (ក) រដ្ឋសមាជិកមិនត្រូវអនុវត្តនូវតម្រូវការសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ និងតម្រូវការគុណវុឌ្ឍិព្រមទាំងស្តង់ដាបច្ចេកទេសណាមួយ ដែលបណ្តាលឱ្យមោឃៈឬបន្ថយនូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ក្នុងលក្ខណៈមួយដែល៖

(i) មិនអនុលោមតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងវាក្យខណ្ឌ ៤(ក) (ខ) ឬ (គ) និង

(ii) ពុំអាចធ្វើការរំពឹងទុកអំពីរដ្ឋសមាជិកនោះបានដោយសមហេតុផល នៅក្នុងពេលដែលការសន្យាចំពោះវិស័យទាំងនោះត្រូវបានធ្វើឡើង។

(ខ) ក្នុងការកំណត់ថា តើរដ្ឋសមាជិកមួយមានអនុលោមភាពទៅនឹងកាតព្វកិច្ចនៅក្រោមវាក្យខណ្ឌ៥(ក) នោះការពិចារណាត្រូវពិនិត្យលើស្តង់ដាអន្តរជាតិរបស់អង្គការអន្តរជាតិពាក់ព័ន្ធនានា ដែលអនុវត្តដោយរដ្ឋសមាជិកនោះ។

៦. ពាក់ព័ន្ធនឹងសេវាកម្មវិជ្ជាជីវៈ[៨] រដ្ឋសមាជិកនីមួយៗត្រូវផ្តល់នូវនីតិវិធីគ្រប់គ្រាន់ ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពអ្នកជំនាញវិជ្ជាជីវៈរបស់រដ្ឋសមាជិកផ្សេងទៀត។

[៨] ដូចដែលបានធ្វើចំណាត់ថ្នាក់នៅក្រោមវិស័យសេវាកម្មធុរកិច្ច យោងតាមឯកសារ MTN.GNS/W/120 របស់អង្គការពាណិជ្ជកម្មពិភពលោក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

៧. ទៅតាមលទ្ធភាពដែលអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក រដ្ឋសមាជិកនីមួយៗត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនទទួលយកនូវឯកសារថតចម្លងដែលបានធ្វើនីត្យានុកូលកម្មស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ជំនួសឱ្យឯកសារច្បាប់ដើម។

៨. ប្រសិនបើតម្រូវការសម្រាប់ការផ្តល់អាជ្ញាប័ណ្ណឬតម្រូវការគុណវុឌ្ឍិ រួមបញ្ចូលទាំងការបញ្ចប់ពេញលេញនៃការពិនិត្យពិច័យ នោះរដ្ឋសមាជិកនីមួយៗត្រូវ តាមលទ្ធភាពដែលអាចធ្វើទៅបាន ធានាថា៖

(ក) ការពិនិត្យពិច័យត្រូវបានរៀបចំកាលវិភាគនៅចន្លោះពេលញឹកញាប់ដែលសមស្រប

(ខ) រយៈពេលសមស្របមួយគឺត្រូវបានផ្តល់ជូន ដើម្បីអនុញ្ញាតឱ្យបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ដាក់ពាក្យស្នើសុំ។

៩. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន បណ្តារដ្ឋសមាជិកត្រូវខិតខំទទួលយកពាក្យស្នើសុំក្នុងទម្រង់អេឡិចត្រូនិក ដែលស្ថិតក្រោមលក្ខខណ្ឌសមមូលនៃនីត្យានុកូលភាពដូចទៅនឹងការដាក់ស្នើជាក្រដាសស្នាមដែរ។

១០. រដ្ឋសមាជិកនីមួយៗត្រូវធានាថា កម្រៃសេវាសម្រាប់ការផ្តល់ការអនុញ្ញាត[១] ដែលយកដោយអាជ្ញាធរមានសមត្ថកិច្ចគឺសមស្របនិងមានតម្លាភាព ហើយការយកកម្រៃបែបនោះផ្ទាល់ពុំបង្កជាការរឹតត្បិតដល់ការផ្គត់ផ្គង់សេវាកម្មពាក់ព័ន្ធឡើយ។

១១. ប្រសិនបើលទ្ធផលនៃការចចារពាក់ព័ន្ធកថាខណ្ឌ៤ នៃមាត្រាVI នៃកិច្ចព្រមព្រៀងGATS ចូលជាធរមាន មាត្រានេះត្រូវធ្វើវិសោធនកម្មតាមការសមស្រប បន្ទាប់ពីមានការពិគ្រោះយោបល់រវាងបណ្តារដ្ឋសមាជិក ដើម្បីធ្វើឱ្យលទ្ធផលទាំងនោះអាចអនុវត្តជាធរមាននៅក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា១៧
## ការទទួលស្គាល់

១. សម្រាប់គោលបំណងនៃការផ្តល់អាជ្ញាប័ណ្ណ ឬការផ្តល់វិញ្ញាបនបត្រ ដល់អ្នកផ្គត់ផ្គង់សេវាកម្ម រដ្ឋសមាជិកមួយអាចទទួលស្គាល់នូវ ការអប់រំឬបទពិសោធន៍ដែលទទួលបាន លក្ខខណ្ឌតម្រូវដែលបំពេញតាម ឬអាជ្ញាប័ណ្ណឬវិញ្ញាបនបត្រដែលត្រូវបានផ្តល់ជូនក្នុងរដ្ឋសមាជិកផ្សេងទៀត។ ការទទួលស្គាល់បែបនេះ ដែលអាចសម្រេចបានតាមរយៈការធ្វើសុខដុមនីយកម្មឬក្រៅពីនេះ អាចនឹងអាស្រ័យទៅលើកិច្ចព្រមព្រៀង ឬកិច្ចរៀបចំណាមួយជាមួយនឹងរដ្ឋសមាជិកពាក់ព័ន្ធ ឬក៏អាចនឹងត្រូវបានផ្តល់ជូនដោយស្វ័យភាព។

[១] កម្រៃសេវាសម្រាប់ការផ្តល់ការអនុញ្ញាតរួមមាន កម្រៃសេវានៃការផ្តល់អាជ្ញាប័ណ្ណ និងកម្រៃសេវាពាក់ព័ន្ធនានាទៅនឹងនីតិវិធីគុណវុឌ្ឍិ ប៉ុន្តែកម្រៃទាំងនោះពុំរួមបញ្ចូលនូវកម្រៃសាចំពោះការប្រើប្រាស់ធនធានធម្មជាតិ ការទូទាត់លើការដេញថ្លៃជាសាធារណៈ ការដាក់សំណើ ឬការបង់ប្រាក់ដោយមិនរើសអើងនានាចំពោះការផ្តល់សម្បទាន ឬវិភាគទានកាតព្វកិច្ចនានាចំពោះការផ្តល់សេវាកម្មជាសកលឡើយ។

២. ពុំមានអ្វីនៅក្នុងមាត្រានេះត្រូវបានបកស្រាយ ដើម្បីរាំងរដ្ឋសមាជិកមួយពីការផ្តល់នូវការទទួលស្គាល់ដោយស្វ័យភាពឡើយ។ ករណីដែលរដ្ឋសមាជិកមួយយល់ព្រមផ្តល់នូវការទទួលស្គាល់ដោយស្វ័យភាពដល់រដ្ឋសមាជិកផ្សេងទៀត រដ្ឋសមាជិកនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់រដ្ឋសមាជិកផ្សេងៗទៀត ដើម្បីបំភ្លឺថា ការអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រដែលទទួលបាន ឬលក្ខខណ្ឌតម្រូវដែលបំពេញតាម នៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងៗទៀតនោះ គប្បីត្រូវបានទទួលស្គាល់ផងដែរ។

៣. ក្នុងគោលបំណងជួយសម្រួលបន្ថែមទៀតដល់បន្លាស់ទីនៃអ្នកជំនាញវិជ្ជាជីវៈនិងពលកម្មជំនាញ បណ្តារដ្ឋសមាជិកត្រូវលើកទឹកចិត្តឱ្យអាជ្ញាធរមានសមត្ថកិច្ច ធ្វើការចរចាកិច្ចព្រមព្រៀង ឬកិច្ចរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកនានា នៅក្នុងវិស័យដែលពួកគេចាត់ទុកថាសមស្រប។

៤. រដ្ឋសមាជិកមួយមិនត្រូវយល់ព្រមផ្តល់នូវការទទួលស្គាល់ ក្នុងលក្ខណៈមួយដែលអាចបង្កឱ្យមានការរើសអើងរវាងបណ្តារដ្ឋសមាជិក ពាក់ព័ន្ធនឹងការអនុវត្តស្តង់ដា ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួន ក្នុងការផ្តល់ការអនុញ្ញាត ការផ្តល់អាជ្ញាប័ណ្ណ ឬការចេញវិញ្ញាបនបត្រដល់អ្នកផ្គត់ផ្គង់សេវាកម្ម ឬការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្មឡើយ។

## មាត្រា១៨
## ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដូចដែលបានប្រមើលទុកមុនក្នុងមាត្រា១៩ (ការរឹតត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់) រដ្ឋសមាជិកមួយមិនត្រូវដាក់ការរឹតត្បិតចំពោះការផ្ទេរ និងការទូទាត់ជាអន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយ ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្ម ដែលខ្លួនបានសន្យាក្រោមកិច្ចព្រមព្រៀងនេះឡើយ។

២. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវជះឥទ្ធិពលដល់សិទ្ធិនិងកាតព្វកិច្ចរបស់បណ្តារដ្ឋសមាជិក ក្នុងនាមជាសមាជិកនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលនៅក្រោមមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិឡើយ រួមទាំងការប្រើប្រាស់សកម្មភាពដោះដូរទាំងឡាយ ដែលអនុលោមទៅនឹងមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងន័យនេះ រដ្ឋសមាជិកមួយមិនត្រូវដាក់ការរឹតត្បិតលើប្រតិបត្តិការមូលធននានាឡើយ លើកលែងតែមានចែងក្នុងមាត្រា១៩ (ការរឹតត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់) ឬផ្អែកតាមសំណើរបស់ IMF។

## មាត្រា១៩
## ការរឹតត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់

១. ស្ថិតក្នុងស្ថានការណ៍ដែលជួបនឹងការលំបាកធ្ងន់ធ្ងរលើតុល្យភាពជញ្ជីងទូទាត់ និងជួបការលំបាកផ្នែកហិរញ្ញវត្ថុពីខាងក្រៅ ឬការគំរាមកំហែងផ្សេងៗពីស្ថានការណ៍បែបនោះ ឬប្រសិនបើមានកាលៈទេសៈពិសេសដោយឡែក មូលហេតុបន្លាស់ទីនៃមូលធន ឬការគំរាមកំហែងបង្កឱ្យ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



គេហទំព័រ ឯកសារផ្លូវការ: | https://t.me/oa_channel

មានផលវិបាកដល់សេដ្ឋកិច្ចឬហិរញ្ញវត្ថុធ្ងន់ធ្ងរនៅក្នុងរដ្ឋសមាជិកមួយ រដ្ឋសមាជិកនោះអាចអនុម័តឬរក្សាទុកនូវការរឹតត្បិតលើពាណិជ្ជកម្មសេវាកម្ម រួមទាំងលើការទូទាត់និងការផ្ទេរ។ វាត្រូវបានទទួលស្គាល់ថា សម្ពាធជាក់លាក់ចំពោះតុល្យភាពជញ្ជីងទូទាត់របស់រដ្ឋសមាជិកមួយនៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច ឬការផ្លាស់ប្តូរសេដ្ឋកិច្ចអាចបណ្តាលឱ្យមានភាពចាំបាច់ក្នុងការប្រើប្រាស់ការរឹតត្បិតនានា ដើម្បីធានាដល់ការថែរក្សាបាននូវកម្រិតនៃការបម្រុងហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ការអនុវត្តកម្មវិធីរបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ឬការផ្លាស់ប្តូរសេដ្ឋកិច្ច។

២. ការរឹតត្បិតដូចមានចែងក្នុងកថាខណ្ឌ១៖

(ក) មិនត្រូវរើសអើងក្នុងចំណោមបណ្តារដ្ឋសមាជិកឡើយ

(ខ) ត្រូវមានសង្គតិភាពទៅនឹងមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ

(គ) ត្រូវចៀសវាងនូវការខូចខាតមិនចាំបាច់ដល់ផលប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀត

(ឃ) មិនត្រូវលើសពីអ្វីដែលជាភាពចាំបាច់ សម្រាប់ការដោះស្រាយចំពោះកាលៈទេសៈដូចដែលបានពណ៌នាក្នុងកថាខណ្ឌ១ និង

(ង) ត្រូវធ្វើឡើងជាបណ្តោះអាសន្ន និងត្រូវលុបចោលជាបន្តបន្ទាប់ នៅពេលដែលស្ថានភាពដូចមានបញ្ជាក់ក្នុងកថាខណ្ឌ១ មានភាពប្រសើរឡើងវិញ។

៣. ក្នុងការកំណត់នូវស្ថានភាពដែលបណ្តាលឱ្យកើតមាននូវការរឹតត្បិតបែបនេះ បណ្តារដ្ឋសមាជិកត្រូវផ្តល់អាទិភាពដល់ការផ្គត់ផ្គង់សេវាកម្មទាំងឡាយណា ដែលមានសារៈសំខាន់ជាងគេចំពោះកម្មវិធីសេដ្ឋកិច្ចឬការអភិវឌ្ឍរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី ការរឹតត្បិតបែបនេះពុំត្រូវអនុម័តឬរក្សាទុកក្នុងគោលបំណងការពារវិស័យសេវាកម្មជាក់លាក់ណាមួយឡើយ។

## មាត្រា២០
## ភាពផ្តាច់មុខនិងអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខនៅក្នុងដែនដីរបស់ខ្លួន សម្រាប់ការផ្គត់ផ្គង់សេវាកម្មផ្តាច់មុខនោះនៅក្នុងទីផ្សារពាក់ព័ន្ធ ពុំប្រព្រឹត្តនូវសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះនៅក្រោម មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) និងមាត្រា១១ (វិធានការបដិលោម)។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២. ករណីដែលអ្នកផ្គត់ផ្គង់ផ្តាច់មុខរបស់រដ្ឋសមាជិកមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្នុងការផ្គត់ផ្គង់សេវាកម្មដែលស្ថិតនៅក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន ហើយដែលសេវាកម្មនោះជាកម្មវត្ថុទៅនឹងការសន្យារបស់រដ្ឋសមាជិកនោះក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនោះត្រូវធានាថា អ្នកផ្គត់ផ្គង់បែបនេះមិនបំពាននូវតួនាទីផ្តាច់មុខរបស់ខ្លួន ដោយប្រព្រឹត្តនូវសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងការសន្យាទាំងនោះ ក្នុងដែនដីរបស់ខ្លួនឡើយ។

៣. តបតាមសំណើរបស់រដ្ឋសមាជិកមួយដែលមានមូលហេតុក្នុងការជឿជាក់ថា អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខនៃរដ្ឋសមាជិកផ្សេងទៀត កំពុងប្រព្រឹត្តសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងកថាខណ្ឌ១ឬ២ នោះរដ្ឋមន្ត្រីAEM អាចស្នើរដ្ឋសមាជិកដែលបង្កើត រក្សាទុក ឬផ្តល់ការអនុញ្ញាតដល់អ្នកផ្គត់ផ្គង់បែបនោះ ផ្តល់នូវព័ត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធនានា។

៤. ប្រសិនបើ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកមួយផ្តល់សិទ្ធិផ្តាច់មុខពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មណាមួយ ដែលគ្របដណ្តប់ដោយការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនោះត្រូវជូនដំណឹងដល់រដ្ឋមន្ត្រី AEM មិនឱ្យតិចជាងបីខែ មុនពេលវេលាដែលប៉ុនប៉ងចាប់ផ្តើមអនុវត្តការផ្តល់សិទ្ធិផ្តាច់មុខនោះ ហើយមាត្រា៣៣ (វិសោធនកម្ម) ត្រូវអនុវត្ត។

៥. ប្រការទាំងឡាយនៃមាត្រានេះត្រូវអនុវត្តផងដែរ ចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខទាំងឡាយ ដែលរដ្ឋសមាជិកមួយជាផ្លូវការឬជាធរមាន (ក) អនុញ្ញាតឬបង្កើតឱ្យមានអ្នកផ្គត់ផ្គង់សេវាកម្មមួយក្រុមតូច និង (ខ) រារាំងគួរឱ្យកត់សម្គាល់ចំពោះការប្រកួតប្រជែង ក្នុងចំណោមអ្នកផ្គត់ផ្គង់សេវាកម្មទាំងនោះ ក្នុងដែនដីរបស់ខ្លួន។

## មាត្រា២១
## ការអនុវត្តធុរកិច្ច

១. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា ការអនុវត្តធុរកិច្ចជាក់លាក់មួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវាកម្មក្រៅពីការអនុវត្តទាំងឡាយដូចមានចែងក្នុងមាត្រា២០ (ភាពផ្តាច់មុខនិងអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ) អាចបន្ទុចបង្អាក់ដល់ការប្រកួតប្រជែង និងដោយហេតុនេះ បង្កជាការរឹតត្បិតដល់ពាណិជ្ជកម្មសេវាកម្ម។

២. តបតាមសំណើរបស់រដ្ឋសមាជិកផ្សេងទៀត រដ្ឋសមាជិកនីមួយៗត្រូវចូលរួមក្នុងការពិគ្រោះយោបល់ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តនានា ដូចមានចែងក្នុងកថាខណ្ឌ១។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំនោះត្រូវពិចារណាឱ្យបានពេញលេញនិងប្រកបដោយសមានចិត្តចំពោះសំណើនោះ និងត្រូវសហការតាមរយៈការផ្តល់ព័ត៌មានមិនសម្ងាត់ដែលអាចរកបានជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គេហទំព័រ សារព័ត៌មានជាតិ: | https://t.me/oa_channel

សាធារណៈដែលទាក់ទងនឹងបញ្ហាចោទសួរនោះ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំក៏ត្រូវផ្ដល់ផងដែរនូវព័ត៌មានដែលអាចរកបានដទៃទៀតដល់រដ្ឋសមាជិកស្នើសុំ ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន និងតាមសេចក្ដីសម្រេចនៃការព្រមព្រៀងគ្នាប្រកបដោយភាពពេញចិត្តពាក់ព័ន្ធនឹងការការពារចំពោះកិច្ចការសម្ងាត់របស់ខ្លួនដោយរដ្ឋសមាជិកស្នើសុំ។

## មាត្រា២២
## ការលើកលែងទូទៅ

ដោយអាស្រ័យតាមលក្ខខណ្ឌតម្រូវថា វិធានការទាំងនោះពុំត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលបង្កឱ្យមានការរើសអើងតាមអំពើចិត្ត ឬពុំសមហេតុផលរវាងប្រទេសទាំងឡាយ ករណីដែលស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ឬបង្កឱ្យមានការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្ម នោះពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីរាំងដល់ការអនុម័តឬការអនុវត្តដោយរដ្ឋសមាជិកណាមួយនូវវិធានការទាំងឡាយណាដែលៈ

(ក) ចាំបាច់ដើម្បីការពារក្រមសីលធម៌សាធារណៈ ឬ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[10]

(ខ) ចាំបាច់ដើម្បីការពារអាយុជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬ រុក្ខជាតិ

(គ) ចាំបាច់ដើម្បីធានានូវការគោរពតាមច្បាប់ឬបទប្បញ្ញត្តិនានា ដែលមិនផ្ទុយទៅនឹងប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងវិធានការពាក់ព័ន្ធនឹងៈ

(i) ការទប់ស្កាត់ចំពោះការអនុវត្តបែបឆបោកនិងក្លែងបន្លំ ឬដើម្បីទប់ទល់ចំពោះលទ្ធផលនៃការខកខានក្នុងការបំពេញតាមកិច្ចសន្យាសេវាកម្មនានា

(ii) ការការពារឯកជនភាពរបស់បុគ្គលពាក់ព័ន្ធនឹងការដំណើរការ និងការចែកចាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសម្ងាត់នៃកំណត់ត្រានិងគណនីបុគ្គល ឬ

(iii) សុវត្ថិភាព

(ឃ) មិនអនុលោមទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) ក្នុងករណីភាពខុសគ្នានៃប្រព្រឹត្តិកម្មនោះត្រូវបានធ្វើឡើងក្នុងគោលបំណងធានាឱ្យបាននូវការដាក់បន្ទុកឬការប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ឬប្រសិទ្ធភាព[11] ពាក់ព័ន្ធនឹងសេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មរបស់បណ្ដារដ្ឋសមាជិកផ្សេងទៀត ឬ

---

[10] ការលើកលែងដើម្បីសណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានយកមកប្រើចំពោះតែករណីដែលការគំរាមកំហែងពិតប្រាកដឬធ្ងន់ធ្ងរគ្រប់គ្រាន់ [illegible] ប៉ះពាល់ដល់ផលប្រយោជន៍ណាមួយនៅក្នុងចំណោមផលប្រយោជន៍ជាមូលដ្ឋាននានារបស់សង្គម។

[11] វិធានការ[illegible]ឡាយណាដែលមានគោលដៅធានានូវការដាក់បន្ទុកឬការប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ឬប្រសិទ្ធភាព រួមបញ្ចូលទាំងវិធានការទាំងឡាយណា ដែលចាត់ឡើងដោយរដ្ឋសមាជិកមួយក្រោមប្រព័ន្ធពន្ធរបស់ខ្លួន ដែលៈ

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

(ង) មិនអនុលោមនឹងមាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានគាពអនុគ្រោះបំផុត) ក្នុងករណីដែលភាពខុសគ្នានៃប្រព្រឹត្តិកម្ម គឺជាលទ្ធផលនៃកិច្ចព្រមព្រៀងណាមួយស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ឬប្រការនានាស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា នៅក្នុងកិច្ចព្រមព្រៀងឬកិច្ចរៀបចំអន្តរជាតិផ្សេងៗទៀត ដែលរដ្ឋសមាជិកនោះជាប់កាតព្វកិច្ច។

## មាត្រា ២៣
## ការលើកលែងផ្នែកសន្តិសុខ

១. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះដែលនឹងត្រូវបកស្រាយៈ

(ក) ដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយផ្តល់ព័ត៌មានណាមួយ ដែលការលាតត្រដាងព័ត៌មាននេះត្រូវបានចាត់ទុកថា ផ្ទុយនឹងផលប្រយោជន៍ចម្បងផ្នែកសន្តិសុខរបស់ខ្លួន ឬ

(ខ) ដើម្បីរារាំងរដ្ឋសមាជិកមួយពីការចាត់វិធានការណាមួយ ដែលខ្លួនគិតថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ចម្បងផ្នែកសន្តិសុខរបស់ខ្លួនៈ

(i) ទាក់ទងនឹងការផ្គត់ផ្គង់សេវាកម្ម ដែលប្រព្រឹត្តទៅដោយផ្ទាល់ឬដោយប្រយោលក្នុងគោលបំណងផ្តល់ការផ្គត់ផ្គង់សម្រាប់ការបង្កើតកម្លាំងយោធា

(ii) ទាក់ទងនឹងវត្ថុធាតុដែលអាចបំបែកបាននិងរំលាយបញ្ចូលគ្នាបាន ឬវត្ថុធាតុនានាដែលកើតចេញពីសារធាតុទាំងនេះ

---

(i) អនុវត្តចំពោះអ្នកផ្គត់ផ្គង់សេវាកម្មដែលជាអនិវេសនជន ដោយទទួលស្គាល់នូវភាពពិតជាក់ស្តែងថា កាតព្វកិច្ចពន្ធរបស់អនិវេសនជនគឺត្រូវបានកំណត់ស្របទៅតាមវត្ថុទាំងឡាយដែលអាចជាប់ពន្ធ ដែលមានប្រភពឬស្ថិតនៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ឬ

(ii) អនុវត្តចំពោះអនិវេសនជន ដើម្បីធានានូវការដាក់បន្ទុកឬការប្រមូលពន្ធនៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ឬ

(iii) អនុវត្តចំពោះអនិវេសនជនឬនិវេសនជនទាំងឡាយ ដើម្បីរាំងចំពោះការចៀសវាងឬការគេចវេសពីការបង់ពន្ធ រួមទាំងវិធានការប្រតិបត្តិតាម ឬ

(iv) អនុវត្តចំពោះអ្នកប្រើប្រាស់សេវាកម្មទាំងឡាយ ដែលសេវាកម្មនោះត្រូវបានផ្គត់ផ្គង់នៅក្នុងឬមកពីដែនដីរបស់រដ្ឋសមាជិកផ្សេងទៀត ដើម្បីធានានូវការដាក់បន្ទុកឬការប្រមូលពន្ធ ដែលបានមកពីប្រភពនានានៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ពីអ្នកប្រើប្រាស់សេវាកម្មបែបនោះ ឬ

(v) កំណត់អំពីភាពខុសគ្នារវាង អ្នកផ្គត់ផ្គង់សេវាកម្មទាំងឡាយដែលរងការជាប់ពន្ធចំពោះកម្មវត្ថុនានាដែលអាចជាប់ពន្ធទូទាំងពិភពលោក ចេញពីអ្នកផ្គត់ផ្គង់សេវាកម្មផ្សេងទៀត ដោយទទួលស្គាល់នូវភាពខុសគ្នារបស់ចរិតលក្ខណៈនៃមូលដ្ឋានពន្ធរវាងពួកគេ ឬ

(vi) កំណត់អំពី ចំណូលដែលត្រូវបម្រុងទុកឬត្រូវបែងចែក ផលចំណេញ កំណើន ការខាតបង់ ការថយចុះ ឬឥណទាន របស់បុគ្គលឬសាខាដែលតាំងនៅជាអចិន្ត្រៃយ៍ ឬរវាងបុគ្គលឬសាខាពាក់ព័ន្ធនឹងបុគ្គលដដែលនេះ ដើម្បីការពារនូវមូលដ្ឋានពន្ធរបស់រដ្ឋសមាជិកនោះ។

សន្ធិសញ្ញា...កំណត់ឬទស្សនាទានពន្ធនានា ដូចមានចែងនៅក្នុងកថាខណ្ឌ(ឃ) នៃមាត្រា២២ (ការលើកលែងទូទៅ) និងនៅក្នុងកំណត់សម្គាល់ជើងទំព័រនេះ ត្រូវបានកំណត់ដោយអាស្រ័យទៅតាមនិយមន័យនិងទស្សនាទានពន្ធ ឬនិយមន័យនិងទស្សនាទានដែលមានអត្ថន័យស្មើឬប្រហាក់ប្រហែល ដោយស្ថិតក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋសមាជិកដែលអនុវត្តវិធានការនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

(iii) ទាក់ទងនឹងវិធានការនានាចាត់ឡើង ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ រួមមាន ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ថាមពល និងធារាសាស្ត្រ ពីការប៉ុនប៉ងដោយចេតនាដើម្បីបង្អាក់ដំណើរការ ឬធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(iv) ដែលត្រូវបានធ្វើឡើងក្នុងពេលសង្គ្រាម ឬនៅក្នុងភាពអាសន្នផ្សេងទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ

(គ) ដើម្បីរារាំងរដ្ឋសមាជិកណាមួយពីការចាត់វិធានការទាំងឡាយណា ដែលស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ សម្រាប់ការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

២. ព័ត៌មានយ៉ាងពេញលេញជាទីបំផុតតាមដែលអាចធ្វើបាន អំពីវិធានការទាំងឡាយណាដែលត្រូវបានអនុវត្តក្រោមកថាខណ្ឌ១(ខ)និង(គ) និងអំពីការបញ្ចប់នៃវិធានការទាំងនោះ ត្រូវផ្តល់ជាព័ត៌មានជូនដល់រដ្ឋមន្ត្រីAEM ។

## មាត្រា ២៤
## ឧបត្ថម្ភធន

១. ថ្វីបើមានចែងក្នុងមាត្រា២ (វិសាលភាព) បណ្តារដ្ឋសមាជិកត្រូវពិនិត្យឡើងវិញលើបញ្ហាវិន័យនានាស្តីពីឧបត្ថម្ភធនពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម ដោយពិចារណាលើវិន័យទាំងឡាយដែលបានព្រមព្រៀងនៅក្រោមមាត្រាXV នៃកិច្ចព្រមព្រៀងGATS ក្នុងគោលបំណងរួមបញ្ចូលវិន័យទាំងនោះទៅក្នុងកិច្ចព្រមព្រៀងនេះ។

២. រដ្ឋសមាជិកមួយដែលយល់ថាខ្លួនរងនូវឥទ្ធិពលអវិជ្ជមាន ដោយសារឧបត្ថមធនពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត អាចស្នើសុំការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកនោះអំពីបញ្ហាទាំងនោះ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំ ត្រូវផ្តល់នូវការពិចារណាប្រកបដោយសមានចិត្តចំពោះសំណើ។

៣. ប្រការទាំងឡាយនៃមាត្រា៣៤ (ការដោះស្រាយវិវាទ) មិនត្រូវអនុវត្តចំពោះសំណើណាមួយដែលបានលើកឡើង ឬការពិគ្រោះយោបល់នានាដែលបានប្រព្រឹត្តទៅក្រោមប្រការទាំងឡាយនៃមាត្រានេះឡើយ ឬមិនត្រូវអនុវត្តចំពោះវិវាទទាំងឡាយដែលកើតឡើងរវាងបណ្តារដ្ឋសមាជិកដែលបណ្តាលមកពីឬនៅក្រោមប្រការទាំងឡាយនៃមាត្រានេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥
# កិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

## មាត្រា ២៥
## ការបង្កើននូវការចូលរួមរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម នៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ាន

១. បណ្តារដ្ឋសមាជិកត្រូវលើកកម្ពស់សមត្ថភាពសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដើម្បីចូលរួមនិងទទួលបានអត្ថប្រយោជន៍ពីកាលានុវត្តភាពនានា ដែលបានផ្តល់ជូនដោយកិច្ចព្រមព្រៀងនេះ។

២. បណ្តារដ្ឋសមាជិកត្រូវខិតខំព្យាយាមធ្វើសហប្រតិបត្តិការនៅក្នុងវិស័យដូចខាងក្រោម៖

(ក) ការអភិវឌ្ឍនិងការជំរុញការកសាងសមត្ថភាព ដែលរួមបញ្ចូល តែមិនកំណត់ចំពោះការហ្វឹកហ្វឺន ការផ្តល់មគ្គុទេសក៍ ការបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីផ្តល់ព័ត៌មានដល់ MSMEs អំពីអត្ថប្រយោជន៍នានាដែលអាចទទួលបានដោយ MSMEs ក្រោមកិច្ចព្រមព្រៀងនេះ

(ខ) ការសម្របសម្រួលនូវការអភិវឌ្ឍកម្មវិធីនានា ដើម្បីជួយដល់ MSMEs ក្នុងការចូលរួម និងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកល

(គ) ការកំណត់និងការលើកឡើងអំពីរបាំងនានា ដែលអាចជាឧបសគ្គដល់ MSMEs ក្នុងការចូលទៅកាន់ទីផ្សាររបស់រដ្ឋសមាជិកផ្សេងទៀត

(ឃ) ការកំណត់និងការឈានឆ្ពោះទៅរកដំណោះស្រាយសមស្រប ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីពង្រឹងសមត្ថភាព MSMEs ក្នុងការចូលរួមសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ

(ង) ការដោះដូរព័ត៌មានទៅវិញទៅមក ដើម្បីជួយដល់រដ្ឋសមាជិកក្នុងការគ្រប់គ្រងនិងការអនុវត្តកិច្ចព្រមព្រៀង ដែលពាក់ព័ន្ធជាមួយនឹង MSMEs និង

(ច) សកម្មភាពផ្សេងទៀតដែលនឹងត្រូវព្រមព្រៀងគ្នាទៅវិញទៅមក។

៣. ពុំមានរដ្ឋសមាជិកណាមួយ ត្រូវធ្វើឧបាស្រ័យទៅនឹងការដោះស្រាយវិវាទក្រោមមាត្រា៣៤ (ការដោះស្រាយវិវាទ) ចំពោះបញ្ហាទាំងឡាយណាដែលកើតឡើងក្រោមមាត្រានេះឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



តេលេក្រាម ឯកសារច្បាប់សាធារណៈ | https://t.me/oa_channel

## មាត្រា ២៦
## ជំនួយបច្ចេកទេស

បណ្ដារដ្ឋសមាជិកបញ្ជាក់អំពីសារៈសំខាន់នៃជំនួយបច្ចេកទេស និងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ក្នុងចំណោមបណ្ដារដ្ឋសមាជិក ដើម្បីសម្រួលដល់ការរៀបចំតារាងវិធានការបដិលោមដែលស្របតាមមាត្រា១១ (វិធានការបដិលោម) ដោយអាស្រ័យទៅតាមលទ្ធភាពនៃធនធាន។

## មាត្រា ២៧[12]
## ការបង្កើននូវការចូលរួមរបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម

១. ដោយបានពិចារណាលើកម្រិតខុសគ្នានៃការអភិវឌ្ឍរបស់បណ្ដារដ្ឋសមាជិក កិច្ចព្រមព្រៀងនេះនឹងរួមបញ្ចូលនូវទម្រង់នៃភាពទន់ភ្លន់ដែលសមស្រប រួមទាំងបទប្បញ្ញត្តិនានាសម្រាប់ប្រព្រឹត្តិកម្មពិសេសនិងដោយឡែកជូនដល់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម។

២. ក្នុងន័យនេះ ការបង្កើនការចូលរួមរបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម នៅក្នុងកិច្ចព្រមព្រៀងនេះត្រូវសម្រួលតាមរយៈ៖

(ក) ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុក ព្រមទាំងប្រសិទ្ធផលនិងភាពប្រកួតប្រជែងរបស់ខ្លួន *ជាដើម* តាមរយៈការប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យាពាក់ព័ន្ធនឹងមូលដ្ឋានពាណិជ្ជកម្ម

(ខ) ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការចូលទៅកាន់បណ្ដាញចែកចាយ និងបណ្ដាញព័ត៌មាន

(គ) ការទទួលស្គាល់ថា ការសន្យារបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម ត្រូវបានធ្វើឡើងស្របតាមដំណាក់កាលនៃការអភិវឌ្ឍរៀងខ្លួនៗ និង

(ឃ) ការផ្ដល់ភាពទន់ភ្លន់ដ៏សមស្របសម្រាប់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម ក្នុងដំណើរការនៃការរៀបចំតារាង និងការធ្វើវិសោធនកម្ម ចំពោះឧបសម្ព័ន្ធរបស់ពួកគេ យោងតាមមាត្រា១២។

## មាត្រា ២៨
## ការចូលរួមពីវិស័យឯកជន

១. បណ្ដារដ្ឋសមាជិកត្រូវលើកទឹកចិត្តដល់កិច្ចសន្ទនា អន្តរកម្ម និងការកសាងបណ្ដាញរវាងអ្នកផ្គត់ផ្គង់សេវាកម្មរបស់ខ្លួន។

២. បណ្ដារដ្ឋសមាជិកអាចអញ្ជើញតំណាងនៃអ្នកផ្គត់ផ្គង់សេវាកម្ម ឬសមាគម ដើម្បីផ្ដល់ជាធាតុចូល និង/ឬ ទស្សនៈនានា អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម។

---

[12] សញ្ញាផ្កាយ (*) បង្ហាញអំពីប្រទេសអភិវឌ្ឍន៍តិចតួច ដូចបានកំណត់ដោយលក្ខណៈវិនិច្ឆ័យដែលចេញដោយគណៈកម្មាធិការរបស់ ECOSOC សម្រាប់គោលនយោបាយអភិវឌ្ឍន៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

តេលេក្រាមឯកសារផ្លូវការ: | https://t.me/oa_channel

# ផ្នែកទី ៦
# អវសានប្បញ្ញត្តិ

## មាត្រា ២៩
## ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

ពុំមានអ្វីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវដកហូតនូវសិទ្ធិនិងកាតព្វកិច្ចដែលមានស្រាប់របស់រដ្ឋសមាជិកមួយ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត[13] ដែលរដ្ឋសមាជិកនោះគឺជាភាគីឡើយ។

## មាត្រា ៣០
## ឧបសម្ព័ន្ធនិងលិខិតុបករណ៍គតិយុត្តនាពេលអនាគត

១. កិច្ចព្រមព្រៀងនេះត្រូវរួមបញ្ចូលនូវឧបសម្ព័ន្ធនិងមាតិកានានាដូចខាងក្រោម ដែលខ្លឹមសារនៅក្នុងនោះត្រូវបង្កើតជាផ្នែកស្នូលនៃកិច្ចព្រមព្រៀងនេះ៖

(ក) ឧបសម្ព័ន្ធស្ដីពីសេវាកម្មហិរញ្ញវត្ថុ

(ខ) ឧបសម្ព័ន្ធស្ដីពីសេវាកម្មទូរគមនាគមន៍

(គ) ឧបសម្ព័ន្ធស្ដីពីសេវាកម្មគាំទ្រដល់ការដឹកជញ្ជូនផ្លូវអាកាស

(ឃ) ឧបសម្ព័ន្ធ១ ស្ដីពីវិធានការបដិលោម និង

(ង) ឧបសម្ព័ន្ធ២ ស្ដីពីវិធានការបដិលោម

២. រាល់លិខិតុបករណ៍គតិយុត្តនាពេលអនាគតនានាដែលបានឯកភាពគ្នា ស្របតាមកិច្ចព្រមព្រៀងនេះត្រូវបង្កើតជាផ្នែកស្នូលនៃកិច្ចព្រមព្រៀងនេះផងដែរ។

## មាត្រា៣១
## យន្តការស្ថាប័ន

១. រដ្ឋមន្ត្រីAEM ត្រូវមានភារកិច្ចទទួលខុសត្រូវ ចំពោះការអនុវត្តកិច្ចព្រមព្រៀងនេះ។

២. រដ្ឋមន្ត្រីAEM ត្រូវសម្របសម្រួលនិងត្រួតពិនិត្យលើ ការអនុវត្តកិច្ចព្រមព្រៀងនេះដោយគ្រប់បណ្ដារដ្ឋសមាជិក និងគ្រប់គណៈអាស៊ាននានាដែលពាក់ព័ន្ធ។

៣. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការសម្របសម្រួលអាស៊ានស្ដីពីសេវាកម្ម (CCS) និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ ត្រូវជួយដល់រដ្ឋមន្ត្រីAEM ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

[13] ពាក្យសព្ទ "កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត" រួមបញ្ចូលទាំង កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងពន្ធ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤. នៅក្នុងការបំពេញមុខងាររបស់ខ្លួន រដ្ឋមន្ត្រីAEM អាចនឹងបង្កើតគណៈបុគ្គលសម្ព័ន្ធ និងចាត់តាំងពួកគេឱ្យ ប្រតិបត្តិ/អនុវត្ត/បំពេញ កិច្ចការជាក់លាក់នានា រឺផ្ទេរប្រតិភូកម្មការទទួលខុសត្រូវរបស់ខ្លួនឱ្យទៅគណៈបុគ្គលសម្ព័ន្ធណាមួយ។

## មាត្រា៣២
## ការពិនិត្យឡើងវិញ

ដោយមានទស្សនៈក្នុងការបន្តនូវគោលបំណងនៃកិច្ចព្រមព្រៀងនេះបន្ថែមទៀត បណ្តារដ្ឋសមាជិកត្រូវអនុវត្តនូវការពិនិត្យឡើងវិញទូទៅលើប្រការនានារបស់កិច្ចព្រមព្រៀងនេះ ក្នុងអំឡុងពេល៥ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀង។ ជារៀងរាល់៥ឆ្នាំបន្ទាប់ពីនោះ បណ្តារដ្ឋសមាជិកត្រូវអនុវត្តនូវការពិនិត្យឡើងវិញជាបន្តបន្ទាប់លើប្រការនានានៃកិច្ចព្រមព្រៀង រួមជាមួយគ្នានឹងតារាងវិធានការបដិលោម វៀរលែងតែមានការឯកភាពផ្ទុយពីនេះដោយបណ្តារដ្ឋសមាជិក។

## មាត្រា៣៣
## វិសោធនកម្ម

១. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ អាចនឹងត្រូវបានកែប្រែតាមរយៈការធ្វើវិសោធនកម្មដែលមានការឯកភាពទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយបណ្តារដ្ឋសមាជិក។

២. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ១ ឧបសម្ព័ន្ធនានាដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា៣០ (ឧបសម្ព័ន្ធនិងលិខិតុបករណ៍គតិយុត្តនាពេលអនាគត) អាចនឹងត្រូវបានកែប្រែតាមរយៈការធ្វើវិសោធនកម្មដែលអនុម័តដោយ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន ឬកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានតាមការសមគួរ។ ការធ្វើវិសោធនកម្មបែបនេះ ត្រូវដាក់ជាឧបសម្ព័ន្ធតាមបែបបទរដ្ឋបាលទៅនឹងកិច្ចព្រមព្រៀងនេះ និងប្រើប្រាស់ជាផ្នែកស្នូលនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា៣៤
## ការដោះស្រាយវិវាទ

វៀរលែងតែត្រូវបានបញ្ជាក់ផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ ពិធីសារអាស៊ានស្តីពីការលើកកម្ពស់យន្តការដោះស្រាយវិវាទ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ឬពិធីសារក្រោយៗទៀតរបស់ពិធីសារនេះត្រូវអនុវត្តចំពោះការដោះស្រាយវិវាទពាក់ព័ន្ធនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា៣៥
## ការបដិសេធផលប្រយោជន៍

រដ្ឋសមាជិកណាមួយអាចបដិសេធចំពោះការផ្តល់ផលប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

(ក) ចំពោះការផ្គត់ផ្គង់សេវាកម្មណាមួយ ប្រសិនបើគេឃើញថា សេវាកម្មនោះត្រូវបានផ្គត់ផ្គង់មកពីឬនៅក្នុងដែនដីនៃរដ្ឋមិនមែនសមាជិក

(ខ) ក្នុងករណីការផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូនតាមដែនសមុទ្រ ប្រសិនបើគេឃើញថា សេវាកម្មនោះត្រូវបានផ្គត់ផ្គង់៖

(i) ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់រដ្ឋមិនមែនសមាជិក និង

(ii) ដោយបុគ្គលនៃរដ្ឋមិនមែនសមាជិក ដែលធ្វើប្រតិបត្តិការ និង/ឬ ប្រើប្រាស់នាវានោះទាំងមូលឬដោយផ្នែក

(គ) ចំពោះអ្នកផ្គត់ផ្គង់សេវាកម្មដែលជានីតិបុគ្គល ប្រសិនបើគេឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត។

## មាត្រា៣៦
## ការរៀបចំអន្តរកាលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង AFAS

១. ដោយយោងតាមមាត្រា១២ (ការផ្លាស់ប្តូរទៅជាតារាងវិធានការបដិលោម) កិច្ចព្រមព្រៀងAFAS និងតារាងនៃការសន្យារបស់កិច្ចព្រមព្រៀងAFAS ដែលធ្វើឡើងដោយបណ្តារដ្ឋសមាជិកក្រោមកិច្ចព្រមព្រៀងAFAS ដែលបានចុះហត្ថលេខាដោយ រដ្ឋមន្ត្រីAEM រដ្ឋមន្ត្រីAFM និងរដ្ឋមន្ត្រីATM នឹងនៅតែមានសុពលភាព *ហើយត្រូវយកមកអនុវត្តដូចគ្នា* រហូតដល់រយៈពេល៧ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រហូតដល់រយៈពេល៩ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងចំពោះវៀតណាម ឬរហូតដល់រយៈពេល១៥ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះចំពោះកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

២. កិច្ចព្រមព្រៀងAFAS ព្រមទាំងពិធីសារទាំងឡាយរបស់កិច្ចព្រមព្រៀងAFAS ត្រូវជំនួសដោយកិច្ចព្រមព្រៀងនេះនិងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីការបញ្ចប់ពេញលេញនៃរយៈពេលរៀងៗខ្លួនដូចមានចែងក្នុងកថាខណ្ឌ១។

## មាត្រា៣៧
## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេលមួយរយប៉ែតសិប(១៨០)ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

២. បណ្តារដ្ឋសមាជិកត្រូវបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់ពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការអាស៊ានជាលាយលក្ខណ៍អក្សរ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

៣. ករណីដែលរដ្ឋសមាជិកមួយមិនអាចធ្វើការជូនដំណឹងអំពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខា នោះសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្ដើមក្នុងកាលបរិច្ឆេទ ដែលរដ្ឋសមាជិកនោះជូនដំណឹងអំពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

៤. អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងភ្លាមៗដល់បណ្ដារដ្ឋសមាជិកទាំងអស់ អំពីការជូនដំណឹង ឬការដាក់តម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ននីមួយៗ ដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

## មាត្រាទី ៣៨
## ការតម្កល់ទុក

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្ដល់ជូនភ្លាមៗ នូវច្បាប់ចម្លងដែលមានការបញ្ជាក់ ទៅកាន់រដ្ឋសមាជិកនីមួយៗ។

**ជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដោយទទួលបានសិទ្ធិប្រទានពេញលេញដែលផ្ដល់ដោយរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។

**បានធ្វើ** នៅរដ្ឋធានីម៉ានីល សាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ក្នុងឯកសារច្បាប់ដើមតែមួយគត់ជាភាសាអង់គ្លេស។

តំណាងរដ្ឋាភិបាលព្រុយណេ

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

តំណាងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

តំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី



តំណាងរដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

តំណាងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

## ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ

### មាត្រា១
### វិសាលភាព

១. ឧបសម្ព័ន្ធនេះអនុវត្តចំពោះវិធានការនានាដែលជះឥទ្ធិពលដល់ការផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ។ ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅក្នុងឧបសម្ព័ន្ធនេះ ត្រូវសំដៅដល់ការផ្គត់ផ្គង់សេវាកម្មៈ

(ក) ចេញពីដែនដីនៃរដ្ឋសមាជិកមួយ ចូលទៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី១៖ ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន)

(ខ) នៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ទៅដល់អ្នកប្រើប្រាស់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី២៖ ការប្រើប្រាស់សេវាកម្មនៅបរទេស)

(គ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀត (ម៉ូដទី៣៖ វត្តមានពាណិជ្ជកម្ម)

(ឃ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី៤៖ វត្តមានរូបវន្តបុគ្គល)។

២. ឧបសម្ព័ន្ធនេះមិនអនុវត្តចំពោះ សេវាកម្មដែលត្រូវបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល ដូចខាងក្រោមៈ

(ក) រាល់សកម្មភាពដែលអនុវត្តដោយធនាគារកណ្តាលឬអាជ្ញាធររូបិយវត្ថុ ឬដោយអង្គភាពសាធារណៈផ្សេងទៀត ក្នុងការតាមដានគោលនយោបាយរូបិយវត្ថុឬអត្រាប្តូរប្រាក់

(ខ) រាល់សកម្មភាពដែលជាផ្នែកនៃប្រព័ន្ធកំណត់ដោយច្បាប់ ពាក់ព័ន្ធនឹងសន្តិសុខសង្គម ឬផែនការចូលនិវត្តន៍សាធារណៈ ឬ

(គ) សកម្មភាពផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពសាធារណៈសម្រាប់គណនី ឬការធានា ឬការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។

៣. សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ ប្រសិនបើរដ្ឋសមាជិកអនុញ្ញាតឱ្យមានសកម្មភាពណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ២(ខ) ឬ ២(គ) ដែលអនុវត្តដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុរបស់ខ្លួន ក្នុងការប្រកួតប្រជែងជាមួយអង្គភាពសាធារណៈ ឬអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុណាមួយ "សេវាកម្ម" ត្រូវរួមបញ្ចូលនូវសកម្មភាពបែបនោះ។

ដើម្បីឱ្យកាន់តែច្បាស់ ឧបសម្ព័ន្ធនេះត្រូវមានអធិកភាពបើទោះជាមានអសង្គតិភាពណាមួយទៅនឹងប្រការផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា២
## និយមន័យ

សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

(ក) **ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន** សំដៅដល់ ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅក្នុងវាក្យខណ្ឌ១(ក) និង (ខ) នៃមាត្រា១ (វិសាលភាព) នៃឧបសម្ព័ន្ធនេះ

(ខ) **គ្រឹះស្ថានហិរញ្ញវត្ថុ** សំដៅដល់ អន្តរការីហិរញ្ញវត្ថុ ឬសហគ្រាសផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងត្រូវបានគ្រប់គ្រងឬត្រួតពិនិត្យដោយធនាគារកណ្ដាល អាជ្ញាធររូបិយវត្ថុ ឬអាជ្ញាធរសេវាកម្មហិរញ្ញវត្ថុ ដោយស្ថិតក្រោមច្បាប់នៃរដ្ឋសមាជិកដែលជាម្ចាស់ដែនដីដែលខ្លួនដាក់ទីតាំង។

(គ) **"សេវាកម្មហិរញ្ញវត្ថុ"** សំដៅដល់ សេវាកម្មទាំងឡាយណាដែលមានចរិតលក្ខណៈហិរញ្ញវត្ថុផ្តល់ដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៃរដ្ឋសមាជិកមួយ។ សេវាកម្មហិរញ្ញវត្ថុ រួមមានសេវាកម្មធានារ៉ាប់រងនិងសេវាកម្មពាក់ព័ន្ធនឹងការធានារ៉ាប់រង ព្រមទាំងសេវាកម្មធនាគារ និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីការធានារ៉ាប់រង)។ សេវាកម្មហិរញ្ញវត្ថុ រួមបញ្ចូលនូវសកម្មភាពដូចខាងក្រោម៖

*សេវាកម្មធានារ៉ាប់រងនិងសេវាកម្មពាក់ព័ន្ធនឹងការធានារ៉ាប់រង*

(i) សេវាកម្មធានារ៉ាប់រងផ្ទាល់(រួមទាំងសហធានារ៉ាប់រង)៖
   ក. អាយុជីវិត
   ខ. មិនមែនអាយុជីវិត

(ii) ការធានារ៉ាប់រងបន្តនិងការផ្ទេរហានិភ័យសេវាកម្មធានារ៉ាប់រងបន្ត

(iii) អន្តរការីធានារ៉ាប់រង ដូចជា ឈ្មួញកណ្ដាលនិងភ្នាក់ងារធានារ៉ាប់រង

(iv) សេវាកម្មទ្រទ្រង់ដល់ការធានារ៉ាប់រង មានដូចជា ការប្រឹក្សាយោបល់ ការគណនានិងការវិភាគផ្សេងៗ ការវាយតម្លៃលើហានិភ័យ និងសេវាកម្មទូទាត់ចំពោះការទាមទារផលប្រយោជន៍។

*សេវាកម្មធនាគារនិងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីការធានារ៉ាប់រង)*

(v) ការទទួលប្រាក់បញ្ញើនិងការទទួលមូលនិធិសំណងផ្សេងទៀតពីសាធារណជន

(vi) ការផ្តល់ឥណទានគ្រប់ប្រភេទ រួមមាន ឥណទានអតិថិជន ឥណទានអ៊ីប៉ូតែក ការទិញបំណុលនិងការផ្តល់ហិរញ្ញប្បទានចំពោះប្រតិបត្តិការពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

(vii) ភតិសន្យាហិរញ្ញវត្ថុ

(viii) រាល់សេវាកម្មទូទាត់និងផ្ទេរប្រាក់ រួមបញ្ចូល ឥណទាន កម្រៃផ្សេងៗ ប័ណ្ណឥណពន្ធ មូលប្បទានបត្រសម្រាប់អ្នកធ្វើដំណើរ និងមូលប្បទានបត្រធនាគារិក

(ix) ការធានានិងការសន្យា

(x) ការធ្វើពាណិជ្ជកម្មសម្រាប់គណនីផ្ទាល់ខ្លួន ឬគណនីរបស់អតិថិជន មិនថាជាការដោះដូរឬយ៉ាងណា នៅក្នុងទីផ្សារជួញដូរភាគហ៊ុនបន្ទាប់បន្សំ ឬក្រៅពីនេះ មានដូចតទៅ៖

ក. ឧបករណ៍ទីផ្សាររូបិយវត្ថុ (រួមមានមូលប្បទានបត្រ រូបិយណត្តិ វិញ្ញាបនបត្រប្រាក់បញ្ញើ)

ខ. ទីផ្សារប្តូរប្រាក់

គ. ឧបករណ៍និស្សន្ទ រួមមានប៉ុន្តែមិនកម្រិតចំពោះ កិច្ចសន្យាអនាគត និងអុបសិន

ឃ. ឧបករណ៍អត្រាប្តូរប្រាក់និងអត្រាការប្រាក់ រួមបញ្ចូលទាំងផលិតផលដូចជាប្រតិបត្តិការស្វប កិច្ចព្រមព្រៀងអត្រាការប្រាក់ក្នុងពេលអនាគត

ង. មូលបត្រដែលអាចផ្ទេរបាន និង

ច. ឧបករណ៍អាចជួញដូរបានផ្សេងទៀត និងទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងមាសដុំ

(xi) ការចូលរួមក្នុងការបោះផ្សាយមូលបត្រគ្រប់ប្រភេទ រួមមាន ការធានាទិញនិងការដាក់លក់មូលបត្រចង្អៀតក្នុងនាមជាភ្នាក់ងារ (មិនថាជាលក្ខណៈសាធារណៈឬឯកជន) និងការផ្តល់នូវសេវាកម្មដែលពាក់ព័ន្ធនឹងការបោះផ្សាយទាំងនោះ

(xii) អាជីវកម្មឈ្មួញកណ្តាលជួញដូររូបិយវត្ថុ

(xiii) ការគ្រប់គ្រងទ្រព្យសកម្ម ដូចជា ការគ្រប់គ្រងសាច់ប្រាក់ ឬផលបត្រ គ្រប់ទម្រង់នៃការគ្រប់គ្រងការវិនិយោគរួម ការគ្រប់គ្រងមូលនិធិសោធន សេវាកម្មមូលបត្រ សេវាកម្មរក្សាទុក និងបរធនបាលកិច្ច

(xiv) សេវាកម្មផាត់ទាត់និងទូទាត់សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ រួមមានមូលបត្រ ឧបករណ៍និស្សន្ទ និងឧបករណ៍អាចជួញដូរបានផ្សេងទៀត

(xv) ការផ្តល់និងការផ្ទេរព័ត៌មានហិរញ្ញវត្ថុ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ និងកម្មវិធីកុំព្យូទ័រពាក់ព័ន្ធ ដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុផ្សេងទៀត និង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

(xvi) ការផ្តល់ការប្រឹក្សាយោបល់ អន្តរការីយកម្ម និងសេវាកម្មទ្រទ្រង់ដល់សេវាកម្មហិរញ្ញវត្ថុផ្សេងទៀត សម្រាប់គ្រប់សកម្មភាពដូចមានចែងនៅក្នុងវាក្យខណ្ឌ (v) ដល់ (xv) ដែលរួមបញ្ចូលទាំងរបាយការណ៍និងការវិភាគឥណទាន ការវិនិយោគនិងការស្រាវជ្រាវលើផលបត្រ និងអនុសាសន៍ ដំបូន្មានអំពីការទិញយកនិងការរៀបចំរចនាសម្ព័ន្ធសាជីវកម្មនិងយុទ្ធសាស្ត្រ

(ឃ) "**អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ**" សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលនៃរដ្ឋសមាជិកមួយ ដែលមានបំណងផ្គត់ផ្គង់ឬកំពុងផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ប៉ុន្តែវាក្យសព្ទ "អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ" នេះ មិនរាប់បញ្ចូលអង្គភាពសាធារណៈឡើយ

(ង) "**សេវាកម្មហិរញ្ញវត្ថុថ្មី**" សំដៅដល់ សេវាកម្មហិរញ្ញវត្ថុដែលមិនមានផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុណាមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ប៉ុន្តែត្រូវបានផ្គត់ផ្គង់ និងត្រូវបានគ្រប់គ្រងនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។ សេវាកម្មទាំងនោះអាចរួមបញ្ចូលនូវសេវាកម្មពាក់ព័ន្ធនឹងផលិតផលដែលមានស្រាប់និងថ្មី ឬក្នុងលក្ខណៈមួយដែលផលិតផលនោះត្រូវបានចែកចាយ។

(ច) "**អង្គភាពសាធារណៈ**" សំដៅដល់៖

(i) រដ្ឋាភិបាល ធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុនៃរដ្ឋសមាជិកមួយ ឬអង្គភាពមួយដែលត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយរដ្ឋសមាជិកមួយ ដែលជាទូទៅចូលរួមអនុវត្តមុខងាររបស់រដ្ឋាភិបាល ឬសកម្មភាពនានាសម្រាប់បំពេញគោលបំណងរបស់រដ្ឋាភិបាល មិនរួមបញ្ចូលអង្គភាពដែលជាទូទៅផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុតាមបែបលក្ខណៈពាណិជ្ជកម្មឡើយ ឬ

(ii) អង្គភាពឯកជនដែលបំពេញនូវមុខងារនានា ដែលជាធម្មតាមុខងារទាំងនោះច្រើនតែបំពេញដោយធនាគារកណ្តាលឬអាជ្ញាធររូបិយវត្ថុ នៅពេលដែលអង្គភាពឯកជននោះអនុវត្តនូវមុខងារទាំងនោះ និង

(ឆ) "**អង្គភាពស្វ័យនិយតករ**" សំដៅដល់ ស្ថាប័នមិនមែនរដ្ឋាភិបាលទាំងឡាយណា រួមមានក្រុមហ៊ុនផ្សារមូលបត្រឬក្រុមហ៊ុនផ្សារអនាគត ភ្នាក់ងារទូទាត់ឬផាត់ទាត់ អង្គភាពឬសមាគមផ្សេងទៀត ដែល៖

(i) ត្រូវបានទទួលស្គាល់ថាជាអង្គភាពស្វ័យនិយតករ និង/ឬ

(ii) អនុវត្តអំណាចរៀបចំបទប្បញ្ញត្តិនិងត្រួតពិនិត្យ ទៅលើអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឬគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងដែនដីរបស់ខ្លួន

ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្តិ ឬតាមប្រតិភូកម្មអំណាចពីរដ្ឋាភិបាលឬអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការសាធារណៈ | https://t.me/oa_channel

## មាត្រា៣
## សេវាកម្មហិរញ្ញវត្ថុថ្មី

រដ្ឋសមាជិកនីមួយៗ ("រដ្ឋសមាជិកជាម្ចាស់ផ្ទះ") ត្រូវផ្ដល់ការផ្ដល់ការពិចារណាប្រកបដោយហេតុផល ចំពោះការដាក់ពាក្យស្នើសុំដោយគ្រឹះស្ថានហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀត ដែលត្រូវបានបង្កើតនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ដើម្បីធ្វើការផ្ដល់សេវាកម្មហិរញ្ញវត្ថុថ្មីណាមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ដែលរដ្ឋសមាជិកជាម្ចាស់ផ្ទះនោះក៏បានផ្ដល់ការអនុញ្ញាតដល់គ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន ស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដើម្បីធ្វើការផ្ដត់ផ្គង់ដោយពុំចាំបាច់អនុម័តច្បាប់ឬកែប្រែច្បាប់ដែលមានស្រាប់[1]។

ករណីដែលពាក្យស្នើសុំទទួលបានការឯកភាព ការផ្ដល់សេវាកម្មហិរញ្ញវត្ថុថ្មីគឺត្រូវអាស្រ័យទៅនឹងការផ្ដល់អាជ្ញាប័ណ្ណ ទម្រង់ស្ថាប័នឬគតិយុត្ត ឬការតម្រូវផ្សេងទៀតរបស់រដ្ឋសមាជិកជាម្ចាស់ផ្ទះ។

## មាត្រា៤
## វិធានការការពារសុវត្ថិភាព

១. ថ្វីបើមានចែងក្នុងប្រការផ្សេងទៀតទាំងឡាយនៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកមួយមិនត្រូវបានរារាំងពីការដាក់ចេញនូវវិធានការនានាក្នុងមូលហេតុនៃការប្រុងប្រយ័ត្នឡើយ រួមមាន សម្រាប់ការការពារវិនិយោគិន អ្នកតម្កល់ប្រាក់ ម្ចាស់ប័ណ្ណធានារ៉ាប់រង ឬអ្នកទទួលបានតួនាទីរក្សាទំនុកចិត្តដែលជំពាក់ដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុមួយ ឬដើម្បីធានានូវបូរណភាពនិងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ឬដើម្បីធានានូវស្ថិរភាពនៃអត្រាប្ដូរប្រាក់ ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

(ក) ករណីដែលវិធានការទាំងនោះ មិនស្របទៅនឹងប្រការនានានៃកិច្ចព្រមព្រៀងនេះ វិធានការទាំងនោះមិនត្រូវប្រើប្រាស់ជាមធ្យោបាយ ក្នុងការចៀសវាងការសន្យាឬកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះនៅក្រោមកិច្ចព្រមព្រៀងនេះឡើយ និង

(ខ) ចំពោះវិធានការដើម្បីធានានូវស្ថិរភាពនៃអត្រាប្ដូរប្រាក់ វិធានការទាំងនោះត្រូវធ្វើឡើងមិនឱ្យលើសពីភាពចាំបាច់ និងត្រូវបានលុបចោល នៅពេលដែលលក្ខខណ្ឌនានាលែងឆ្លុះបញ្ចាំងពីភាពសមហេតុផលនៃការប្រព្រឹត្តទៅឬការរក្សាទុក ហើយវិធានការទាំងនោះត្រូវអនុវត្តដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត។

២. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយលាតត្រដាងនូវព័ត៌មានពាក់ព័ន្ធនឹងកិច្ចការនិងគណនីបុគ្គលរបស់អតិថិជន ឬព័ត៌មានដែលជាការសម្ងាត់ ឬព័ត៌មានពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលជាកម្មសិទ្ធិរបស់អង្គភាពសាធារណៈឡើយ។

---

[1] ដើម្បីឱ្យកាន់តែច្បាស់ រដ្ឋសមាជិកមួយអាចដាក់ចេញនូវបទប្បញ្ញត្តិថ្មី ឬវិធានការពាក់ព័ន្ធបន្ថែមផ្សេងទៀត ក្នុងការអនុញ្ញាតចំពោះការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុថ្មី។

## មាត្រា៥
## ការទទួលស្គាល់

១. រដ្ឋសមាជិកមួយអាចទទួលស្គាល់វិធានការប្រុងប្រយ័ត្នរបស់រដ្ឋផ្សេងៗទៀត ឬស្ថាប័នដែលរៀបចំស្តង់ដាអន្តរជាតិនានា ក្នុងការកំណត់ពីរបៀបដែលវិធានការរបស់រដ្ឋសមាជិកពាក់ព័ន្ធនឹងសេវាកម្មហិរញ្ញវត្ថុត្រូវបានអនុវត្ត[2]។ ការទទួលស្គាល់បែបនេះ ដែលអាចនឹងសម្រេចទៅបានតាមរយៈការធ្វើសុខដុមនីយកម្មឬតាមមធ្យោបាយផ្សេងទៀត អាចផ្អែកលើកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលណាមួយជាមួយនឹងរដ្ឋពាក់ព័ន្ធ ឬស្ថាប័នដែលរៀបចំស្តង់ដាអន្តរជាតិនានា ឬក៏អាចផ្តល់ជូនដោយស្វ័យត។

២. រដ្ឋសមាជិកមួយដែលជាភាគីនៃកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលបែបនោះ ដូចមានចែងក្នុងកថាខណ្ឌ១ មិនថានៅពេលអនាគតឬមានស្រាប់ ត្រូវផ្តល់នូវកាលានុវត្តភាពគ្រប់គ្រាន់សម្រាប់រដ្ឋសមាជិកផ្សេងទៀតដែលមានចំណាប់អារម្មណ៍ ដើម្បីចរចាលើការចូលរួមរបស់ពួកគេនៅក្នុងកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលនោះ ឬដើម្បីចរចាលើកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយស្ថិតក្រោមកាលៈទេសៈដែលមាននូវបទប្បញ្ញត្តិការគ្រប់គ្រង ការអនុវត្តបទប្បញ្ញត្តិនោះ ដែលមានលក្ខណៈសមមូល ហើយប្រសិនបើសមគួរនីតិវិធីនានាពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានរវាងភាគីនៃកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលនោះ។ ករណីដែលរដ្ឋសមាជិកមួយផ្តល់នូវការទទួលស្គាល់ដោយស្វ័យត រដ្ឋសមាជិកនោះត្រូវផ្តល់នូវកាលានុវត្តភាពគ្រប់គ្រាន់សម្រាប់រដ្ឋសមាជិកផ្សេងទៀត ដើម្បីបំភ្លឺថា កាលៈទេសៈបែបនោះពិតជាមានមែន។

## មាត្រា៦
## តម្លាភាព

១. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា បទប្បញ្ញត្តិនិងគោលនយោបាយគ្រប់គ្រងលើសកម្មភាពនានានៃសេវាកម្មហិរញ្ញវត្ថុដែលប្រកបដោយតម្លាភាព មានសារៈសំខាន់ក្នុងការសម្របសម្រួលដល់អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុបរទេស ឱ្យមានលទ្ធភាពឈានចូលទៅកាន់និងធ្វើប្រតិបត្តិការនៅក្នុងទីផ្សាររវាងគ្នានិងគ្នា។ រដ្ឋសមាជិកនីមួយៗប្តេជ្ញាចិត្តក្នុងការជំរុញតម្លាភាពបទប្បញ្ញត្តិនៅក្នុងសេវាកម្មហិរញ្ញវត្ថុ។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា វិធានការនៃការអនុវត្តទូទៅដែលត្រូវបានអនុម័តឬរក្សាទុកដោយរដ្ឋសមាជិកនោះ ត្រូវបានផ្សព្វផ្សាយទាន់ពេលវេលា ឬម៉្យាងទៀតធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ។ ព័ត៌មានទាំងនោះអាចត្រូវបានផ្សព្វផ្សាយជាភាសាតាមជម្រើសរបស់

[2] ដើម្បីឱ្យកាន់តែច្បាស់ ពុំមានអ្វីនៅក្នុងមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធនេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកផ្តល់នូវការទទួលស្គាល់វិធានការប្រុងប្រយ័ត្នរបស់រដ្ឋសមាជិកផ្សេងទៀតឡើយ។



គេហទំព័រ ឯកសារផ្លូវការ: | https://t.me/oa_channel
ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

រដ្ឋសមាជិក។ រដ្ឋសមាជិកនីមួយៗ ត្រូវខិតខំព្យាយាមក្នុងការផ្សព្វផ្សាយជាភាសាអង់គ្លេសនូវការបកប្រែទាំងស្រុង ឬខ្លឹមសារសង្ខេប ឬសេចក្តីពន្យល់នៃវិធានការនៃការអនុវត្តទូទៅទាំងនោះ។ ការផ្សព្វផ្សាយបែបនោះមិនត្រូវចាត់ទុកថា ជាការបកប្រែផ្លូវការឡើយ លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះ។

៣. តាមលទ្ធភាពដែលអាចធ្វើទៅបាន រដ្ឋសមាជិកនីមួយៗត្រូវ៖

(ក) ធ្វើការផ្សព្វផ្សាយ ឬធ្វើយ៉ាងណាឱ្យបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចទទួលបានជាមុននូវច្បាប់និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ដែលរដ្ឋសមាជិកនោះបានស្នើឡើងដើម្បីអនុម័ត ព្រមទាំងគោលបំណងនៃច្បាប់និងបទប្បញ្ញត្តិទាំងនោះ និង

(ខ) ផ្តល់ឱ្យបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍[3] និងរដ្ឋសមាជិកផ្សេងទៀតនូវកាលានុវត្តភាពសមស្រប ដើម្បីផ្តល់យោបល់ចំពោះច្បាប់និងបទប្បញ្ញត្តិដែលបានស្នើឡើងទាំងនោះ។

៤. អាជ្ញាធរផ្នែកនិយតកម្មនៃរដ្ឋសមាជិកនីមួយៗ ត្រូវធ្វើយ៉ាងណាឱ្យបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចដឹងអំពីលក្ខខណ្ឌតម្រូវនានា រាប់បញ្ចូលទាំងឯកសារនានាដែលតម្រូវឱ្យមាន សម្រាប់ការបំពេញពាក្យស្នើសុំពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ។

៥. ករណីមានការស្នើជាលាយលក្ខណ៍អក្សរពីអ្នកដាក់ពាក្យស្នើសុំ អាជ្ញាធរផ្នែកនិយតកម្មត្រូវផ្តល់ព័ត៌មានដល់អ្នកដាក់ពាក្យស្នើសុំនោះអំពីស្ថានភាពនៃការស្នើសុំ។ ប្រសិនបើអាជ្ញាធរនោះតម្រូវឱ្យផ្តល់នូវព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យស្នើសុំ អាជ្ញាធរនោះត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមួយសមស្រប។

៦. អាជ្ញាធរផ្នែកនិយតកម្មត្រូវធ្វើសេចក្តីសម្រេចចិត្តផ្នែករដ្ឋបាល ចំពោះពាក្យស្នើសុំដែលពេញលេញរបស់អ្នកដាក់ពាក្យស្នើសុំពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ នៅក្នុងអំឡុងពេល ១៨០ថ្ងៃ ហើយត្រូវជូនដំណឹងឱ្យបានទាន់ពេលវេលាដល់អ្នកដាក់ពាក្យស្នើសុំអំពីសេចក្តីសម្រេចចិត្តនោះ។ ពាក្យស្នើសុំមួយមិនត្រូវចាត់ទុកថាពេញលេញឡើយ រហូតដល់រាល់ការបកស្រាយបំភ្លឺនានាត្រូវបានប្រព្រឹត្តទៅ ហើយអាជ្ញាធរផ្នែកនិយតកម្មចាត់ទុកថារាល់ព័ត៌មានចំបាច់ត្រូវបានទទួល។ ករណីដែលការអនុវត្តជាក់ស្តែងមិនអាចប្រព្រឹត្តទៅបានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងអំឡុងពេល ១៨០ថ្ងៃ អាជ្ញាធរផ្នែកនិយតកម្មត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមួយសមស្រប ហើយត្រូវខិតខំព្យាយាមធ្វើសេចក្តីសម្រេចចិត្តឱ្យបានក្នុងរយៈពេលមួយសមស្របបន្ទាប់ពីនោះ។

---

[3] រដ្ឋភាគីសមាជិក បានបញ្ជាក់អំពីការយល់ដឹងរួមដូចគ្នាថា បុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍នៅក្នុងមាត្រានេះ គឺជាបុគ្គលទាំងឡាយដែលផលប្រយោជន៍ផ្ទាល់ផ្នែកហិរញ្ញវត្ថុរបស់ពួកគេ អាចនឹងរងឥទ្ធិពលជាដុំកំភួនពីការអនុម័តនូវច្បាប់និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅទាំងនោះ។

៧. ករណីមានការស្នើដាក់យលក្ខណ៍អក្សរពីអ្នកដាក់ពាក្យស្នើសុំដែលមិនទទួលបានជោគជ័យ អាជ្ញាធរផ្នែកនិយតកម្មដែលបានបដិសេធចំពោះពាក្យស្នើសុំ ត្រូវតែខិតខំព្យាយាមផ្តល់ព័ត៌មានដល់អ្នកដាក់ពាក្យស្នើសុំ អំពីហេតុផលនានាសម្រាប់ការបដិសេធចំពោះពាក្យស្នើសុំនោះ។

៨. រដ្ឋសមាជិកនីមួយៗត្រូវរក្សាទុកឬបង្កើតនូវយន្តការសមស្រប ដែលឆ្លើយតបចំពោះការសាកសួរព័ត៌មាននានាពីសំណាក់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ទាក់ទងទៅនឹងវិធានការនៃការអនុវត្តទូទៅដែលគ្របដណ្តប់ដោយឧបសម្ព័ន្ធនេះ។

៩. រដ្ឋសមាជិកនីមួយៗត្រូវចាត់វិធានការសមស្របដែលអាចនឹងធ្វើទៅបាន ដើម្បីធានាថា វិធាននៃការអនុវត្តទូទៅដែលបានអនុម័តឬរក្សាទុកដោយអង្គភាពស្វ័យនិយតករ[4] របស់រដ្ឋសមាជិកនោះ ត្រូវបានផ្សព្វផ្សាយទាន់ពេលវេលា ឬម៉្យាងទៀតធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ[5]។

១០. តាមលទ្ធភាពដែលអាចអនុវត្តទៅបាន រដ្ឋសមាជិកនីមួយៗគប្បីអនុញ្ញាតឱ្យមានរយៈពេលសមស្របមួយ រវាងការផ្សព្វផ្សាយអំពីបទប្បញ្ញត្តិចុងក្រោយ និងកាលបរិច្ឆេទនៃការចូលជាធរមានរបស់បទប្បញ្ញត្តិនោះ។

## មាត្រា៧
## ប្រព័ន្ធទូទាត់និងផាត់ទាត់

ស្ថិតក្រោមខចែងនិងលក្ខខណ្ឌនានា ដែលផ្តល់នូវប្រព្រឹត្តិកម្មជាតិ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក នោះរដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀតដែលបានបង្កើតឡើងនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ទទួលបាននូវលទ្ធភាពចូលទៅកាន់ប្រព័ន្ធទូទាត់និងផាត់ទាត់ ដែលត្រូវបានប្រតិបត្តិការដោយអង្គភាពសាធារណៈ និងលទ្ធភាពចូលទៅកាន់ឧបករណ៍សម្រួលដល់ការផ្តល់មូលនិធិនិងហិរញ្ញប្បទានផ្លូវការនានា ដែលមានក្នុងប្រតិបត្តិការធុរកិច្ចទូទៅ។ កថាខណ្ឌនេះមិនមានបំណងដើម្បីផ្តល់នូវលទ្ធភាពចូលទៅកាន់ឧបករណ៍ឥណទានធនាគារកណ្តាលរបស់រដ្ឋសមាជិកនោះឡើយ។

## មាត្រា៨
## អង្គភាពស្វ័យនិយតករ

ប្រសិនបើរដ្ឋសមាជិកមួយ តម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុណាមួយនៃរដ្ឋសមាជិកផ្សេងទៀតក្លាយទៅជាសមាជិកនៃ ឬចូលរួមក្នុង ឬមានលទ្ធភាពចូលទៅកាន់អង្គភាពស្វ័យនិយតករដើម្បីផ្តល់នូវសេវាកម្មហិរញ្ញវត្ថុនៅក្នុងដែនដីរបស់ខ្លួន រដ្ឋសមាជិកនោះនឹងខិតខំព្យាយាមដើម្បីធានាថា អង្គភាពស្វ័យនិយតករនោះប្រតិបត្តិតាមកាតព្វកិច្ចនានានៅក្នុងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) នៃកិច្ចព្រមព្រៀងនេះ និងមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធនេះ។

---

[4] កថាខណ្ឌនេះ អនុវត្តចំពោះតែរដ្ឋសមាជិកណាមួយ ករណីដែលរដ្ឋសមាជិកនោះបានបង្កើតនូវអង្គភាពស្វ័យនិយតករប៉ុណ្ណោះ។

[5] ដើម្បីឱ្យកាន់តែច្បាស់ បណ្តារដ្ឋសមាជិកបានឯកភាពថា ព័ត៌មានបែបនោះអាចនឹងត្រូវបានផ្សព្វផ្សាយជាភាសាតាមជម្រើសរបស់រដ្ឋសមាជិកនីមួយៗ។



https://t.me/oa_channel

## មាត្រា៥
## ការផ្ទេរព័ត៌មាននិងដំណើរការព័ត៌មាន

១. រដ្ឋសមាជិកមួយមិនត្រូវចាត់វិធានការនានាដែលៈ

(ក) រារាំងដល់ការផ្ទេរព័ត៌មាន រួមមាន ការផ្ទេរទិន្នន័យតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ

(ខ) រារាំងដល់ដំណើរការព័ត៌មាន ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ឬ

(គ) រារាំងដល់ការផ្ទេរឧបករណ៍ ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ដោយអាស្រ័យទៅនឹងវិធាននៃការនាំចូលទាំងឡាយដែលមានសង្គតិភាពទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិនានា។

២. ពុំមានអ្វីនៅក្នុងកថាខណ្ឌ១ ដែលៈ

(ក) រឹតត្បិតដល់សិទ្ធិរបស់រដ្ឋសមាជិកមួយដើម្បីការពារទិន្នន័យផ្ទាល់ខ្លួន ឯកជនភាពផ្ទាល់ខ្លួន និងការសម្ងាត់នៃកំណត់ត្រានិងគណនីបុគ្គល រួមបញ្ចូលទាំងភាពអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ដរាបណាសិទ្ធិបែបនោះមិនត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការគេចវេះពីការសន្យាឬភាតព្វកិច្ចនានារបស់រដ្ឋសមាជិកនោះ ក្រោមកិច្ចព្រមព្រៀងនេះ

(ខ) រារាំងដល់និយតករណាមួយនៃរដ្ឋសមាជិក ក្រោមមូលហេតុផ្នែកច្បាប់និងការប្រុងប្រយ័ត្ន ពីការតម្រូវឱ្យអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅក្នុងដែនដីរបស់ខ្លួន ប្រតិបត្តិតាមបទប្បញ្ញត្តិក្នុងស្រុក ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យ[6] និងការផ្ទុកទិន្នន័យ និងការថែទាំប្រព័ន្ធទិន្នន័យ ក៏ដូចជាការរក្សាទុកនូវច្បាប់ចម្លងនៃកំណត់ត្រានានានៅក្នុងដែនដីរបស់ខ្លួន ឬ

(គ) ត្រូវបានបកស្រាយ ដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយធ្វើការអនុញ្ញាតឱ្យមានការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន ឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មនានាពាក់ព័ន្ធនឹងអ្វីដែលខ្លួនពុំបានធ្វើការសន្យា រួមទាំង ធ្វើការអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុដែលជាអនិវាសនជន ធ្វើការផ្គត់ផ្គង់នូវ ទោះជាក្នុងនាមជាអ្នកផ្គត់ផ្គង់បង្គោលតាមរយៈអន្តរការីឬក្នុងនាមជាអន្តរការី ការផ្តល់និងការផ្ទេរព័ត៌មានហិរញ្ញវត្ថុ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌ(គ)(xv) នៃមាត្រា២ (និយមន័យ) នៃឧបសម្ព័ន្ធនេះ។[7]

---

[6] ដើម្បីឱ្យកាន់តែច្បាស់ ការគ្រប់គ្រងទិន្នន័យ រួមមាន ភាតព្វកិច្ចដំណើរការក្នុងមូលដ្ឋាននៃប្រតិបត្តិការទូទាត់ក្នុងស្រុក។

[7] ដើម្បីឱ្យកាន់តែច្បាស់ ករណីដែលរដ្ឋសមាជិកមួយមិនបានធ្វើការសន្យាវិស័យសេវាកម្ម ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែនឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មណាមួយ រដ្ឋសមាជិកនោះត្រូវមានសិទ្ធិក្នុងការចាត់វិធានការនានាដែលរារាំងការផ្ទេរព័ត៌មាន ដំណើរការព័ត៌មាន ឬការផ្ទេរឧបករណ៍ ដូចមានចែងក្នុងកថាខណ្ឌ១ ពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា១០

## ការដោះស្រាយវិវាទ

សមាជិកនៃក្រុមការងារដែលត្រូវបានបង្កើតស្របតាមមាត្រា៣៤ (ការដោះស្រាយវិវាទ) នៃកិច្ចព្រមព្រៀងនេះ សម្រាប់ការដោះស្រាយវិវាទលើបញ្ហាពាក់ព័ន្ធនឹងការប្រុងប្រយ័ត្ន និងបញ្ហាពាក់ព័ន្ធនឹងហិរញ្ញវត្ថុផ្សេងទៀត ត្រូវមានជំនាញចាំបាច់ពាក់ព័ន្ធទៅនឹងសេវាកម្មហិរញ្ញវត្ថុជាក់លាក់ដែលស្ថិតក្នុងវិវាទ។

## មាត្រា១១

## ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្ដល់ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឲ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្ដល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត។[៥]

២. ថ្វីបើមានចែងក្នុងកថាខណ្ឌ១ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប្រសិនបើរដ្ឋសមាជិកមួយបញ្ចប់ឬធ្វើវិសោធនកម្មកិច្ចព្រមព្រៀងទាំងឡាយណា ជាមួយនឹងរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក នោះរដ្ឋសមាជិកផ្សេងទៀតអាចស្នើសុំធ្វើការចរចាក្នុងគោលបំណងដាក់បញ្ចូលក្រោមកិច្ចព្រមព្រៀងនេះ នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលផ្ដល់ដោយកិច្ចព្រមព្រៀងនោះឡើយ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំ ត្រូវចូលរួមក្នុងការចរចាជាមួយនឹងរដ្ឋសមាជិកស្នើសុំ។ រាល់ការផ្ដល់នូវប្រព្រឹត្តិកម្មអនុគ្រោះបែបនោះដល់រដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះផ្នែកទាំងឡាយណាដែលជារបស់រដ្ឋសមាជិកដែលត្រូវបានស្នើសុំ។

៣. រដ្ឋសមាជិកអាចរក្សាទុកនូវវិធានការដែលអសង្គតិភាពទៅនឹងកថាខណ្ឌ១ ប្រសិនបើវិធានការបែបនោះត្រូវបានដាក់បញ្ចូលនៅក្នុង និងបំពេញតាមលក្ខខណ្ឌនៃ បញ្ជីលើកលែងប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់ខ្លួន។

៤. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ មិនត្រូវបានបកស្រាយដើម្បីរាំងរដ្ឋសមាជិកណាមួយពីការអនុញ្ញាតឬការផ្ដល់អត្ថប្រយោជន៍នានាដល់ប្រទេសជាប់ព្រំដែន ក្នុងគោលបំណងសម្រួលដល់ការដោះដូរនានាដែលកំណត់ចំពោះតំបន់មានព្រំដែនជាប់គ្នានូវសេវាកម្មដែលត្រូវបានផលិត និងប្រើប្រាស់ក្នុងតំបន់មូលដ្ឋាន។

---

ព្រំដែនឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មនោះ ដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុដូចមានចែងក្រោមកថាខណ្ឌ១។ យ៉ាងណាមិញ រដ្ឋសមាជិកមួយមិនត្រូវគេចវេះពីកាតព្វកិច្ចរបស់ខ្លួន ដើម្បីអនុញ្ញាតចំពោះការផ្ទេរនិងដំណើរការទាំងឡាយណាដែលមានពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែនឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មមួយ ដែលប្រព្រឹត្តទៅសម្រាប់គោលបំណងនៃការគ្រប់គ្រងត្រួតពិនិត្យជាក្រុម និងការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវនៃរបាយការណ៍របស់រដ្ឋសមាជិកផ្សេងទៀតឡើយ។

[illegible]ដើម្បីឱ្យកាន់តែច្បាស់ កាតព្វកិច្ចនានានៅក្នុងកថាខណ្ឌ១និង៣ អនុវត្តចំពោះតែការសន្យាវិស័យសេវាកម្មហិរញ្ញវត្ថុ ក្រោមកញ្ចប់សន្យា[illegible]កិច្ចព្រមព្រៀងAFAS លើកលែងតែការសន្យាក្រោមកិច្ចព្រមព្រៀងក្របខណ្ឌសមាហរណកម្មធនាគារអាស៊ាន (ABIF)។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គេហទំព័រ អង្គភាពព័ត៌មាន | https://t.me/oa_channel

## មាត្រា១២
## ការរៀបចំដើម្បីពន្លឿនសមាហរណកម្មហិរញ្ញវត្ថុ

១. រដ្ឋសមាជិកពីរឬច្រើនអាចរៀបចំការចរចានិងឯកភាពគ្នា ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មចំពោះវិស័យឬអនុវិស័យជាក់លាក់ ("បណ្តារដ្ឋសមាជិកចូលរួម")។ ការផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះចំពោះបណ្តារដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះផ្នែកទាំងឡាយណាដែលជារបស់រដ្ឋសមាជិកចូលរួម។

២. បណ្តារដ្ឋសមាជិកចូលរួម ត្រូវរក្សានូវការផ្តល់ព័ត៌មានដល់រដ្ឋសមាជិកដែលនៅសេសសល់តាមរយៈលេខាធិការដ្ឋានអាស៊ានអំពីវឌ្ឍនភាពឬលទ្ធផលនៃការចរចា រួមទាំងការរៀបចំតារាងសន្យាសម្រាប់វិស័យឬអនុវិស័យជាក់លាក់ដែលពាក់ព័ន្ធ។ រដ្ឋសមាជិកទាំងឡាយណាដែលមានបំណងចូលរួមការចរចាដែលកំពុងបន្តនានា ក្នុងចំណោមបណ្តារដ្ឋសមាជិកចូលរួម អាចធ្វើទៅបានដោយការពិគ្រោះយោបល់ជាមួយនឹងបណ្តារដ្ឋសមាជិកចូលរួម។

៣. រដ្ឋសមាជិកណាមួយដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងណាមួយ ដែលធ្វើឡើងស្របតាមកថាខណ្ឌ១ អាចចូលរួមក្នុងកិច្ចព្រមព្រៀងនោះបាន ដោយអាស្រ័យទៅនឹងការឯកភាពគ្នាជាឯកច្ឆន្ទពីបណ្តារដ្ឋសមាជិកចូលរួម។

៤. បណ្តារដ្ឋសមាជិកចូលរួម អាចកែលម្អបន្ថែមលើប៉ារ៉ាម៉ែត្រសម្រាប់វិស័យឬអនុវិស័យជាក់លាក់ដែលនឹងធ្វើការសន្យា ដូចដែលអាចនឹងផ្អែកតាមការឯកភាពគ្នាជារួម ដោយបណ្តារដ្ឋសមាជិកចូលរួមទាំងអស់ ក្នុងគោលបំណងនៃការធ្វើសេរីភាវូបនីយកម្មបន្ថែមលើពាណិជ្ជកម្មសេវាកម្ម។

៥. រាល់កិច្ចព្រមព្រៀងដែលធ្វើឡើងស្របតាមកថាខណ្ឌ១ ត្រូវដាក់តម្កល់ជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជូនភ្លាមៗនូវច្បាប់ចម្លងដែលមានការបញ្ជាក់ទៅកាន់រដ្ឋសមាជិកចូលរួមនីមួយៗ និងជូនដំណឹងដូចគ្នាដល់បណ្តារដ្ឋសមាជិកផ្សេងទៀត។

## មាត្រា១៣
## ច្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ[៩]

ពាក់ព័ន្ធនឹងច្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុណាមួយរបស់រដ្ឋសមាជិកផ្សេងទៀត តាមរយៈម៉ូដទី៣៖ វត្តមានពាណិជ្ជកម្ម ដូចបានកំណត់ក្នុងមាត្រា១ (វិសាលភាព) នៃឧបសម្ព័ន្ធនេះ វៀរលែងតែមានចែងផ្ទុយពីនេះនៅក្នុងតារាងវិធានការបដិលោម បើទោះជាផ្អែកលើមូលដ្ឋាននៃផ្នែកណាមួយរបស់តំបន់ឬផ្អែកលើមូលដ្ឋាននៃដែនដីទាំងមូលរបស់ខ្លួនក្តី រដ្ឋសមាជិកមួយមិនត្រូវរក្សាទុកឬអនុម័តនូវវិធានការនានាដែលជា៖

[៩] រដ្ឋសមាជិកមួយប្តេជ្ញាចិត្តដើម្បីអនុញ្ញាតចំពោះការផ្ទេរមូលធនទៅក្នុងដែនដីរបស់ខ្លួន ប្រសិនបើការផ្ទេរមូលធននោះពាក់ព័ន្ធនឹងការសន្យាបើកច្រកចូលទីផ្សាររបស់ខ្លួន ពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុក្រោមជំពូកនេះ។

១. ការដាក់កំណត់ទៅលើ៖

(ក) ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុ ទោះជាក្នុងទម្រង់កូតាចំនួន ភាពផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ខ) តម្លៃសរុបនៃប្រតិបត្តិការសេវាកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្ម ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(គ) ចំនួនសរុបនៃការប្រតិបត្តិសេវាកម្មហិរញ្ញវត្ថុ ឬបរិមាណសរុបនៃទិន្នផលសេវាកម្មហិរញ្ញវត្ថុគិតជាឯកតាលេខដែលបានរៀបចំឡើងក្នុងទម្រង់ជាកូតា ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច[10]

(ឃ) ចំនួនសរុបនៃរូបវន្តបុគ្គល ដែលអាចនឹងត្រូវបានជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុជាក់លាក់ណាមួយ ឬដែលគ្រឹះស្ថានហិរញ្ញវត្ថុអាចនឹងជួលមកធ្វើការ ហើយជាបុគ្គលដែលចាំបាច់សម្រាប់ និងដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹង ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុជាក់លាក់មួយ ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ង) ការរួមចំណែកនៃមូលធនបរទេស ក្នុងទម្រង់ជាអត្រាភាគរយអតិបរមាដែលអនុញ្ញាតចំពោះភាគទុនបរទេស ឬតម្លៃសរុបនៃការវិនិយោគបរទេសជាលក្ខណៈបុគ្គល ឬជាលក្ខណៈរួម។

២. រឹតត្បិតឬតម្រូវចំពោះប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះទុន ដែលតាមរយៈវិធានការទាំងនោះ ទើបគ្រឹះស្ថានហិរញ្ញវត្ថុអាចផ្គត់ផ្គង់សេវាកម្មណាមួយបាន។

## មាត្រា១៤
## ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន[11]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាត ដោយស្ថិតក្រោមខចែងនិងលក្ខខណ្ឌនានាដែលផ្តល់នូវប្រព្រឹត្តិកម្មជាតិ ឱ្យអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀតដើម្បី

[10] កថាខណ្ឌ១(គ) មិនគ្របដណ្តប់លើវិធានការនានារបស់រដ្ឋសមាជិក ដែលដាក់កំណត់លើធាតុចូលសម្រាប់ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឡើយ។

[11] ដើម្បីឱ្យកាន់តែច្បាស់ មាត្រានេះនឹងអនុវត្តនៅពេលដែលធ្វើការផ្ទេរទៅជាវិធីសាស្ត្របញ្ជីអវិជ្ជមាន។ តារាងវិធានការបដិលោមសម្រាប់វិស័យសេវាកម្មហិរញ្ញវត្ថុ យោងតែទៅលើមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) នៃកិច្ចព្រមព្រៀងនេះ និងមាត្រា១៣ (ប្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ) និងមាត្រា១៤ (ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន) នៃឧបសម្ព័ន្ធនេះប៉ុណ្ណោះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

ផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធស្ដីពី (ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន)។[12]

២. រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យបុគ្គលដែលមានទីតាំងក្នុងដែនដីរបស់ខ្លួន និងជនជាតិរបស់ខ្លួនដែលមានទីតាំងនៅទីណាក៏ដោយ ដើម្បីទិញសេវាកម្មហិរញ្ញវត្ថុពីអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀត ដែលមានទីតាំងនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយក្រៅពីរដ្ឋសមាជិកដែលធ្វើការអនុញ្ញាត។ កាតព្វកិច្ចនេះមិនតម្រូវអោយរដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់ទាំងនោះ ដើម្បីធ្វើអាជីវកម្មឬជំរុញលើកទឹកចិត្តឱ្យធ្វើអាជីវកម្មនៅក្នុងដែនដីរបស់ខ្លួនឡើយ។ រដ្ឋសមាជិកអាចកំណត់និយមន័យ "ការធ្វើអាជីវកម្ម" និង "ការជំរុញលើកទឹកចិត្តឱ្យធ្វើអាជីវកម្ម" សម្រាប់គោលបំណងនៃកាតព្វកិច្ចនេះ ប្រសិនបើនិយមន័យទាំងនោះមិនអសង្គតិភាពទៅនឹងកថាខណ្ឌ១។

៣. ដោយពុំប៉ះពាល់វិធានការនានានៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រុងប្រយ័ត្ន ចំពោះការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន រដ្ឋសមាជិកមួយអាចតម្រូវឱ្យមានការចុះបញ្ជី ឬការផ្តល់អាជ្ញាប័ណ្ណ ចំពោះអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀត និងចំពោះឧបករណ៍ហិរញ្ញវត្ថុ។

## មាត្រា១៥
## វត្ថុមានក្នុងស្រុក

មាត្រា៩ (វត្ថុមានក្នុងស្រុក) នៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឡើយ។

12 ពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន ដែលផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុណាមួយដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធស្ដីពី (ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន) របស់រដ្ឋសមាជិកមួយ ហើយប្រសិនបើបន្លាស់ទីមូលធនឆ្លងកាត់ព្រំដែនគឺជាផ្នែកមានសារៈសំខាន់មួយនៃសេវាកម្មនោះផ្ទាល់ រដ្ឋសមាជិកនោះសន្យាអនុញ្ញាតចំពោះបន្លាស់ទីមូលធនបែបនោះ។

# ឧបសម្ព័ន្ធស្តីពីសេវាកម្មទូរគមនាគមន៍

## មាត្រា១
## វិសាលភាព

១. ឧបសម្ព័ន្ធនេះ ត្រូវអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មលើបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ។

២. ឧបសម្ព័ន្ធនេះមិនត្រូវអនុវត្តចំពោះវិធានការនានាដែលពាក់ព័ន្ធនឹងសេវាសោតទស្សន៍ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់រដ្ឋសមាជិកនីមួយៗឡើយ។

៣. ពុំមានអ្វីនៅក្នុងឧបសម្ព័ន្ធនេះត្រូវបានបកស្រាយ ដើម្បី៖

(ក) តម្រូវឱ្យរដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយផ្សេងទៀត បង្កើត កសាង ជាវ ជួល ប្រតិបត្តិការ ឬផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍ឡើយ វៀរលែងតែមានចែងផ្ទុយពីនេះដោយអាស្រ័យទៅនឹងតារាងវិធានការបដិសេធរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ខ) តម្រូវឱ្យរដ្ឋសមាជិកមួយ (ឬតម្រូវឱ្យរដ្ឋសមាជិកដាក់កាតព្វកិច្ចលើអ្នកផ្គត់ផ្គង់សេវាកម្មក្រោមយុត្តាធិការរបស់ខ្លួន) បង្កើត កសាង ជាវ ជួល ប្រតិបត្តិការ ឬផ្គត់ផ្គង់នូវបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍ដែលមិនត្រូវបានផ្តល់ជូនជាសាធារណៈ។

## មាត្រា២
## និយមន័យ

សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ វាក្យសព្ទ៖

(ក) "**និន្នាការថ្លៃដើម**" សំដៅដល់ ការយកថ្លៃដើមធ្វើជាគោល និងអាចរួមបញ្ចូលនូវផលចំណេញសមស្របមួយ ហើយអាចពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការគណនាថ្លៃដើមផ្សេងៗគ្នាចំពោះបរិក្ខារឬសេវាកម្មផ្សេងគ្នា។

(ខ) "**អ្នកប្រើប្រាស់ចុងក្រោយ**" សំដៅដល់ អ្នកជាវ ឬអ្នកប្រើប្រាស់ចុងក្រោយនូវបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ រួមទាំងអ្នកផ្គត់ផ្គង់សេវាកម្មណាមួយក្រៅពីអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ។

(គ) "**បរិក្ខារសារវន្ត**" សំដៅដល់ គ្រឿងបរិក្ខារទាំងឡាយនៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែល៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

(i) ត្រូវបានផ្តល់ផ្តាច់មុខឬយ៉ាងច្រើនលើសលប់ ដោយអ្នកផ្គត់ផ្គង់តែមួយ ឬដោយអ្នកផ្គត់ផ្គង់ក្នុងចំនួនមានកម្រិត និង

(ii) មិនអាចជំនួសបានតាមលក្ខណៈសេដ្ឋកិច្ចឬបច្ចេកទេស ដើម្បីផ្តល់សេវាកម្ម។

(ឃ) **"សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ"** សំដៅដល់ សេវាទូរស័ព្ទចល័តបែបពាណិជ្ជកម្ម ដែលត្រូវបានផ្តល់ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចុងក្រោយប្រើប្រាស់នូវទូរស័ព្ទចល័តឬឧបករណ៍ផ្សេងទៀតនៃប្រទេសដើម សម្រាប់សេវាជាសម្លេង ទិន្នន័យ ឬការផ្ញើសារ ខណៈដែលស្ថិតនៅក្រៅដែនដី ដែលបណ្តាញទូរគមនាគមន៍សាធារណៈនៃប្រទេសដើមរបស់អ្នកប្រើប្រាស់ចុងក្រោយនោះតាំងនៅ។

(ង) **"ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ"** សំដៅដល់ បរិវេណ[1] ដែលការតភ្ជាប់ប្រព្រឹត្តទៅជាមួយនឹងប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិណាមួយ ដូចដែលត្រូវបានកំណត់ដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ឬដោយអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលកាន់កាប់ឬគ្រប់គ្រងលើបរិវេណនោះ បើចាំបាច់។

(ច) **"បណ្តាញផ្ទួលជាវ"** សំដៅដល់ បរិក្ខារទូរគមនាគមន៍រវាងទីតាំងពីរឬច្រើន ដែលត្រូវបានរៀបចំជាលក្ខណៈដោយឡែកសម្រាប់ការប្រើប្រាស់ជាលក្ខណៈផ្តាច់មុខ ឬរៀបចំឱ្យមានភាពទំនេរអាចប្រើប្រាស់បាន សម្រាប់អ្នកប្រើប្រាស់ជាក់លាក់។

(ឆ) **"អ្នកផ្គត់ផ្គង់មេ"** សំដៅដល់ អ្នកផ្គត់ផ្គង់ដែលមានសមត្ថភាពធ្វើឱ្យជះឥទ្ធិពលខ្លាំងដល់លក្ខខណ្ឌនៃការចូលរួម ដោយពាក់ព័ន្ធទៅនឹងថ្លៃនិងការផ្គត់ផ្គង់នៅក្នុងទីផ្សារពាក់ព័ន្ធចំពោះបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលបណ្តាលមកពី៖

(i) ការគ្រប់គ្រងលើបរិក្ខារសារវន្ត ឬ

(ii) ការប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងទីផ្សារ

(ជ) **"ភាពមិនរើសអើង"** សំដៅដល់ ប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនតិចជាងប្រព្រឹត្តិកម្មដែលត្រូវបានផ្តល់ជូនអ្នកប្រើប្រាស់ផ្សេងទៀតណាមួយ នៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈដូចគ្នា ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា។

---

[1] អាស្រ័យលើប្រទេសនៃស្ថានីយ៍ ស្ថានីយ៍អាចរួមបញ្ចូលទាំងចំណុចចូលដំណើរការដែលបានកំណត់ផ្សេងទៀត។

(ឈ) "ទិន្នន័យឯកជន" សំដៅដល់ រាល់ព័ត៌មានទាំងឡាយណា អំពីរូបវន្តបុគ្គលដែលមានអត្តសញ្ញាណឬដែលអាចកំណត់អត្តសញ្ញាណបាន។

(ញ) "បណ្ដាញទូរគមនាគមន៍សាធារណៈ" សំដៅដល់ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សាធារណៈ ដែលអនុញ្ញាតចំពោះទូរគមនាគមន៍រវាងនិងក្នុងចំណោមទីតាំងបញ្ចប់នៃបណ្ដាញដែលបានកំណត់។

(ដ) "សេវាទូរគមនាគមន៍សាធារណៈ" សំដៅដល់ សេវាទូរគមនាគមន៍ទាំងឡាយណា ដែលត្រូវបានតម្រូវយ៉ាងច្បាស់លាស់ឬមានជាធរមាន ដោយរដ្ឋសមាជិកមួយដើម្បីឱ្យផ្ដល់ជូនជាទូទៅដល់សាធារណៈ។ សេវាទាំងនោះអាចរួមបញ្ចូលនូវ ការបញ្ជូនទូរលេខ ទូរស័ព្ទ តេឡិច និងការបញ្ជូនទិន្នន័យ *ជាដើម* ដែលជាទូទៅពាក់ព័ន្ធនឹងការបញ្ជូនព័ត៌មានដែលផ្ដល់ដោយអតិថិជន រវាងទីតាំងកំណត់ពីរឬច្រើន ដោយពុំមានការផ្លាស់ប្ដូរទម្រង់ឬមាតិកានៃព័ត៌មានរបស់អតិថិជនពីចុងម្ខាងទៅចុងម្ខាងឡើយ។

(ឋ) "ទូរគមនាគមន៍" សំដៅដល់ ការបញ្ជូននិងការទទួលរលកសញ្ញាក្នុងទម្រង់អេឡិកត្រូម៉ាញ៉េទិក។

(ឌ) "អង្គភាពនិយ័តកម្មទូរគមនាគមន៍" សំដៅដល់ អង្គភាពឬបណ្ដាអង្គភាពនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ដែលទទួលខុសត្រូវនៅក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់រដ្ឋសមាជិកនោះ សម្រាប់ការធ្វើនិយ័តកម្មទូរគមនាគមន៍ និង

(ឍ) "អ្នកប្រើប្រាស់" សំដៅដល់ អ្នកប្រើប្រាស់ចុងក្រោយ ឬអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ និងសេវាទូរគមនាគមន៍សាធារណៈ។

## មាត្រា៣
## សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាកម្មណាមួយនៃរដ្ឋសមាជិកផ្សេងទៀតទទួលបានសិទ្ធិចូលប្រើប្រាស់ និងការប្រើប្រាស់បណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ក្នុងខចែងនិងលក្ខខណ្ឌទាន់ពេលវេលា តម្លាភាព សមហេតុផល និងមិនរើសអើង វៀរលែងតែមានភាពផ្ទុយពីនេះដោយអាស្រ័យទៅនឹងតារាងវិធានការបដិលោមរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ។ កាតព្វកិច្ចនេះត្រូវអនុវត្តតាមរយៈកថាខណ្ឌ២ ដល់ ៦ *ជាដើម*។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតមានសិទ្ធិចូលប្រើប្រាស់ និងការប្រើប្រាស់បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈដែលផ្ដល់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការ៖ | https://t.me/oa_channel

នៅក្នុងដែនដីឬឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកនោះ រួមបញ្ចូលទាំង បណ្ដាញជួលជាវឯកជន ហើយក្នុងន័យនេះ ដោយអាស្រ័យទៅនឹងប្រការនានានៃកថាខណ្ឌ៥ និង ៦ ត្រូវធានាថា អ្នកផ្គត់ផ្គង់បែបនេះត្រូវបានអនុញ្ញាតឱ្យ៖

(ក) ទិញ ឬជួល និងបំពាក់បរិក្ខារចុងបណ្ដាញឬបរិក្ខារដទៃទៀត ដែលភ្ជាប់ទៅវិញទៅមក ជាមួយនឹងបណ្ដាញ និងដែលចាំបាច់ដើម្បីផ្គត់ផ្គង់សេវាកម្មរបស់ខ្លួន

(ខ) តភ្ជាប់ទៅវិញទៅមកនូវបណ្ដាញជួលជាវឯកជនឬបណ្ដាញកម្មសិទ្ធិផ្ទាល់ខ្លួន ជាមួយ នឹងបណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ឬភ្ជាប់ជាមួយនឹងបណ្ដាញ ជួលជាវឬបណ្ដាញកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកផ្គត់ផ្គង់សេវាកម្មផ្សេងទៀត និង

(គ) ប្រើប្រាស់ប្រូតូកូលនៃប្រព័ន្ធដំណើរការតាមជម្រើសផ្ទាល់ខ្លួន ក្នុងការផ្គត់ផ្គង់សេវាកម្ម ណាមួយ ដែលជាជម្រើសផ្សេងៗទៅតាមការចាំបាច់ ដើម្បីធានាពីភាពមានរួចរាល់នូវ បណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍ ដើម្បីផ្ដល់ជាទូទៅដល់សាធារណៈ។

៣. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតអាចប្រើប្រាស់ បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ សម្រាប់ការបញ្ជូនទីព័ត៌មាននៅក្នុង ប្រទេសឬឆ្លងកាត់ព្រំដែន រាប់បញ្ចូលទាំងការប្រាស្រ័យទាក់ទងផ្ទៃក្នុងក្រុមហ៊ុននៃអ្នកផ្គត់ផ្គង់ សេវាកម្មនោះ និងសម្រាប់សិទ្ធិចូលប្រើប្រាស់ព័ត៌មានរក្សាទុកក្នុងមូលដ្ឋានទិន្នន័យ ឬដែល ក្រៅពីនេះ រក្សាទុកនៅក្នុងទម្រង់ដែលអាចអានបានដោយម៉ាស៊ីនកុំព្យូទ័រ នៅក្នុងដែនដីនៃ រដ្ឋសមាជិកណាមួយ។

៤. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ៣ រដ្ឋសមាជិកមួយអាចអនុវត្តនូវវិធានការនានា តាមការចាំបាច់ ដើម្បី៖

(ក) ធានាឱ្យបាននូវសន្តិសុខនិងការសម្ងាត់របស់សារ ឬ

(ខ) ការពារនូវទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់ចុងក្រោយ នៃបណ្ដាញទូរគមនាគមន៍ឬសេវា ទូរគមនាគមន៍សាធារណៈ

ប្រសិនបើ វិធានការទាំងនោះពុំត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលបង្កឱ្យមាននូវការរើសអើង តាមអំពើចិត្តឬមិនសមហេតុផល ឬការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្ម។

៥. រដ្ឋសមាជិកនីមួយៗត្រូវធានាថា ពុំមានលក្ខខណ្ឌណាមួយត្រូវបានដាក់បន្ទុកទៅលើសិទ្ធិចូល ប្រើប្រាស់និងការប្រើប្រាស់បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្រៅពី ការចាំបាច់ដើម្បី៖

(ក) ការពារភាពទទួលខុសត្រូវផ្នែកសេវាសាធារណៈរបស់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ ឬសេវាទូរគមនាគមន៍សាធារណៈ ជាពិសេសលើលទ្ធភាពរបស់ពួកគេក្នុងការបង្កើតនូវបណ្តាញឬសេវារបស់ខ្លួន ដែលមានរួចរាល់សម្រាប់ផ្តល់ជាទូទៅដល់សាធារណៈ ឬ

(ខ) ការពារភាពពេញលេញឥតចន្លោះផ្នែកបច្ចេកទេស នៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ។

៦. ប្រសិនបើពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងកថាខណ្ឌ៥ លក្ខខណ្ឌនានាសម្រាប់សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ រួមមាន៖

(ក) តម្រូវការក្នុងការប្រើប្រាស់ដែនតភ្ជាប់បច្ចេកទេសដែលជាក់លាក់ រួមទាំងប្រូតូកូលនៃដែនតភ្ជាប់ សម្រាប់ការតភ្ជាប់បណ្តាញជាមួយបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ

(ខ) តម្រូវការនានាតាមការចាំបាច់ សម្រាប់ការបំពេញប្រតិបត្តិការរវាងគ្នាទៅវិញទៅមកនៃសេវាទូរគមនាគមន៍សាធារណៈ និងដើម្បីលើកទឹកចិត្តចំពោះសមិទ្ធផលនៃគោលដៅដូចមានចែងក្នុងមាត្រា១៧ (ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ)

(គ) លិខិតអនុញ្ញាតចំពោះប្រភេទនៃបរិធានទូរគមនាគមន៍ឬឧបករណ៍ផ្សេងទៀត ដែលអាចតភ្ជាប់ជាមួយនឹងបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ព្រមទាំងតម្រូវការបច្ចេកទេសពាក់ព័ន្ធនឹងការភ្ជាប់នៃគ្រឿងបរិក្ខារទាំងនោះទៅនឹងបណ្តាញ

(ឃ) ការរឹតត្បិតលើការតភ្ជាប់បណ្តាញទៅវិញទៅមកនៃបណ្តាញជួលជាឯកជនឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួន ជាមួយនឹងបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ឬក៏ជាមួយនឹងបណ្តាញជួលជាឯកជនឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកផ្គត់ផ្គង់សេវាកម្មផ្សេងទៀត ឬ

(ង) ការជូនដំណឹង ការអនុញ្ញាត ការចុះបញ្ជី និងការផ្តល់អាជ្ញាប័ណ្ណ។

## មាត្រា៤
## លេខទូរគមនាគមន៍ដែលអាចកាន់កាប់បានដោយអ្នកប្រើប្រាស់

រដ្ឋសមាជិកនីមួយៗត្រូវខិតខំធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៅក្នុងដែនដីរបស់ខ្លួន ផ្តល់លេខទូរគមនាគមន៍ដែលអាចកាន់កាប់បានដោយអ្នកប្រើប្រាស់សម្រាប់សេវាទូរស័ព្ទចល័ត ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ឱ្យបានតាមលទ្ធភាពដែលអាចធ្វើទៅបានទាំងផ្នែកបច្ចេកទេសនិងផ្នែកសេដ្ឋកិច្ច ដោយផ្អែកលើមូលដ្ឋានទាន់ពេលវេលា និងក្នុងលក្ខខណ្ឌសមហេតុផល។

គេហទំព័រ ឯកសារច្បាប់សាធារណៈ | https://t.me/oa_channel

## មាត្រា៥
## ការការពារភាពប្រកួតប្រជែង[2]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុម័តឬរក្សានូវវិធានការសមស្របនានា សម្រាប់គោលបំណងក្នុងការទប់ស្កាត់អ្នកផ្គត់ផ្គង់ដែលមានតែមួយឬអ្នកផ្គត់ផ្គង់ច្រើនរួមគ្នា ដែលចាត់ទុកជាអ្នកផ្គត់ផ្គង់មេ ពីការចូលរួមនៅក្នុងឬកំពុងបន្តការអនុវត្តដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង។

២. ការអនុវត្តដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ដូចមានចែងនៅក្នុងកថាខណ្ឌ១ ជាពិសេស រួមមានៈ

(ក) ការចូលរួមនៅក្នុងការឧបត្ថម្ភធនដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង

(ខ) ការប្រើប្រាស់ព័ត៌មានដែលទទួលបានពីគូប្រកួតប្រជែង បង្កជាលទ្ធផលដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង និង

(គ) ពុំផ្តល់លទ្ធភាពដល់អ្នកផ្គត់ផ្គង់ផ្សេងទៀតនៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងការទទួលបានព័ត៌មានបច្ចេកទេសពាក់ព័ន្ធនឹងបរិក្ខារសារវន្តនិងព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មឱ្យបានទាន់ពេលវេលា ដែលព័ត៌មានទាំងនោះចាំបាច់សម្រាប់ពួកគេក្នុងការផ្គត់ផ្គង់សេវាកម្ម។

## មាត្រា៦
## ប្រព្រឹត្តិកម្មដោយអ្នកផ្គត់ផ្គង់មេ

រដ្ឋសមាជិកនីមួយៗត្រូវធានាថា ដោយស្ថិតក្នុងស្ថានភាពដូចគ្នា អ្នកផ្គត់ផ្គង់មេក្នុងដែនដីរបស់ខ្លួនផ្តល់ដល់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងប្រព្រឹត្តិកម្ម ដែលអ្នកផ្គត់ផ្គង់មេនោះផ្តល់ដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធនិងក្រុមហ៊ុនសាខារបស់ខ្លួន ឬអ្នកផ្គត់ផ្គង់សេវាកម្មដែលមិនមែនជាក្រុមហ៊ុនសាខារបស់ខ្លួនផ្សេងទៀត ពាក់ព័ន្ធនឹងៈ

(ក) ភាពអាចរកបាន ការផ្តល់ជូន អត្រាតម្លៃ ឬគុណភាព នៃសេវាទូរគមនាគមន៍ដូចគ្នា[3] និង

(ខ) ភាពអាចរកបាននៃដែនតភ្ជាប់បច្ចេកទេសដែលចាំបាច់សម្រាប់ការតភ្ជាប់បណ្តាញ។

---

[2] កម្ពុជា និងឡាវ ពន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
[3] ឥណ្ឌូនេស៊ី ពន្យាក្នុងការអនុវត្តអនុកថាខណ្ឌនេះនៅចុងឆ្នាំ២០២០។

## មាត្រា៧
## ការលក់បន្ត[4]

រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តល់ផ្តង់មេទាំងឡាយនៅក្នុងដែនដីរបស់ខ្លួនមិនដាក់លក្ខខណ្ឌ ឬការរឹតត្បិតនានាដែលមិនសមហេតុផល ឬរើសអើង ចំពោះការលក់បន្តនៃសេវាទូរគមនាគមន៍សាធារណៈ ដោយអ្នកផ្តល់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត។

## មាត្រា៨
## ការតភ្ជាប់បណ្តាញ[5]

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តល់ផ្គង់បណ្តាញទូរគមនាគមន៍សាធារណៈនៅក្នុងដែនដីរបស់ខ្លួន ផ្តល់ការតភ្ជាប់បណ្តាញដល់អ្នកផ្តល់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ទៅតាមវិសាលភាពដូចមានកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តល់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តនៅក្នុងដែនដីរបស់ខ្លួន ផ្តល់នូវការតភ្ជាប់បណ្តាញ សម្រាប់បរិធាននិងឧបករណ៍របស់អ្នកផ្តល់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត នៅទីតាំងណាមួយដែលអាចប្រព្រឹត្តទៅបានតាមលក្ខណៈបច្ចេកទេសនៅក្នុងបណ្តាញនោះ។ ការតភ្ជាប់បណ្តាញបែបនេះត្រូវបានផ្តល់ដោយ៖

(ក) ស្ថិតក្រោម ខចែង លក្ខខណ្ឌនានា (រួមទាំងស្តង់ដានិងភាពលម្អិតផ្នែកបច្ចេកទេស) និងអត្រាតម្លៃនិងគុណភាព ដែលមិនរើសអើង ហើយដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលត្រូវបានផ្តល់ចំពោះសេវាកម្មដូចគ្នារបស់ខ្លួន ឬចំពោះសេវាកម្មដូចគ្នារបស់អ្នកផ្តល់ផ្គង់សេវាកម្មដែលមិនមែនជាក្រុមហ៊ុនសាខារបស់ខ្លួន ឬចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនសាខារបស់ខ្លួន

(ខ) ស្ថិតក្នុងភាពទាន់ពេលវេលា និងអាស្រ័យលើ ខចែង លក្ខខណ្ឌនានា (រួមទាំងស្តង់ដានិងភាពលម្អិតផ្នែកបច្ចេកទេស) និងអត្រាតម្លៃដែលផ្អែកលើនិន្នាការថ្លៃដើម ដែលមាន

---

[4] ព្រុយណេ អាចទាមទារឱ្យអ្នកមានអាជ្ញាបណ្ណ ដែលទិញសេវាទូរគមនាគមន៍សាធារណៈផ្អែកលើមូលដ្ឋានលក់ដុំ លក់បន្តនូវសេវាកម្មរបស់ខ្លួនចំពោះតែអ្នកប្រើប្រាស់ចុងក្រោយប៉ុណ្ណោះ។

[5] [illegible] សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

[illegible] សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

[illegible]ណាម សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០។

[illegible] សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តេលេក្រាម ឯកសារច្បាប់សាធារណៈ | https://t.me/oa_channel

តម្លាភាព សមហេតុផល អាស្រ័យលើលទ្ធភាពសេដ្ឋកិច្ច និងលាតត្រដាងគ្រប់គ្រាន់ ហើយដែលអាស្រ័យហេតុនេះ អ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ពុំចាំបាច់ទូទាត់ចំណាយចំពោះគ្រឿងបង្គុំឬបរិក្ខារដែលខ្លួនមិនត្រូវការជាចាំបាច់សម្រាប់ការផ្ដល់សេវាកម្មឡើយ និង

(គ) ផ្អែកតាមការស្នើសុំ ចំពោះបណ្ដាទីតាំងបន្ថែមទៅលើទីតាំងចុងបណ្ដាញ ដែលត្រូវបានផ្ដល់ដល់អ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈភាគច្រើន គឺជាកម្មវត្ថុនៃការគិតថ្លៃដែលឆ្លុះបញ្ចាំងថ្លៃដើមនៃការបំពាក់បរិក្ខារចាំបាច់បន្ថែម។

៣. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចធ្វើការតភ្ជាប់បណ្ដាញបរិក្ខារនិងឧបករណ៍របស់ពួកគេជាមួយអ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តនៅក្នុងដែនដីរបស់ខ្លួន ដោយអនុលោមតាមជម្រើសយ៉ាងតិចមួយក្នុងចំណោមជម្រើសខាងក្រោមៈ

(ក) សេចក្ដីយោងស្ដីពីការតភ្ជាប់បណ្ដាញដែលអនុម័តដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍របស់រដ្ឋសមាជិកនោះ ដោយក្នុងនោះមានអត្រាតម្លៃ ខចែង និងលក្ខខណ្ឌនានា ដែលអ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្ត ផ្ដល់ជូនជាទូទៅដល់អ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈ

(ខ) ខចែងនិងលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងស្ដីពីការតភ្ជាប់បណ្ដាញដែលមានស្រាប់ ឬ

(គ) កិច្ចព្រមព្រៀងស្ដីពីការតភ្ជាប់បណ្ដាញថ្មីតាមរយៈការចរចាពាណិជ្ជកម្ម។

៤. រដ្ឋសមាជិកនីមួយៗត្រូវធានាថា នីតិវិធីអនុវត្តសម្រាប់ការតភ្ជាប់បណ្ដាញទៅនឹងអ្នកផ្គត់ផ្គង់មេ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

៥. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេនៅក្នុងដែនដីរបស់ខ្លួន ត្រូវធ្វើយ៉ាងណាឱ្យកិច្ចព្រមព្រៀងស្ដីពីការតភ្ជាប់បណ្ដាញ ឬសំណើកិច្ចព្រមព្រៀងស្ដីពីការតភ្ជាប់ដែលត្រូវផ្ដល់ អាចស្វែងរកបានជាសាធារណៈ។

៦. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តមិនប្រើប្រាស់ឬផ្ដល់នូវព័ត៌មានរសើបឬព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម អំពីអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ ឬសេវាទូរគមនាគមន៍សាធារណៈ ឬអំពីអ្នកប្រើប្រាស់ចុងក្រោយ ដែលទទួលបានតាមរយៈការធ្វើធុរកិច្ចលើការតភ្ជាប់បណ្ដាញរបស់ខ្លួន ជាមួយនឹងបរិក្ខារទូរគមនាគមន៍របស់អ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងគោលដៅផ្សេងក្រៅពីការធ្វើធុរកិច្ចលើការតភ្ជាប់បណ្ដាញឡើយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## មាត្រា៩
## ការផ្ដល់និងការកំណត់ថ្លៃសេវាកម្មបណ្ដាញជួលដាច់[6]

រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តនៅក្នុងដែនដីរបស់ខ្លួន ផ្ដល់ដល់អ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈរបស់រដ្ឋសមាជិកផ្សេងទៀត នូវសេវាកម្មបណ្ដាញជួលដាច់ដែលជាបណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងលក្ខខណ្ឌនិងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង និងតម្លាភាព។

## មាត្រា១០
## សហទីតាំង[7]

ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តក្នុងដែនដីរបស់ខ្លួន អនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចដំឡើងបរិក្ខាររបស់ពួកគេនៅក្នុងអគាររបស់អ្នកផ្គត់ផ្គង់មេ ស្របតាមខចែងនិងលក្ខខណ្ឌនានា រួមមាន លទ្ធភាពផ្នែកបច្ចេកទេសនិងភាពទំនេរនៃទីតាំងក្នុងករណីដែលអាចអនុវត្តទៅបាន និងស្ថិតក្នុងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង(រួមបញ្ចូលទាំងពេលវេលាសមស្រប) និងតម្លាភាព។

## មាត្រា១១
## អង្គភាពនិយ័តកម្មទូរគមនាគមន៍ឯករាជ្យ

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អង្គភាពនិយ័តកម្មទូរគមនាគមន៍របស់ខ្លួន គឺស្ថិតនៅដាច់ដោយឡែកពី និងពុំជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះមុខអ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈណាមួយឡើយ។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា សេចក្ដីសម្រេចចិត្តនិងនីតិវិធីដែលប្រើប្រាស់ដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍របស់ខ្លួន គឺមិនលម្អៀងចំពោះរាល់អ្នកចូលរួមក្នុងទីផ្សារ។

---

[6] កម្ពុជា សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។
វៀតណាម សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០ ។

[7] កម្ពុជា សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។
ថៃ សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
វៀតណាម សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តេលេក្រាម ឯកសារសៀវភៅសាធារណៈ | https://t.me/oa_channel

## មាត្រា១២
## សេវាសកល

រដ្ឋសមាជិកនីមួយៗមានសិទ្ធិដើម្បីកំណត់នូវប្រភេទនៃកាតព្វកិច្ចសេវាសកល ដែលខ្លួនមានបំណងរក្សាទុក។ កាតព្វកិច្ចបែបនេះមិនត្រូវបានចាត់ទុកជាការប្រឆាំងនឹងការប្រកួតប្រជែងឡើយ ប្រសិនបើកាតព្វកិច្ចទាំងនោះត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព មិនរើសអើង និងមានលក្ខណៈប្រកួតប្រជែងដោយអព្យាក្រឹត្យ ហើយមិនបានដាក់បន្ទុកលើសពីភាពចាំបាច់ចំពោះប្រភេទនៃសេវាសកលដែលកំណត់ដោយរដ្ឋសមាជិកនោះ។

## មាត្រា១៣
## ការផ្តល់អាជ្ញាប័ណ្ណ[8]

១. ករណីដែលអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត ត្រូវបានតម្រូវឱ្យមានសម្រាប់ការផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ នោះរដ្ឋសមាជិកនីមួយៗត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវ៖

(ក) លក្ខណៈវិនិច្ឆ័យនិងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ ឬការអនុញ្ញាតផ្សេងទៀត និងរយៈពេលដែលត្រូវការជាធម្មតាដើម្បីផ្តល់សេចក្តីសម្រេចចិត្តលើពាក្យស្នើសុំអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត និង

(ខ) ខចែង និងលក្ខខណ្ឌនានានៃអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត បែបឯកត្តជន ដែលខ្លួនបានដាក់ចេញរួច។[9]

២. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិកមួយ ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីលទ្ធផលនៃពាក្យស្នើសុំរបស់ខ្លួនដោយពុំមានការពន្យារពេលបន្ទាប់ពីមានសេចក្តីសម្រេចចិត្ត។ ករណីសេចក្តីសម្រេចចិត្តបដិសេធចំពោះពាក្យស្នើសុំអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិកនោះត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីមូលហេតុនៃការបដិសេធ ស្របតាមការស្នើសុំ។

## មាត្រា១៤
## ការបែងចែកនិងការប្រើប្រាស់ធនធានកម្រ[10]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុវត្តនីតិវិធីរបស់ខ្លួនក្នុងការបែងចែកនិងការប្រើប្រាស់ធនធានកម្រដែលពាក់ព័ន្ធនឹងទូរគមនាគមន៍ រួមបញ្ចូលទាំង ហ្វ្រេកង់ស៍ និងក្បាលលេខទូរគមនាគមន៍ ក្នុងលក្ខណៈមួយដែលមានសត្យានុម័ត ទាន់ពេលវេលា តម្លាភាព និងមិនរើសអើង។

---

[8] កម្ពុជា៖ សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

[9] ដើម្បីឲ្យកាន់តែច្បាស់ ខចែងនិងលក្ខខណ្ឌនានាអាចនឹងមិនរាប់បញ្ចូលនូវខចែងនិងលក្ខខណ្ឌជាក់លាក់នៃអ្នកមានអាជ្ញាបណ្ណ ដែលជាព័ត៌មានសម្ងាត់។

[10] កម្ពុជា៖ សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២. រដ្ឋសមាជិកនីមួយៗត្រូវផ្សព្វផ្សាយជាសាធារណៈ អំពីស្ថានភាពបច្ចុប្បន្ននៃការបែងចែកបន្ទាត់ហ្វ្រេកង់ស៍ ប៉ុន្តែមិនត្រូវបានទាមទារឱ្យផ្តល់ព័ត៌មានអំពីអត្តសញ្ញាណលម្អិតនៃហ្វ្រេកង់ស៍ដែលត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ជាក់លាក់ក្នុងគោលដៅរបស់រដ្ឋាភិបាលឡើយ។

៣. វិធានការរបស់រដ្ឋសមាជិកមួយ ក្នុងការបែងចែកនិងផ្តល់ការប្រើប្រាស់វិសាលគមន៍ហ្វ្រេកង់ស៍និងការគ្រប់គ្រងហ្វ្រេកង់ស៍ មិនមែនជាវិធានការដែលអសង្គតិភាពនឹងមាត្រា៨ (ច្រកចូលទីផ្សារ) នៃកិច្ចព្រមព្រៀងនេះឡើយ។ ក្នុងន័យនេះ រដ្ឋសមាជិកនីមួយៗរក្សានូវសិទ្ធិក្នុងការបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងវិសាលគមន៍និងហ្វ្រេកង់ស៍ ដែលអាចជះឥទ្ធិពលចំពោះការកម្រិតចំនួននៃអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ប្រសិនបើការកម្រិតនោះមានសង្គតិភាពទៅនឹងប្រការនានានៃកិច្ចព្រមព្រៀងនេះ។ សិទ្ធិបែបនោះ រួមមានលទ្ធភាពក្នុងការបែងចែងបន្ទាត់ហ្វ្រេកង់ស៍ ដោយពិចារណាលើតម្រូវការបច្ចុប្បន្ននិងអនាគតនិងភាពទំនេរនៃវិសាលគមន៍។

## មាត្រា១៥
## តម្លាភាព

រដ្ឋសមាជិកនីមួយៗត្រូវធានាថា រាល់ព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនានាដែលជះឥទ្ធិពលដល់សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយរួមមាន តារាងតម្លៃ និងខចែងនិងលក្ខខណ្ឌនានានៃសេវាកម្មភាពលម្អិតផ្នែកបច្ចេកទេសនៃដែនតភ្ជាប់ជាមួយបណ្តាញនិងសេវាបែបនោះ ព័ត៌មានអំពីអង្គភាពនានាដែលទទួលខុសត្រូវចំពោះការរៀបចំនិងការអនុម័តស្តង់ដា ដែលជះឥទ្ធិពលលើសិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់ លក្ខខណ្ឌនានាដែលអនុវត្តចំពោះការបំពាក់បរិធានឬបរិក្ខារផ្សេងទៀត និងសេចក្តីជូនដំណឹង ការអនុញ្ញាត ការចុះបញ្ជី ឬការផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើមាន។

## មាត្រា១៦
## ការដោះស្រាយវិវាទទូរគមនាគមន៍

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចមានពេលវេលាសមស្របដើម្បីធ្វើឧបាស្រ័យទៅកាន់អង្គភាពនិយ័តកម្មទូរគមនាគមន៍របស់ខ្លួនឬអង្គភាពដោះស្រាយវិវាទ ដើម្បីដោះស្រាយវិវាទនានាដែលកើតឡើងក្រោមឧបសម្ព័ន្ធនេះ ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

២. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈណាមួយ ដែលរងនូវផលប៉ះពាល់ពីការកំណត់ឬសេចក្តីសម្រេចចិត្តរបស់អង្គភាពនិយ័តកម្មទូរគមនាគមន៍ពាក់ព័ន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តេលេក្រាម ឯកសារប្រើប្រាស់សាធារណៈ | https://t.me/oa_channel

របស់ខ្លួន អាចប្តឹងទាមទារឱ្យអង្គភាពនោះធ្វើការពិចារណាឡើងវិញអំពីការកំណត់ឬសេចក្តីសម្រេចចិត្តបែបនោះ។ ពុំមានរដ្ឋសមាជិកណាមួយត្រូវអនុញ្ញាតឱ្យមានបណ្តឹងទាមទារបែបនោះ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការមិនប្រតិបត្តិទៅតាមការកំណត់ឬសេចក្តីសម្រេចចិត្តរបស់អង្គភាពនិយ័តកម្មនោះឡើយ វៀរលែងតែអាជ្ញាធរមានសមត្ថកិច្ចព្យួរឬដកចេញនូវការកំណត់ ឬសេចក្តីសម្រេចចិត្តនោះ។

៣. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈណាមួយ ដែលរងការប៉ះពាល់ដោយការកំណត់ឬការសម្រេចចុងក្រោយរបស់អង្គភាពនិយ័តកម្មទូរគមនាគមន៍ពាក់ព័ន្ធរបស់ខ្លួន អាចស្នើសុំពិនិត្យឡើងវិញនូវការកំណត់ឬសេចក្តីសម្រេចនេះ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា១៧
## ទំនាក់ទំនងនឹងអង្គការអន្តរជាតិ

បណ្តារដ្ឋសមាជិកទទួលស្គាល់នូវសារៈសំខាន់នៃស្តង់ដាអន្តរជាតិសម្រាប់ភាពចុះសម្រុងគ្នាទូទាំងពិភពលោកនិងអន្តរប្រតិបត្តិការនៃបណ្តាញនិងសេវាទូរគមនាគមន៍ និងការទទួលរ៉ាប់រងដើម្បីជំរុញស្តង់ដានេះ តាមរយៈការងាររបស់ស្ថាប័នអន្តរជាតិពាក់ព័ន្ធ រួមមាន សហភាពទូរគមនាគមន៍អន្តរជាតិ និងអង្គការអន្តរជាតិសម្រាប់ស្តង់ដាជាដើម។

## មាត្រា១៨
## ទូរស័ព្ទរ៉ូមីងអន្តរជាតិ

១. បណ្តារដ្ឋជាសមាជិកត្រូវខិតខំព្យាយាមដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ស្តីពីការជំរុញអត្រាតម្លៃប្រកបដោយតម្លាភាពនិងសមហេតុផលសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ ដែលអាចនឹងជួយដល់ការជំរុញកំណើនពាណិជ្ជកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក និងលើកកម្ពស់សុខុមាលភាពអតិថិជន។

២. រដ្ឋសមាជិកអាចជ្រើសរើសនូវជំហាននានា ដើម្បីលើកកម្ពស់តម្លាភាពនិងភាពប្រកួតប្រជែងពាក់ព័ន្ធនឹងអត្រាតម្លៃសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ និងជម្រើសនៃបច្ចេកទេសផ្សេងពីសេវារ៉ូមីង ដូចជា៖

(ក) ការធានាព័ត៌មានពាក់ព័ន្ធនឹងអត្រាតម្លៃលក់រាយ គឺអាចស្វែងរកបានដោយងាយចំពោះអតិថិជន និង

(ខ) ការធ្វើអប្បបរមាកម្មលើឧបសគ្គចំពោះការប្រើប្រាស់ជម្រើសនៃបច្ចេកទេសផ្សេងពីសេវារ៉ូមីង ដែលករណីនេះ នៅពេលដែលអតិថិជនធ្វើដំណើរទៅក្នុងដែនដីនៃរដ្ឋសមាជិកមួយដោយចេញពីដែនដីនៃរដ្ឋសមាជិកផ្សេងទៀត អាចចូលប្រើប្រាស់បាននូវសេវាទូរគមនាគមន៍ដោយប្រើប្រាស់នូវឧបករណ៍តាមជម្រើសរបស់ខ្លួន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា រដ្ឋសមាជិកមួយអាចជ្រើសរើសដើម្បីជំរុញភាពប្រកួតប្រជែងពាក់ព័ន្ធនឹងអត្រាតម្លៃសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ រួមទាំង តាមរយៈកិច្ចរៀបចំពាណិជ្ជកម្មនានា ឬដើម្បីអនុម័តឬរក្សាទុកនូវវិធានការនានា ដែលជះឥទ្ធិពលដល់អត្រាតម្លៃសម្រាប់សេវារ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ក្នុងគោលបំណងធានានូវអត្រាតម្លៃដែលសមស្រប។ ប្រសិនបើរដ្ឋសមាជិកមួយយល់ថាសមហេតុផល រដ្ឋសមាជិកនោះអាចធ្វើកិច្ចសហប្រតិបត្តិការ និងអនុវត្តយន្តការនានាជាមួយនឹងបណ្តារដ្ឋសមាជិកផ្សេងទៀត ដើម្បីសម្រួលដល់ការអនុវត្តវិធានការទាំងនោះ រួមបញ្ចូលទាំង តែមិនកំណត់ តាមរយៈការឈានចូលទៅក្នុងកិច្ចរៀបចំណាមួយជាមួយនឹងបណ្តារដ្ឋសមាជិកទាំងនោះ។

៤. ប្រសិនបើរដ្ឋសមាជិកមួយ ("រដ្ឋសមាជិកទីមួយ") ជ្រើសរើសគ្រប់គ្រងអត្រាតម្លៃឬលក្ខខណ្ឌនានាសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ រដ្ឋសមាជិកនោះត្រូវធានាថាអ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ("រដ្ឋសមាជិកទីពីរ") មានលទ្ធភាពទទួលបាននូវអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំនោះ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ សម្រាប់អតិថិជនរបស់ខ្លួនដែលធ្វើដំណើរនៅក្នុងដែនដីនៃរដ្ឋសមាជិកទីមួយ ប្រសិនបើរដ្ឋសមាជិកទីពីរបានឈានចូលទៅក្នុងកិច្ចរៀបចំណាមួយជាមួយនឹងរដ្ឋសមាជិកទីមួយ ដើម្បីគ្រប់គ្រងអត្រាតម្លៃឬលក្ខខណ្ឌនានាតាមបែបបដិការ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ សម្រាប់អ្នកផ្គត់ផ្គង់របស់រដ្ឋសមាជិកទាំងពីរនោះ។[11] ថ្វីបើយ៉ាងនេះក៏ដោយ រដ្ឋសមាជិកទីមួយអាចនឹងតម្រូវឱ្យអ្នកផ្គត់ផ្គង់នៃរដ្ឋសមាជិកទីពីរ ប្រើប្រាស់ពេញលេញនូវវិធីសាស្ត្រនៃការចរចាផ្នែកពាណិជ្ជកម្មដើម្បីឈានដល់ការព្រមព្រៀងគ្នាលើខចែងនានាសម្រាប់ការទទួលបានអត្រាតម្លៃឬលក្ខខណ្ឌទាំងនោះ។

៥. រដ្ឋសមាជិកមួយដែលធានានូវលទ្ធភាពទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ដូចមានចែងក្នុងកថាខណ្ឌ៤ ត្រូវបានចាត់ទុកថាប្រតិបត្តិស្របទៅតាមមាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបាន

---

[11] ដើម្បីឱ្យកាន់តែច្បាស់៖

(ក) ពុំមានរដ្ឋសមាជិកណាមួយ ដោយពឹងផ្អែកតែម្យ៉ាងលើមូលដ្ឋាននៃកាតព្វកិច្ចនានាដែលដាក់ដោយរដ្ឋសមាជិកទីមួយក្រោមប្រការពាក់ព័ន្ធនឹងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ឬក្រោមប្រការពាក់ព័ន្ធនឹងការមិនរើសអើងដាក់លាក់ផ្នែកទូរគមនាគមន៍ ដែលនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិណាមួយ ត្រូវធ្វើការស្នើសុំឬទទួលបានសម្រាប់អ្នកផ្គត់ផ្គង់របស់ខ្លួន នូវលទ្ធភាពក្នុងការទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ដែលមានចែងនៅក្រោមមាត្រានេះឡើយ។

(ខ) លទ្ធភាពទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំដោយរដ្ឋសមាជិកទីមួយ ត្រូវប្រព្រឹត្តទៅបានសម្រាប់អ្នកផ្គត់ផ្គង់របស់រដ្ឋសមាជិកទីពីរ លុះត្រាតែអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំនោះគឺអាចប្រៀបធៀបគ្នាបានយ៉ាងសមស្របទៅនឹងអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំតាមបែបបដិការក្រោមកិច្ចរៀបចំនោះ។ ក្នុងករណីគ្មានការឯកភាពគ្នា អង្គភាពនិយ័តកម្មទូរគមនាគមន៍នៃរដ្ឋសមាជិកទីមួយត្រូវកំណត់ថាតើ អត្រាតម្លៃឬលក្ខខណ្ឌនានាបែបនោះគឺអាចប្រៀបធៀបគ្នាបានជាសមស្របដែរឬយ៉ាងណា។ សម្រាប់គោលបំណងនៃកំណត់សម្គាល់ជើងទំព័រនេះ អត្រាតម្លៃឬលក្ខខណ្ឌនានាដែលអាចប្រៀបធៀបគ្នាបានយ៉ាងសមស្រប សំដៅដល់ អត្រាតម្លៃឬលក្ខខណ្ឌនានាដែលត្រូវបានឯកភាពថាអាចប្រៀបធៀបគ្នាបានដោយអ្នកផ្គត់ផ្គង់ពាក់ព័ន្ធ ឬក្នុងករណីគ្មានការឯកភាពគ្នា ដែលត្រូវបានកំណត់ថាអាចប្រៀបធៀបគ្នាបានដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍នៃរដ្ឋសមាជិកទីមួយ។



https://t.me/oa_channel

ភាពអនុគ្រោះបំផុត) នៃកិច្ចព្រមព្រៀងនេះ និងមាត្រា៣ (សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់) និងមាត្រា៦ (ប្រព្រឹត្តិកម្មដោយអ្នកផ្គត់ផ្គង់មេ) នៃឧបសម្ព័ន្ធនេះ។

៦. ពុំមានអ្វីនៅក្នុងមាត្រានេះត្រូវតម្រូវឱ្យរដ្ឋសមាជិកមួយ ធ្វើការគ្រប់គ្រងអត្រាតម្លៃនិងលក្ខខណ្ឌនានា សម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិឡើយ។

## មាត្រា១៩

## ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ[12] [13]

១. ករណីស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍សាធារណៈណាមួយនៅក្នុងដែនដីរបស់ខ្លួន ធ្វើប្រតិបត្តិការស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ក្នុងនាមជាបណ្ដាញទូរគមនាគមន៍សាធារណៈ រដ្ឋសមាជិកនោះត្រូវធានាថា អ្នកផ្គត់ផ្គង់បែបនោះផ្ដល់ជូនអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលសមហេតុផល និងមិនរើសអើង ស្ថិតក្នុងកាលៈទេសៈដូចគ្នា។

២. ករណីដែលបរិក្ខារនិងសេវាកម្មនៃប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រ មិនអាចជំនួសបានតាមលក្ខណៈសេដ្ឋកិច្ចនិងបច្ចេកទេស នោះរដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេណាមួយដែលកាន់កាប់ឬគ្រប់គ្រងស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ក្នុងដែនដីរបស់ខ្លួន អនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត៖

(i) អាចចូលប្រើប្រាស់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ និង

(ii) ធ្វើសហទីតាំងសម្រាប់ឧបករណ៍បញ្ជូននិងពង្រាយការតភ្ជាប់ នៅឯស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ

ដោយផ្អែកលើខចែងនិងលក្ខខណ្ឌនានា និងនៅក្នុងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង និងតម្លាភាព។

---

[12] ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

[13] សម្រាប់វៀតណាម៖

(i) មាត្រានេះត្រូវអនុវត្តចំពោះតែអ្នកផ្គត់ផ្គង់មេ ដែលកាន់កាប់ឬគ្រប់គ្រងស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិរបស់វៀតណាម

(ii) ក្រោមកថាខណ្ឌ២(i) លទ្ធភាពចូលប្រើប្រាស់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ត្រូវស្របទៅនឹងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកពាក់ព័ន្ធរបស់វៀតណាម និង

(iii) ក្រោមកថាខណ្ឌ២(ii) ការធ្វើសហទីតាំងសម្រាប់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ដែលកាន់កាប់ឬគ្រប់គ្រងដោយអ្នកផ្គត់ផ្គង់មេនៅក្នុងដែនដីរបស់វៀតណាម ត្រូវលើកលែងការធ្វើសហទីតាំងបែបរូបវន្ត។ ប្រការនេះអាចរួមបញ្ចូលការធ្វើសហទីតាំងបែបនិម្មិត។

# ឧបសម្ព័ន្ធស្តីពីសេវាកម្មគាំទ្រដល់ការដឹកជញ្ជូនផ្លូវអាកាស

១. "សេវាកម្មជួសជុលនិងថែទាំអាកាសយាន" សំដៅដល់ សកម្មភាពពាក់ព័ន្ធនឹងការជួសជុល និងការថែទាំ ដែលត្រូវបានប្រព្រឹត្តទៅចំពោះអាកាសយានមួយ ឬមួយផ្នែកនៃអាកាសយាន នៅខណៈពេលដែលអាកាសយាននោះត្រូវបានផ្អាកពីប្រតិបត្តិការសេវាកម្ម ហើយមិនរាប់បញ្ចូលការថែទាំក្នុងខ្សែច្រវាក់ប្រតិបត្តិការសេវាកម្មឡើយ។

២. "ការលក់ឬការធ្វើទីផ្សារចំពោះសេវាកម្មដឹកជញ្ជូនផ្លូវអាកាស" សំដៅដល់ កាលានុវត្តភាពទាំងឡាយសម្រាប់ក្រុមហ៊ុនដឹកជញ្ជូនផ្លូវអាកាសពាក់ព័ន្ធ ដើម្បីលក់ឬធ្វើទីផ្សារដោយសេរីលើសេវាកម្មដឹកជញ្ជូនផ្លូវអាកាសរបស់ខ្លួន ដោយរួមបញ្ចូលគ្រប់ទិដ្ឋភាពនៃការធ្វើទីផ្សារ មានដូចជាការស្រាវជ្រាវទីផ្សារ ការផ្សព្វផ្សាយ និងការចែកចាយ។ សកម្មភាពទាំងនេះមិនរួមបញ្ចូលនូវការកំណត់ថ្លៃនៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាស ឬលក្ខខណ្ឌអនុវត្តឡើយ។

៣. "សេវាកម្មបម្រុងទុកមុនតាមប្រព័ន្ធកុំព្យូទ័រ" សំដៅដល់ សេវាកម្មទាំងឡាយដែលត្រូវបានផ្តល់ដោយប្រព័ន្ធកុំព្យូទ័រ ដែលមានផ្ទុកព័ត៌មានអំពីកាលវិភាគហោះហើររបស់ក្រុមហ៊ុនដឹកជញ្ជូនផ្លូវអាកាស ភាពទំនេររបស់យន្តហោះ ថ្លៃសំបុត្រយន្តហោះ និងលក្ខខណ្ឌនៃថ្លៃ ដែលតាមរយៈប្រព័ន្ធបែបនេះ ការបម្រុងទុកមុនឬការចេញសំបុត្រយន្តហោះអាចប្រព្រឹត្តទៅបាន។

៤. "ការជួលអាកាសយានដោយគ្មានក្រុមអាកាសយានិក" សំដៅដល់ ការជួលអាកាសយានមួយដោយគ្មានក្រុមអាកាសយានិក ដែលជាធម្មតាហៅកាត់ថា "ការជួលស្ងួត"។ ស្ថិតនៅក្រោមកិច្ចព្រមព្រៀងជួលភាគច្រើន អ្នកសុំជួលដែលជាអ្នកផ្តល់នូវក្រុមអាកាសយានិក គឺជាភាគីមានតួនាទីទទួលខុសត្រូវ ហើយក៏ជាអ្នកដែលត្រូវតែអនុវត្តតួនាទីគ្រប់គ្រងប្រតិបត្តិការរបស់អាកាសយាន រួមជាមួយនឹងការទទួលខុសត្រូវនានាចំពោះអ្នកបម្រើការ។

៥. "ការជួលអាកាសយានដោយមានក្រុមអាកាសយានិក" សំដៅដល់ ការជួលអាកាសយានមួយដោយមានក្រុមអាកាសយានិក ដែលជាធម្មតាហៅកាត់ថា "ការជួលសើម"។ នៅក្នុងការជួលសើម អ្នកជួលឱ្យជាធម្មតាអនុវត្តតួនាទីគ្រប់គ្រងប្រតិបត្តិការរបស់អាកាសយាន។ ជាទូទៅ ស្ថានភាពនៃការជួលសើម មានន័យថា អាកាសយាននោះគប្បីត្រូវបានប្រតិបត្តិការក្រោមវិញ្ញាបនបត្រប្រតិបត្តិករផ្លូវអាកាស (AOC) ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដែលចុះបញ្ជីអាកាសយាននោះ។

៦. "សេវាកម្មបញ្ជូនទំនិញផ្លូវអាកាស" សំដៅដល់ សកម្មភាពនិងការរៀបចំសេវាកម្មដឹកជញ្ជូនផ្លូវអាកាសនិងសេវាកម្មពាក់ព័ន្ធ ដែលត្រូវបានផ្តល់ជូនឬអនុវត្តក្នុងនាមតំណាងឱ្យអ្នកបញ្ជូនទំនិញ/អ្នកទទួលទំនិញ សម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសដែលចេញពីអាកាសយានដ្ឋានដើមទៅគោលដៅចុងក្រោយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

វិសាលភាពនៃសេវាកម្ម រួមមានសេវាកម្មដូចខាងក្រោម៖

(i) ការជានាកន្លែងទំនេរសម្រាប់ផ្ទុកទំនិញជាមួយក្រុមហ៊ុនអាកាសចរណ៍

(ii) ការរៀបចំឯកសារចាំបាច់សម្រាប់ការនាំចេញ/នាំចូល

(iii) ការរៀបចំដំណើរការមេបបទគយ

(iv) ការទទួលនិងការប្រគល់ទំនិញ

(v) ការវេចខ្ចប់/ការរៀបចំបញ្ចូលឃ្លាំង

(vi) ការប្រមូលទំនិញដាក់រួមគ្នា និងការដឹកជញ្ជូនទំនិញជាលក្ខណៈដាច់ដោយឡែក

(vii) សេវាកម្មបញ្ជូនទំនិញពីផ្ទះមួយទៅផ្ទះមួយ និងសេវាកម្មភស្តុភារកម្ម និង

(viii) សេវាកម្មដឹកជញ្ជូនទំនិញក្នុងស្រុក។

៧. "**ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំទំនិញ**" សំដៅដល់ សេវាកម្មដែលត្រូវបានផ្តល់ឬរៀបចំសម្រាប់ឃ្លាំងទំនិញ ដំណើរការសម្របសម្រួលនានា និងសេវាកម្មទាំងឡាយសម្រាប់ការផ្ទុកនិងការបម្រើសេវាកម្មគ្រប់គ្រងរៀបចំចំពោះគ្រប់ប្រភេទនៃការដឹកជញ្ជូន ដែលត្រូវបានដឹកជញ្ជូនតាមផ្លូវអាកាស។ ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំទំនិញ គ្របដណ្តប់លើការបម្រើសេវាកម្មគ្រប់គ្រងរៀបចំបែបរូបវន្តនៃទំនិញចេញ/ចូល ការដឹកជញ្ជូនឆ្លងកាត់ ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំចំពោះការដឹកជញ្ជូនមិនប្រក្រតី ការត្រួតពិនិត្យឯកត្តាផ្ទុក (ULD) និងសេវាកម្មពាក់ព័ន្ធនឹងការត្រួតពិនិត្យដោយគយ។

៨. "**សេវាកម្មបម្រើម្ហូបអាហារលើអាកាសយាន**" សំដៅដល់ ការរៀបចំ/ការផលិតម្ហូបអាហារនិងភេសជ្ជៈនានាសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ រួមមាន ការលើកដាក់ឡើង/ចុះនៃឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ក្នុងការបម្រើម្ហូបអាហារ ការរៀបចំរទេះរុញ ទស្សនាវដ្តី ផ្កា វត្ថុអនុស្សាវរីយ៍ និងសម្ភារៈបន្ទាប់បន្សំផ្សេងៗចូលក្នុង/ចេញពីអាកាសយាន ការដុះលាង ការសម្អាត ការទុកដាក់ឧបករណ៍បម្រើម្ហូបអាហារ និងការបោកសម្អាតកម្រាលប្រើប្រាស់ក្នុងបន្ទប់អាកាសយាន។

៩. "**សេវាកម្មចាក់ប្រេងឥន្ធនៈ**" សំដៅដល់ ការគ្រប់គ្រងនិងការធ្វើប្រតិបត្តិការយានយន្តដឹកជញ្ជូនប្រេងឥន្ធនៈសម្រាប់អាកាសយាន និងយានយន្តបម្រើការនៅអាកាសយានដ្ឋាន និងការចែកចាយផលិតផលប្រេងឥន្ធនៈ។ (អង្គការសហប្រជាជាតិ CPC 74220, 74610, 61300, 62113, 622271)

១០. "**ការថែទាំអាកាសយានក្នុងខ្សែច្រវាក់ប្រតិបត្តិការសេវាកម្ម**" សំដៅដល់ ការថែទាំត្រួតពិនិត្យទៀងទាត់និងមិនទៀងទាត់ និងការផ្តល់ការបញ្ជាក់អំពីដំណើរការខុសប្រក្រតី ដែលសកម្មភាពទាំងនេះប្រព្រឹត្តទៅ*នៅតាមផ្លូវ* និងនៅស្ថានីយ៍មូលដ្ឋាន រួមជាមួយនឹងការប្រើប្រាស់រយៈពេលយ៉ាងយូរត្រឹម២៤ម៉ោង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១១. "ការបម្រើសេវាកម្មនៅលើផ្ទៃដី" សំដៅដល់ សេវាកម្មទាំងឡាយ ដែលត្រូវបានផ្តល់ដោយឧបករណ៍គាំទ្រនៅលើផ្ទៃដី សម្រាប់បម្រើសេវាកម្មដល់អាកាសយានមួយនៅពេលមកដល់ ក្នុងអំឡុងពេលកំពុងសំចតរហូតដល់ពេលនៃការចេញដំណើរ។

សេវាកម្មទាំងនោះ រួមមានការសម្របសម្រួលដូចខាងក្រោម៖

(i) ឧបករណ៍គាំទ្រនៅលើផ្ទៃដី (GSE) ឧទាហរណ៍ គ្រាក់ទ័រអូសឬសណ្តោងអាកាសយាន ឧបករណ៍ផ្តល់ខ្យល់ម៉ាស៊ីនត្រជាក់ ឧបករណ៍បញ្ឆេះម៉ាស៊ីនអាកាសយាន ឧបករណ៍ផ្តល់ថាមពលអគ្គិសនី ឧបករណ៍លើកដាក់ឥវ៉ាន់ ឧបករណ៍ ULDs

(ii) សេវាកម្មរថយន្តដឹកជញ្ជូនអ្នកដំណើរ និងក្រុមអាកាសយានិកទៅកាន់និងចេញមកពីអាកាសយាន ឆ្ពោះទៅស្ថានីយ៍អ្នកដំណើរ

(iii) សេវាកម្មសន្តិសុខចំពោះអាកាសយាន ក៏ដូចជាអ្នកដំណើរនៅតំបន់បម្រើសេវាកម្មនៅលើផ្ទៃដី

(iii) សេវាកម្មសម្អាតផ្នែកខាងក្នុងអាកាសយាននិងបង្គន់អនាម័យ

(iv) សេវាកម្មផ្គត់ផ្គង់ទឹកចល័ត

(v) សេវាកម្មកញ្ចប់បុស្តិ៍ប្រៃសណីយ៍ និង

(vi) ការថែទាំឧបករណ៍ GSE និង ULDs ។

១២. "ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើរ" សំដៅដល់ ដំណើរការចំពោះប្រព័ន្ធនៃការចេញដំណើរនិងការមកដល់នៅឯស្ថានីយ៍។ ចំពោះការចេញដំណើរ ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើររួមមានសកម្មភាពចំនួនបី ដូចជា៖ (១) អ្នកដំណើរដែលបានចុះឈ្មោះចូលបញ្ជីពីក្នុងក្រុង ធ្វើការចុះឈ្មោះនៅក្រៅបរិវេណអាកាសយានដ្ឋាន (២) ការចុះឈ្មោះចូលបញ្ជីនៅឯស្ថានីយ៍នៃអាកាសយានដ្ឋាន និង (៣) អ្នកដំណើរដែលបានចុះឈ្មោះចូលបញ្ជីរួច មានឥវ៉ាន់តាមខ្លួននៅឯច្រកអាកាសយាន ហើយធ្វើការចុះចូលបញ្ជីនៅហ្នឹងកន្លែង។ ចំពោះការមកដល់ ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើររួមមានសកម្មភាពចំនួនបី ដូចជា៖ (១) ការដាក់ចុះឥវ៉ាន់របស់អ្នកដំណើរពីអាកាសយាន (២) ការដឹកជញ្ជូនឥវ៉ាន់របស់អ្នកដំណើររវាងអាកាសយាននិងកន្លែងយកឥវ៉ាន់ និង (៣) ការលើកដាក់ឥវ៉ាន់របស់អ្នកដំណើរទៅលើកន្លែងយកឥវ៉ាន់។

១៣. "ការបម្រើសេវាកម្មអ្នកដំណើរ" សំដៅដល់ ការទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មដល់អ្នកដំណើរ ចាប់តាំងពីកន្លែងនៃការចុះឈ្មោះចូលបញ្ជីទៅដល់អាកាសយាន ស្របទៅតាមនីតិវិធី និងសេចក្តីណែនាំរបស់ក្រុមហ៊ុនដឹកជញ្ជូន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គេហទំព័រ ឯកសារស្ថាប័នគណៈ | https://t.me/oa_channel